ឯករាជ្យ សន្តិភាព សេរីភាព
ប្រជាធិបតេយ្យ អព្យាក្រឹត និងវឌ្ឍនភាពសង្គម

គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការគណបក្សក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជា
ប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# ខ្លឹមសារគន្លឹះ

## មាគ៌ាដឹកនាំ កម្មវិធីនយោបាយ យុទ្ធសាស្ត្រ និងបទពិសោធន៍

លេខាធិការដ្ឋាន
២០១៨

ឯករាជ្យ សន្តិភាព សេរីភាព
ប្រជាធិបតេយ្យ អព្យាក្រឹត និងវឌ្ឍនភាពសង្គម

គណបក្សប្រជាជនកម្ពុជា
គណៈកម្មាធិការគណបក្សក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជា
ប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# ខ្លឹមសារគន្លឹះ

## មាគ៌ាដឹកនាំ កម្មវិធីនយោបាយ យុទ្ធសាស្ត្រ និងបទពិសោធន៍

លេខាធិការដ្ឋាន
២០១៨

# សេចក្តីផ្តើម

នៅក្នុងក្របខ័ណ្ឌនៃផែនការប្រតិបត្តិរបស់ខ្លួន, ក្រុមការងារយុវជនប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(**កយក**) បានកំណត់និងដាក់ចេញនូវចក្ខុវិស័យវែងឆ្ងាយនិងច្បាស់-លាស់ គឺយុវជនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុគឺជាកម្លាំងសាមគ្គីដ៏រឹងមាំនិងស្មោះស្ម័គ្រភក្តីចំពោះគណបក្ស ដើម្បីចូលរួមចំណែកថែរក្សានិងលើកតម្កើងឧត្តមប្រយោជន៍ជាតិ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។

ក្នុងគោលដៅសម្រេចចក្ខុវិស័យខាងលើ **កយក** មានបេសកកម្មដ៏ចំបងគឺពង្រឹងនិងពង្រីកស្មារតីសាមគ្គីនិងគាំទ្រមាគ៌ានយោបាយរបស់គណបក្ស និងចូលរួមបោះឆ្នោតជូនគណបក្ស ដែលបេសកកម្មនេះទាមទារជាចាំបាច់នូវការពន្យល់និងផ្តល់ជូនយុវជនគណ-បក្ស នូវចំណេះដឹងលើមាគ៌ាដឹកនាំ កម្មវិធីនយោបាយ យុទ្ធសាស្ត្រ បទពិសោធន៍ និងស្នាដៃជាប្រវត្តិសាស្ត្ររបស់គណបក្ស ក៏ដូចជារបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់គណបក្ស។ ក្នុងស្មារតីនេះ **កយក** បានខិតខំប្រមូលនិងចងក្រងនូវឯកសារសំខាន់ៗរបស់គណបក្ស និងរបស់រាជរដ្ឋាភិបាលជាច្រើនឯកសារ ដោយសង្ខេបរំលេចចេញតែខ្លឹមសារគន្លឹះសំខាន់ៗ ដើម្បីជាជំនួយស្មារតី ដែលជួយសម្រួលដល់ការស្វែងយល់របស់យុវជនគណបក្សប្រជាជន នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ឯកសារខាងលើ ត្រូវបានប្រមូលផ្តុំក្នុងមាតិកានុក្រមតែមួយ ហើយបែងចែកជា ៤ផ្នែក ទៅតាមកម្មវត្ថុនៃអត្ថបទដូចខាងក្រោម÷

ផ្នែកទី១. មាគ៌ាដឹកនាំ ដែលរំលេចនូវខ្លឹមសារគន្លឹះ ពាក់ព័ន្ធបទបញ្ជាផ្ទៃក្នុងនិងលក្ខន្តិកៈគណបក្ស ព្រមទាំងការកសាងអត្តចរិតសីលធម៌របស់មន្ត្រីគណបក្ស

ផ្នែកទី២. កម្មវិធីនយោបាយ ដែលរំលេចនូវខ្លឹមសារគន្លឹះ ពាក់ព័ន្ធគោលនយោបាយនិងកម្មវិធីនយោបាយរបស់គណបក្ស

ផ្នែកទី៣. យុទ្ធសាស្ត្រ ដែលរំលេចនូវខ្លឹមសារគន្លឹះ នៃយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណ តាំងពីដំណាក់កាលទី១ ដល់ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលក្រោមការដឹកនាំរបស់គណបក្ស

ផ្នែកទី៤. បទពិសោធន៍ ដែលរំលេចនូវខ្លឹមសារគន្លឹះ ពាក់ព័ន្ធសាវតារស្នាដៃធំៗនិងបទពិសោធន៍របស់គណបក្ស។

# មាតិកានុក្រម


ផ្នែកទី១. មាគ៌ាដឹកនាំ........................................................................ ១

១. បទបញ្ញាផ្ទៃក្នុងរបស់គណបក្សប្រជាជនកម្ពុជា....................................... ១

២. លក្ខន្តិកៈរបស់គណបក្សប្រជាជនកម្ពុជា.............................................. ១៩

៣. ការយល់ដឹងអំពីលក្ខន្តិកៈគណបក្សប្រជាជនកម្ពុជា ........................... ៣៥

៤. ការកសាងអត្តចរិត សីលធម៌ល្អប្រពៃរបស់មន្ត្រីគណបក្ស...................... ៣៩

ផ្នែកទី២. កម្មវិធីនយោបាយ ........................................................... ៤៣

១. គោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជាសម្រាប់កសាង និងការពារ មាតុភូមិ ឆ្នាំ២០១៨-២០២៣ ................................................... ៤៣

២. កម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា ២០១៨-២០២៣.......... ៤៥

៣. គោលការណ៍គ្រឹះនៃកម្មវិធីនយោបាយរបស់គណបក្ស........................ ៥៣

ផ្នែកទី៣. យុទ្ធសាស្ត្រ ................................................................ ៥៥

១. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣........................................... ៥៥

២. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២...........................................៦៧

៣. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១........................................... ៨៥

៤. យុទ្ធសាស្ត្រត្រីកោណ..................................................................១០៩

ផ្នែកទី៤. បទពិសោធន៍ ................................................................១១៣

១. ស្នាដៃធំៗ ៨ យ៉ាង របស់គណបក្សប្រជាជនកម្ពុជា............................១១៣

២. សាវតារ ស្នាដៃធំៗជាប្រវត្តិសាស្ត្រ និងបទពិសោធន៍...........................១១៥

៣. សភាពការណ៍កម្ពុជា និងបណ្តាភារកិច្ចចំពោះមុខ............................ ១២៥

# ផ្នែកទី១. មាគ៌ាដឹកនាំ

## ១. បទបញ្ញាផ្ទៃក្នុងរបស់គណបក្សប្រជាជនកម្ពុជា

បទបញ្ញាផ្ទៃក្នុងរបស់គណបក្សប្រជាជនកម្ពុជា ត្រូវបានអនុម័តដោយសន្និបាតគណៈកម្មាធិការកណ្តាល លើកទី២៣ នៅរាជធានីភ្នំពេញ នាថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៧ ដែលមាន ១២ ជំពូក និង ៣៧ ប្រការ ដូចខាងក្រោម÷

### ជំពូក១÷ គោលបំណង ឧត្តមគតិរបស់គណបក្ស ថ្ងៃកំណើតគណបក្ស

**ប្រការ១** ÷ គណបក្សប្រជាជនកម្ពុជា បានបដិសន្ធិឡើងទៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១។ គណបក្សប្រជាជនកម្ពុជាប្រកាន់ភ្ជាប់ឧត្តមគតិស្នេហាជាតិ ហ៊ានធ្វើពលិកម្មគ្រប់យ៉ាងដើម្បីប្រយោជន៍ប្រទេសជាតិ និងប្រជាជន ខិតខំបង្រួបបង្រួមប្រមូលផ្តុំកម្លាំងរបស់ជាតិទាំងមូល ដើម្បីកសាងប្រទេសកម្ពុជា ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ អព្យាក្រឹត និងវឌ្ឍនភាពសង្គម។

**ប្រការ២** ÷ ដើម្បីជាសក្ខីភាពនៃបុព្វហេតុរបស់គណបក្ស ជារៀងរាល់ឆ្នាំ គណបក្សចាត់តាំងប្រារព្ធពិធីបុណ្យជាផ្លូវការរបស់គណបក្សចំនួន ៤ គឺ÷

- បុណ្យខួបកំណើតគណបក្ស ២៨ មិថុនា ១៩៥១
- បុណ្យខួបទិវាប្រជាជនកម្ពុជា បានរួចចាកផុតពីរបបប្រល័យពូជសាសន៍ ៧ មករា ១៩៧៩
- បុណ្យខួបកំណើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ២ ធ្នូ ១៩៧៨
- ទិវាគោរពវិញ្ញាណក្ខ័ន្ធប្រជាជនកម្ពុជា ដែលរងគ្រោះដោយរបបប្រល័យពូជសាសន៍ប៉ុលពត ២០ ឧសភា។

គណបក្សគ្រប់ថ្នាក់មានកាតព្វកិច្ចត្រូវចាត់តាំងប្រារព្ធពិធីបុណ្យ ទាំងបួននេះ ឱ្យបានសមស្របតាមលទ្ធភាព កាលៈទេសៈ និងទីកន្លែងនីមួយៗ។

## ជំពូក២÷ ឈ្មោះ សញ្ញា បទភ្លេង និងចំរៀងគណបក្ស

**ប្រការ៣** ÷ ឈ្មោះ និងផ្លាកសញ្ញារបស់គណបក្សត្រូវលើកនៅ :

- ទីស្នាក់ការកណ្តាលនារាជធានីភ្នំពេញ
- គ្រប់ទីស្នាក់ការរបស់គណបក្សខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- សាលប្រជុំនានារបស់គណបក្សគ្រប់ថ្នាក់
- កន្លែងផ្សេងៗទៀតស្របតាមការកំណត់នៃច្បាប់
- បោះពុម្ពលើសៀវភៅឯកសាររបស់គណបក្ស
- ផលិតជាស្លាកសញ្ញាសម្រាប់ពាក់លើអាវក្នុងពិធីផ្សេងៗរបស់គណបក្ស។

**ប្រការ៤** ÷ បទភ្លេង និងចំរៀងគណបក្ស ត្រូវប្រើប្រាស់ជាផ្លូវការក្នុងពិធីនានារបស់គណបក្ស :

- ពិធីបញ្ចូលសមាជិកគណបក្ស
- សន្និបាត ឬមហាសន្និបាតរបស់គណបក្ស
- ពិធីបុណ្យរបស់គណបក្ស។

## ជំពូក៣÷ មហាសន្និបាតតំណាងទូទាំងប្រទេស

**ប្រការ៥** ÷ មហាសន្និបាតតំណាងទូទាំងប្រទេស គឺជាអង្គការដឹកនាំខ្ពស់បំផុតរបស់គណបក្ស។ មហាសន្និបាតមានភារកិច្ច :

- ពិនិត្យពិភាក្សា និងអនុម័តលើរបាយការណ៍នយោបាយរបស់គណៈកម្មាធិការកណ្តាលអំពីសភាពការណ៍រួមរបស់គណបក្ស
- កំណត់គោលនយោបាយក្នុងប្រទេស ក្រៅប្រទេស និងភារកិច្ចរបស់គណបក្ស តាមដំណាក់កាលនីមួយៗ
- បំពេញបន្ថែម ឬកែសម្រួលលក្ខន្តិកៈគណបក្ស
- រំសាយគណៈកម្មាធិការកណ្តាលចាស់ និងបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការកណ្តាលសម្រាប់អាណត្តិថ្មី។

មហាសន្និបាតតំណាងទូទាំងប្រទេស ប្រជុំ ៥ឆ្នាំម្តង។ តំណាងចូលរួមមហាសន្និបាតត្រូវបានបោះឆ្នោតជ្រើសតាំងដោយមហាសន្និបាត ថ្នាក់ក្រោមផ្ទាល់ លើកលែងសមាជិកគណៈកម្មាធិការកណ្តាលដែលជាតំណាងដោយស្វ័យប្រវត្តិ។ ក្នុងករណីដែលមិនអាចបើកមហាសន្និបាតតំណាងសាមញ្ញបាន ឬបើមានភារកិច្ចបន្ទាន់ចំពោះមុខ និងដោយមានសំណើរបស់សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ចំនួន ២ ភាគ ៣ ឬសំណើរបស់សមាជិកគណៈកម្មាធិការកណ្តាលចំនួន ១ ភាគ ៣ នោះអាចកោះប្រជុំមហាសន្និបាតតំណាងទូទាំងប្រទេសជាវិសាមញ្ញ។ តំណាងចូលរួមមហាសន្និបាតវិសាមញ្ញអាស្រ័យដោយគណៈកម្មាធិការកណ្តាលសម្រេចចង្អុលចុះ តាមសំណើរបស់គណៈអចិន្ត្រៃយ៍។ តំណាងចូលរួមមហាសន្និបាត ជាអ្នកដែលបានចូលរួមអនុវត្តយ៉ាងសកម្មនូវភារកិច្ចនយោបាយ និងការងាររបស់គណបក្ស មានការយល់ដឹងច្បាស់អំពីគោលការណ៍ គោលនយោបាយនានារបស់គណបក្ស មានស្មារតីទទួលខុសត្រូវចំពោះបុព្វហេតុរបស់គណបក្ស និងរបស់ប្រទេសជាតិ។ មហាសន្និបាតតំណាងវិសាមញ្ញ មានភារកិច្ចដូចមហាសន្និបាតតំណាងសាមញ្ញដែរ លើកលែងតែការបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការកណ្តាល គឺមានភារកិច្ចត្រឹមកែសម្រួល ឬបំពេញបន្ថែមសមាជិកនៃគណៈកម្មាធិការកណ្តាលប៉ុណ្ណោះ។

**ប្រការ៦** ÷ គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល រៀបចំ និងកោះអញ្ជើញតំណាងចូលរួមមហាសន្និបាតតំណាងទូទាំងប្រទេស តាមការសម្រេចរបស់គណៈកម្មាធិការកណ្តាល។ ការជូនដំណឹងក្នុងគណបក្ស ស្តីពីការបើកមហាសន្និបាតតំណាងទូទាំងប្រទេស ត្រូវធ្វើឱ្យបានយ៉ាងតិច ១ ខែមុនពេលបើកសម័យប្រជុំ ដោយភ្ជាប់ជាមួយនូវរបៀបវារៈការកំណត់អំពីសមាសភាព និងចំនួនតំណាងដែលត្រូវមកចូលរួម។

**ប្រការ៧** ÷ មហាសន្និបាតតំណាងទូទាំងប្រទេស ដែលចាត់ទុកជាបានការលុះត្រាតែមាន

សមាជិកគណៈកម្មាធិការកណ្ដាលយ៉ាងតិច ២ ភាគ ៣ និងមានតំណាងលើសពីពាក់កណ្ដាលនៃចំនួនគណបក្សថ្នាក់ក្រោម ដែលចំណុះផ្ទាល់គណៈកម្មាធិការកណ្ដាលចូលរួម ហើយចំនួនតំណាងដែលមិនមែនជាសមាជិកគណៈកម្មាធិការកណ្ដាល ត្រូវតែមានលើសពីចំនួនសមាជិកគណៈកម្មាធិការកណ្ដាលទាំងមូល។ ការអនុម័តរបស់មហាសន្និបាតតំណាង គឺកំណត់សម្លេងភាគច្រើន។

## ជំពូក៤÷ គណៈកម្មាធិការកណ្ដាល

**ប្រការ៨ ÷** គណៈកម្មាធិការកណ្ដាល ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតរបស់មហាសន្និបាតតំណាងទូទាំងប្រទេសដើម្បីដឹកនាំការងាររបស់គណបក្ស ក្នុងចន្លោះពីមហាសន្និបាតតំណាងសាមញ្ញមួយ ទៅមហាសន្និបាតតំណាងសាមញ្ញមួយទៀត។

**ប្រការ៩÷** ចំនួនសមាជិកគណៈកម្មាធិការកណ្ដាល និងបញ្ជីឈ្មោះបេក្ខជន ត្រូវបានអនុម័តដោយមហាសន្និបាតតំណាងទូទាំងប្រទេស តាមសំណើរបស់គណៈកម្មាធិការកណ្ដាល។ ការជ្រើសតាំងគណៈកម្មាធិការកណ្ដាល ត្រូវធ្វើតាមវិធីបោះឆ្នោតលើបញ្ជីឈ្មោះបេក្ខជន និងតាមបែបបទដែលកំណត់ដោយមហាសន្និបាតតំណាងទូទាំងប្រទេស។ បេក្ខជនដែលមានសំលេងគាំទ្រលើសពីពាក់កណ្ដាលនៃចំនួនអ្នកបោះឆ្នោតដោយរាប់តាមលំដាប់លេខរៀងពីខ្ពស់ទៅទាប រហូតដល់គ្រប់ចំនួនដែលបានកំណត់ ត្រូវជាប់ឆ្នោតជាសមាជិកគណៈកម្មាធិការកណ្ដាល។

**ប្រការ១០÷** សន្និបាតគណៈកម្មាធិការកណ្ដាលត្រូវធ្វើ២ដងក្នុង១ឆ្នាំ។ ក្នុងករណីចាំបាច់អាចបើកសន្និបាតវិសាមញ្ញ។ គណៈអចិន្ត្រៃយ៍កណ្ដាល កោះប្រជុំសន្និបាតគណៈកម្មាធិការកណ្ដាលដោយត្រូវធ្វើលិខិតអញ្ជើញជូនសមាជិកយ៉ាងតិច ១៥ថ្ងៃ មុនពេលប្រជុំ លើកលែងតែក្នុងការប្រញាប់ និងត្រូវភ្ជាប់ជាមួយនូវរបៀបវារៈនៃការប្រជុំ។ ការអនុម័ត របស់សន្និបាតគណៈកម្មាធិការកណ្ដាល

កំណត់យកសម្លេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកគណៈកម្មាធិការកណ្តាលទាំងមូល លើកលែងតែការដាក់វិន័យចំពោះសមាជិក និងអង្គការចាត់តាំងគណបក្សដែលមានការកំណត់ដោយឡែក។

**ប្រការ១១÷** សមាជិកគណៈកម្មាធិការកណ្តាលមានភារកិច្ច ត្រូវក្តាប់ជាប់នូវកម្មវិធីនយោបាយ សេចក្តីសម្រេចចិត្ត គោលការណ៍នយោបាយនានារបស់គណបក្ស ដើម្បីចាត់តាំងអនុវត្តឱ្យមានប្រសិទ្ធភាពនៅតាមផ្នែក ឬថ្នាក់ដែលខ្លួនទទួលខុសត្រូវ និងខិតខំតស៊ូដើម្បីប្រែក្លាយគោលការណ៍ គោលនយោបាយរបស់គណបក្សឱ្យទៅជាច្បាប់ និងគោលការណ៍រួមរបស់រដ្ឋ។ សមាជិកគណៈកម្មាធិការកណ្តាល ធ្វើសកម្មភាពទីណា ត្រូវរួមចំណែកទទួលខុសត្រូវក្នុងការដឹកនាំការងារគណបក្ស និងចូលរួមក្នុងការកសាងពង្រឹងគណបក្សនៅទីនោះ។ ក្នុងរយៈពេល ១ ត្រីមាសម្តង សមាជិកគណៈកម្មាធិការកណ្តាលត្រូវធ្វើរបាយការណ៍ជូនគណៈអចិន្ត្រៃយ៍អំពីសកម្មភាពរបស់ខ្លួន ក្នុងការអនុវត្តភារកិច្ចនយោបាយរបស់គណបក្ស។ សមាជិកគណៈកម្មាធិការកណ្តាលមានសិទ្ធិផ្តល់មតិជាលាយលក្ខណ៍អក្សរ ជូនគណៈអចិន្ត្រៃយ៍អំពីការងាររបស់គណបក្ស ហើយរាល់មតិរបស់ខ្លួនត្រូវបានទទួលនូវការឆ្លើយតប។

### ជំពូក៥÷ ប្រធាន អនុប្រធាន និងប្រធានកិត្តិយស

**ប្រការ១២÷** ប្រធាន អនុប្រធាន និងប្រធានកិត្តិយស ជាថ្នាក់ដឹកនាំកំពូលរបស់គណបក្ស។ ប្រធានគណបក្ស ជាប្រធានគណៈកម្មាធិការកណ្តាល និងជាប្រធានគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល។ ប្រធានគណបក្សទទួលខុសត្រូវដឹកនាំលើគ្រប់វិស័យការងាររបស់គណបក្ស តាមគោលការណ៍រួមដែលបានសម្រេចដោយគណៈកម្មាធិការកណ្តាល និងគណៈអចិន្ត្រៃយ៍។ អនុប្រធានទទួលខុសត្រូវជួយប្រធានដឹកនាំការងារមួយចំនួន តាមការប្រគល់ភារកិច្ចរបស់ប្រធាន និងគណៈអចិន្ត្រៃយ៍ និងតំណាងឱ្យប្រធាននៅពេលដែល

ប្រធានអវត្តមាន។ ប្រធានកិត្តិយស ជាឥស្សរជនដែលមានគុណបំណាច់យ៉ាងធំធេងចំពោះគណបក្ស ត្រូវបានសន្និបាតគណៈកម្មាធិការកណ្តាលអនុម័ត។

**ប្រការ១៣÷** ប្រធានគណបក្ស ត្រូវបានជ្រើសតាំងដោយសន្និបាតគណៈកម្មាធិការកណ្តាល តាមរយៈការបោះឆ្នោតដោយសំឡេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកគណៈកម្មាធិការកណ្តាលទាំងមូល។ បើសិនជាក្នុងការបោះឆ្នោតលើកទី១ គ្មានបេក្ខជនណាទទួលបានសំលេងភាគច្រើនដាច់ខាតទេនោះ ត្រូវជ្រើស-រើសយកតែបេក្ខជន ២រូប ដែលបានទទួលសំលេងច្រើនជាងគេក្នុងការបោះឆ្នោតលើកទី១ ដើម្បីធ្វើការបោះឆ្នោតលើកទី២ ជ្រើសរើសយកបេក្ខជនដែលបានសំលេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកគណៈកម្មាធិការកណ្តាលទាំងមូលធ្វើជាប្រធាន។ បើសិនជាក្នុងការបោះឆ្នោតលើកទី២ គ្មានបេក្ខជនណាទទួលបានសំលេងភាគច្រើនដាច់ខាតទេនោះ ត្រូវជ្រើសរើសយកតែបេក្ខជន ដែលបានទទួលសំលេងច្រើនជាងគេ ក្នុងការបោះឆ្នោតលើកទី២ ដើម្បីធ្វើការអនុម័ត បើបេក្ខជននោះទទួលបានសំលេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកគណៈកម្មាធិការកណ្តាលទាំងមូល គឺត្រូវបានជាប់ឆ្នោតជាប្រធាន។ បើសិនជាក្នុងការអនុម័តនេះមិនបានទទួលសំលេងភាគច្រើនដាច់ខាតទេនោះ ត្រូវជ្រើសរើសបេក្ខជន និងធ្វើការបោះឆ្នោតជ្រើសរើសប្រធានសាជាថ្មី។ អនុប្រធានគណបក្សត្រូវបានជ្រើសតាំងដោយសន្និបាតគណៈកម្មាធិការកណ្តាល តាមវិធីដូចគ្នានឹងការជ្រើសតាំងប្រធាន។

**ប្រការ១៤÷** ប្រធាន អនុប្រធានគណបក្ស ត្រូវបានជ្រើសតាំងសម្រាប់អាណត្តិ ៥ឆ្នាំ។ ក្នុងករណីដែលប្រធានគណបក្សទទួលមរណភាព ឬមិនអាចបំពេញភារកិច្ចបានប្រការផ្សេងៗនោះ អនុប្រធានត្រូវទទួលដឹកនាំការងារបន្តជាប្រធានស្តីទីរហូតដល់ពេលមានការជ្រើសតាំងប្រធានគណបក្សថ្មី។

ក្នុងករណីដែលមុខតំណែងប្រធាន អនុប្រធានគណបក្សនៅទំនេរដោយប្រការផ្សេងៗរយៈពេលយ៉ាងតិច ៣ខែ ត្រូវរៀបចំជ្រើសតាំងប្រធាន អនុ-ប្រធានថ្មីជំនួសរហូតដល់ចប់អាណត្តិ។

**ជំពូក៦÷ គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល**

**ប្រការ១៥÷** គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ត្រូវបានជ្រើសតាំងក្នុងចំណោមសមាជិកគណៈកម្មាធិការកណ្តាល តាមរយៈការបោះឆ្នោតរបស់សន្និបាតគណៈកម្មាធិការកណ្តាល ដោយយកសំលេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកគណៈកម្មាធិការកណ្តាលទាំងមូល។ ក្នុងករណីចាំបាច់ដោយយោងតាមសំណូមពរ ភារកិច្ចជាក់ស្តែងតាមសំណើរបស់គណៈអចិន្ត្រៃយ៍ សន្និបាតគណៈកម្មាធិការកណ្តាល អាចជ្រើសតាំងបំពេញសមាជិកគណៈអចិន្ត្រៃយ៍តាមរយៈការបោះឆ្នោត ដោយសំលេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកគណៈកម្មាធិការកណ្តាលទាំងមូល។

**ប្រការ១៦÷** គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ដឹកនាំរាល់ការងាររបស់គណ-បក្សក្នុងចន្លោះពេលពីសន្និបាតពេញអង្គមួយ ទៅសន្និបាតពេញអង្គមួយទៀតរបស់គណៈកម្មាធិការកណ្តាល ដោយផ្អែកលើសេចក្តី សម្រេចចិត្តនៃមហាសន្និបាតតំណាងទូទាំងប្រទេស និងសន្និបាតគណៈកម្មាធិការកណ្តាល។ គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលមានភារកិច្ច÷

- កំណត់គោលការណ៍ វិធានការធំៗដើម្បីអនុវត្តសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតតំណាង ទូទាំងប្រទេស និងសន្និបាតគណៈកម្មាធិការកណ្តាល
- កំណត់ទិសដៅភារកិច្ចធំៗ តាមរយៈពេលនីមួយៗលើគ្រប់ផ្នែកការងាររបស់គណបក្សជាអាទិ៍ការងារនយោបាយ សតិអារម្មណ៍ ការងារចាត់តាំងកសាងបក្ស ការងារហិរញ្ញវត្ថុ ការកសាងធនធានមនុស្ស

- រៀបចំរចនាសម្ព័ន្ធ នៃអង្គការចាត់តាំង របស់គណបក្សចំណុះផ្ទាល់គណៈកម្មាធិការ
- ណែនាំគោលការណ៍ កសាងរចនាសម្ព័ន្ធ ខ្សែរយៈចាត់តាំង និងសកម្មភាពរបស់អង្គការចាត់តាំងគណបក្សថ្នាក់ក្រោម
- កំណត់ក្របខ័ណ្ឌ និងគោលនយោបាយនានាសម្រាប់មន្ត្រី បុគ្គលិក កម្មករបំរើការងារក្នុងអង្គការចាត់តាំងនានារបស់គណបក្សគ្រប់ថ្នាក់
- រៀបចំចាត់តាំង ប្រគល់ភារកិច្ច តំឡើងឋានៈ និងអនុវត្តវិន័យចំពោះមន្ត្រីរបស់គណបក្សដែលស្ថិតក្នុងសមត្ថកិច្ចគ្រប់គ្រងផ្ទាល់
- សម្រេចអំពីការសុំចូលជាសមាជិកគណបក្សក្នុងករណីពិសេស
- សម្រេចជ្រើសរើសសមាជិកគណបក្ស ដើម្បីឈរឈ្មោះជាបេក្ខជនក្នុងការបោះឆ្នោតតំណាងរាស្ត្រ
- ជ្រើសរើសសមាជិកគណបក្សចូលកាន់មុខនាទីក្នុងរាជរដ្ឋាភិបាល និងស្ថាប័នរបស់រដ្ឋ
- រៀបចំខ្លឹមសារសម្រាប់សន្និបាតគណៈកម្មាធិការកណ្តាល
- អនុវត្តនយោបាយការបរទេសរបស់គណបក្ស
- ត្រួតពិនិត្យការងារនៃរាល់ស្ថាប័ន និងគណៈកម្មាធិការគណបក្សចំណុះ។

**ប្រការ១៧ ÷** គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ប្រជុំមួយខែម្តង ហើយអាចប្រជុំមុនពេលកំណត់ បើសិនជាមានការបន្ទាន់ និងចាំបាច់អាស្រ័យដោយប្រធានគណបក្សកោះប្រជុំ។ ការអនុម័តរបស់គណៈអចិន្ត្រៃយ៍ ដោយកំណត់យកសំលេងភាគច្រើននៃចំនួនសមាជិកគណៈអចិន្ត្រៃយ៍ទាំងមូល លើកលែងតែការអនុម័តដាក់ពិន័យសមាជិក និងអង្គការចាត់តាំងគណបក្សដែលមានការកំណត់ដោយឡែក ។

## ជំពូក៧÷ គណៈប្រចាំការរបស់គណៈអចិន្ត្រៃយ៍

**ប្រការ១៨÷** គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល បង្កើតគណៈប្រចាំការរបស់គណៈអចិន្ត្រៃយ៍រួមមាន ប្រធាន ១រូប និងសមាជិកមួយចំនួនដែលបានជ្រើសរើសនៅក្នុងចំណោមសមាជិក គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ។

**ប្រការ១៩÷** គណៈប្រចាំការទទួលខុសត្រូវជំនួសមុខគណៈអចិន្ត្រៃយ៍ ដើម្បីដោះស្រាយការងារប្រចាំថ្ងៃតាមការប្រគល់ភារកិច្ចរបស់គណៈអចិន្ត្រៃយ៍។ ប្រធានគណៈ-ប្រចាំការធ្វើទំនាក់ទំនងជាប្រចាំជាមួយប្រធាន និងអនុប្រធានគណបក្ស ដើម្បីរាយការណ៍សុំគោលការណ៍ដឹកនាំ និងត្រួតពិនិត្យដោះស្រាយការងារ។

**ប្រការ២០÷** គណៈប្រចាំការរបស់គណៈអចិន្ត្រៃយ៍ប្រជុំក្នុង ១សប្តាហ៍ម្តង។ ក្នុងករណីមានការចាំបាច់ និងបន្ទាន់ អាចប្រជុំមុនពេលកំណត់។ ការអនុម័តរបស់គណៈប្រចាំការ កំណត់យកសំលេងភាគច្រើននៃចំនួនសមាជិកគណៈប្រចាំការទាំងមូល។

## ជំពូក៨÷ ស្ថាប័នជំនួយការរបស់គណបក្ស

**ប្រការ២១÷** ស្ថាប័នជំនួយការរបស់គណៈកម្មាធិការកណ្តាលរួមមាន÷

១. ខុទ្ទកាល័យ

២. គណៈចាត់តាំង

៣. គណៈឃោសនាអប់រំ

៤. គណៈកម្មាធិការត្រួតពិនិត្យ

៥. គណៈស្រាវជ្រាវប្រវត្តិសាស្ត្រគណបក្ស

៦. គណៈកម្មាធិការហិរញ្ញវត្ថុ

៧. គណៈទាក់ទងបរទេស។

ស្ថាប័ននីមួយៗ ទទួលខុសត្រូវធ្វើជាសេនាធិការឲ្យគណៈកម្មាធិការកណ្តាល លើផ្នែកការងារជំនាញតាមតួនាទី ភារកិច្ច ដែលបានកំណត់ដោយគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល។ ខុទ្ទកាល័យ គណៈកម្មាធិការកណ្តាល សហការជាមួយគ្រប់ស្ថាប័ន ដើម្បរៀបចំកម្មវិធីការងារ និងខ្លឹមសារប្រជុំរបស់គណៈប្រចាំការ គណៈអចិន្ត្រៃយ៍ និងសន្និបាតគណៈកម្មាធិការកណ្តាល ។

**ប្រការ២២÷** យោងតាមសំណូមពរភារកិច្ចជាក់ស្តែង គណៈអចិន្ត្រៃយ៍សម្រេចចាត់តាំងក្រុមការងារ ក្រុមជំនួយការ ដើម្បីអនុវត្តការងារចាំបាច់មួយចំនួន។ ក្រុមការងារ ក្រុមជំនួយការទាំងនោះ នឹងត្រូវរំសាយជាស្វ័យប្រវត្តិនៅពេលចប់ភារកិច្ចរបស់ខ្លួន ។

## ជំពូក៩÷ គណៈកម្មាធិការគណបក្សមូលដ្ឋាន

**ប្រការ២៣÷** គណៈកម្មាធិការគណបក្សមូលដ្ឋាន ជាអង្គការចាត់តាំងមូលដ្ឋានរបស់គណបក្ស។ គណៈកម្មាធិការគណបក្សមូលដ្ឋាន ត្រូវបានបង្កើតឡើងនៅតាមឃុំ សង្កាត់ គ្រឹះស្ថានសិក្សា មន្ទីរពេទ្យ អង្គភាពផលិតកម្ម អាជីវកម្ម សិប្បកម្ម និងអង្គការសង្គមនានា ដែលមានសមាជិកគណបក្សចាប់ពី ៥០ នាក់ឡើងទៅ។ ចំពោះមូលដ្ឋានដែលមានសមាជិកគណបក្សតិចជាង ៥០នាក់ ត្រូវបង្កើតជាសាខាគណបក្សមូលដ្ឋាន។ គណៈកម្មាធិការគណបក្សមូលដ្ឋាន មានសាខាចំណុះតិច ឬច្រើនស្របទៅតាមសភាពការណ៍ជាក់ស្តែងនៃមូលដ្ឋាននីមួយៗ។ ចំពោះសាខាចំណុះនៅមូលដ្ឋាន ឬផ្នែកណាដែលមានសមាជិកគណបក្សច្រើន ត្រូវបង្កើតអនុសាខា និងចងក្រងជាក្រុមបក្សចំណុះអនុសាខា។

**ប្រការ២៤÷** គណៈកម្មាធិការគណបក្សមូលដ្ឋាន រួមមាន ប្រធាន អនុប្រធាន និងសមាជិកមួយចំនួន។ បរិមាណសមាជិគណៈកម្មាធិការគណបក្សមូលដ្ឋានមានតិច ឬ

ច្រើន ដោយយោងទៅតាមបរិមាណសមាជិកគណបក្សក្នុងមូលដ្ឋាននីមួយៗ។ ត្រូវពិនិត្យដើម្បីជ្រើសរើសអ្នកដឹកនាំនៅតាមមូលដ្ឋានសំខាន់ៗ ដូចជាប្រធានសាខាភូមិ នាយក ឬនាយករង សាលារៀន មន្ទីរពេទ្យ រោងចក្រ សហគ្រាសប្រធាន ឬអនុប្រធានអង្គភាពអាជីវកម្ម ផលិតកម្ម បញ្ចូលជាសមាជិកគណៈកម្មាធិការគណបក្សមូលដ្ឋាន។ គណៈកម្មាធិការ គណបក្សមូលដ្ឋាន ត្រូវបែងចែកភារកិច្ចឱ្យសមាជិកនីមួយៗ ទទួលបន្ទុកផ្នែកការងារគណបក្សនីមួយៗ និងទទួលបន្ទុកដឹកនាំផ្ទាល់សាខាចំណុះ។ គណៈកម្មាធិការគណបក្សមូលដ្ឋានដែលមានបរិមាណសមាជិកពី ៩នាក់ ឡើងទៅ ត្រូវបង្កើតឱ្យមានចំនួនសមាជិកអចិន្ត្រៃយ៍ស្មើនឹង ១ ភាគ ៣ នៃសមាជិកគណៈកម្មាធិការគណបក្សទាំងអស់ដើម្បីដឹកនាំការងារគណបក្សគ្រប់ផ្នែកជាប្រចាំ ។

**ប្រការ២៥ ÷** ការគ្រប់គ្រងគណៈកម្មាធិការគណបក្សមូលដ្ឋាន ត្រូវបានកំណត់ ដូចខាងក្រោមៈ

- គណៈកម្មាធិការគណបក្សមូលដ្ឋានឃុំ សង្កាត់ ត្រូវចំណុះការដឹកនាំផ្ទាល់របស់គណៈកម្មាធិការគណបក្សស្រុក ខណ្ឌ។
- គណៈកម្មាធិការគណបក្សមូលដ្ឋាន គ្រឹះស្ថានសិក្សាៈ

* កំរិតអនុវិទ្យាល័យ ត្រូវស្ថិតក្រោមការដឹកនាំផ្ទាល់របស់គណៈកម្មាធិការគណបក្សខេត្ត ក្រុង ។ គណៈកម្មាធិការគណបក្សខេត្ត ក្រុង អាចប្រគល់ភារកិច្ចដកឹនាំនេះឱ្យគណៈកម្មាធិការគណបក្សស្រុក ខណ្ឌ អនុវត្តជំនួសបាន ស្របតាមសភាពការណ៍ជាក់ស្តែង ។

* កំរិតវិទ្យាល័យ មហាវិទ្យាល័យ សាកលវិទ្យាល័យ សាលាគរុកោសល្យ សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ និងមុខជំនាញ ត្រូវស្ថិតក្រោមការដឹកនាំផ្ទាល់របស់គណៈកម្មាធិការគណបក្សខេត្ត ក្រុង ដោយមានសហការជាមួយគណៈកម្មាធិការគណបក្សក្រសួងអប់រំ យុវជន និងកីឡា។

* ដោយឡែក ចំពោះគិរិតសាលាបឋមសិក្សា និងមត្តេយ្យសិក្សា គឺបង្កើតសាខាគណបក្សស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគណបក្ស ឃុំ សង្កាត់ (មិនបង្កើតជាគណៈកម្មាធិការគណបក្សមូលដ្ឋាន) ។

- គណៈកម្មាធិការគណបក្សមូលដ្ឋាន មន្ទីរពេទ្យធំៗនៅរាជធានីភ្នំពេញ ត្រូវស្ថិតក្រោមការដឹកនាំផ្ទាល់របស់គណបក្សក្រសួងសុខាភិបាល ដោយមានសហការជាមួយគណៈកម្មាធិការគណបក្សក្រុង ។
- គណៈកម្មាធិការគណបក្សមូលដ្ឋាន មន្ទីរពេទ្យរបស់ខេត្ត ក្រុង ត្រូវស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគណបក្សខេត្ត ក្រុង។ គណៈកម្មាធិ-ការគណបក្សខេត្ត ក្រុង អាចប្រគល់ភារកិច្ចដឹកនាំនេះឱ្យគណៈកម្មាធិការគណបក្សស្រុក ខណ្ឌ អនុវត្តជំនួសបាន ស្របតាមសភាពការណ៍ជាក់ស្តែង ។
- គណៈកម្មាធិការគណបក្សមូលដ្ឋាន នៅតាមរោងចក្រ សហគ្រាស ត្រូវស្ថិតក្រោមការដឹកនាំផ្ទាល់ របស់គណៈកម្មាធិការគណបក្សក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ដោយមានសហការជាមួយគណៈកម្មាធិការគណបក្សខេត្ត ក្រុង ។
- គណៈកម្មាធិការគណបក្សមូលដ្ឋាន អង្គភាពផលិតកម្ម អាជីវកម្ម សិប្បកម្ម និងអង្គការសង្គមនានា ត្រូវស្ថិតក្រោមការដឹកនាំរបស់គណៈកម្មាធិការគណ-បក្សខេត្ត ក្រុង។ គណៈកម្មាធិការគណបក្សខេត្ត ក្រុង អាចប្រគល់ភារកិច្ចដឹកនាំនេះ ឱ្យគណៈកម្មាធិការគណបក្សស្រុក ខណ្ឌ អនុវត្តជំនួសបាន ស្របតាមសភាពការណ៍ជាក់ស្តែង ។

**ប្រការ២៦** ÷ គណៈកម្មាធិការគណបក្សមូលដ្ឋាន មានតួនាទីៈ

- ក្តាប់ជាប់នូវកម្មវិធីនយោបាយរបស់គណបក្ស ដើម្បីចាត់តាំងអនុវត្តឱ្យស្របតាមសភាពការណ៍ជាក់ស្តែងនៅមូលដ្ឋាន
- ដឹកនាំការងារគណបក្ស អំពីការងារនយោបាយ សតិអារម្មណ៍ និងចាត់តាំង

ក្នុងក្របខ័ណ្ឌមូលដ្ឋានរបស់ខ្លួន

- ផ្សារភ្ជាប់ជិតស្និទ្ធជាមួយមហាជន ប្រជាជននៅមូលដ្ឋាន ខិតខំបំផុសមហាជនចូលរួមកសាង ពង្រឹងរដ្ឋអំណាច និងកែលំអជីវភាពរស់នៅ
- ការពារឥទ្ធិពល និងប្រជាប្រិយភាពរបស់គណបក្ស ខិតខំប្រមូលកំលាំងមហាជនច្រើនកុះករឱ្យគាំទ្រគណបក្សប្រជាជនកម្ពុជា ។

**ប្រការ២៧**÷ គណៈកម្មាធិការគណបក្សមូលដ្ឋាន ត្រូវអនុវត្តតាមភារកិច្ច និងសិទ្ធិដែលកំណត់ដោយគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល ។

**ប្រការ២៨**÷ គណៈកម្មាធិការគណបក្សមូលដ្ឋាន ប្រជុំជីវភាព ១ខែម្ដង ពេលចាំបាច់ត្រូវប្រជុំវិសាមញ្ញ។ ក្រៅពីការប្រជុំជីវភាពប្រចាំខែ គណៈកម្មាធិការគណបក្សមូលដ្ឋាន ត្រូវកំណត់ពេលវេលាមួយដង ឬពីរដង ដើម្បីរៀនសូត្រឱ្យជ្រួតជ្រាបអំពីសភាពការណ៍ និងភារកិច្ចរបស់គណបក្ស ព្រមទាំងសេចក្ដីសម្រេចចិត្តនានារបស់គណបក្សថ្នាក់លើ។ គណៈកម្មាធិការ គណបក្សមូលដ្ឋាន ដំណើរការមហាសន្និបាត ១ឆ្នាំម្ដង ដើម្បីត្រួតពិនិត្យការដឹកនាំរបស់គណបក្សក្នុងឆ្នាំកន្លងមក និងពិភាក្សាអនុម័តទិសដៅការងារសម្រាប់ឆ្នាំបន្ទាប់លើការងារនយោបាយ សតិអារម្មណ៍ ចាត់តាំងត្រួតពិនិត្យ ហិរញ្ញវត្ថុ ជីវភាព និងបោះឆ្នោតជ្រើសតាំងគណៈកម្មាធិការគណបក្សមូលដ្ឋានថ្មី។ គណៈកម្មា-ធិការ គណបក្សមូលដ្ឋាន ត្រូវចាត់តាំងសមាជិកឱ្យទទួលខុសត្រូវចុះជួយពង្រឹងគ្រប់សាខាគណបក្សចំណុះ ដើម្បីឱ្យសាខាគណបក្សទាំងនោះមានលទ្ធភាព និងសមត្ថភាពគ្រប់គ្រាន់ក្នុងការធ្វើសកម្មភាពនៅមូលដ្ឋាន ។

## ជំពូក១០÷ ការលើកសរសើរ និងដាក់វិន័យ

**ប្រការ២៩**÷ ការលើកសរសើរមានរូបភាពពីរគឺ÷ លិខិតសរសើរ និងប័ណ្ណសរសើរ។

- គណៈកម្មាធិការនៃគណបក្សគ្រប់ថ្នាក់ អាចចេញសេចក្ដីសម្រេចលើកសរសើរជូនរង្វាន់របស់ថ្នាក់ខ្លួនដល់សមាជិក ឬអង្គការចាត់តាំងដែល

ស្ថិតក្រោមឱវាទ។ គណៈកម្មាធិការនៃគណបក្សថ្នាក់លើ ពិនិត្យ និងសម្រេចលើកសរសើរជូនរង្វាន់ដល់ថ្នាក់ក្រោម ដោយយោងតាមសំណើរបស់គណៈកម្មាធិការនៃគណបក្សថ្នាក់ក្រោម។ សេចក្ដីសម្រេចនេះ ត្រូវបានកត់ត្រាទុកក្នុងសំណុំលិខិតផ្ទាល់របស់សាមីខ្លួន ឬសាមីអង្គការចាត់តាំងគណបក្ស។

- គំរូឯកភាពនៃលិខិតសរសើរ និងប័ណ្ណសរសើររបស់ថ្នាក់នីមួយៗ ត្រូវកំណត់ដោយថ្នាក់កណ្ដាល។

**ប្រការ៣០**÷ ការដាក់វិន័យមានរូបភាពដូចខាងក្រោម÷

- ចំពោះសមាជិក : ស្ដីបន្ទោស ដកតួនាទី និងបញ្ចេញពីសមាជិក។
- ចំពោះអង្គការចាត់តាំងគណបក្ស : ស្ដីបន្ទោស និងរំសាយ។
- រូបភាពស្ដីបន្ទោសគឺត្រូវអនុវត្តចំពោះសមាជិកឬអង្គការចាត់តាំងគណបក្សដែលបានប្រព្រឹត្តខុសឆ្គងក្នុងការអនុវត្តភារកិច្ច និងសិទ្ធិរបស់ខ្លួន ប៉ុន្តែមិនបណ្ដាលឱ្យប៉ះពាល់ ឬប៉ះពាល់តិចតួច ដែលមិនជះឥទ្ធិពលខ្លាំងដល់ផលប្រយោជន៍គណបក្ស។
- រូបភាពដកតួនាទី ត្រូវអនុវត្តចំពោះមន្ត្រី គណបក្សកំពុងកាន់មុខតំណែងមួយ ឬច្រើនក្នុងគណបក្ស(មុខតំណែងដែលអាស្រ័យដោយការបោះឆ្នោតឬចង្អុលតែងតាំង) ដែលបានប្រព្រឹត្តខុសឆ្គង ហើយបានទទួលការស្ដីបន្ទោសច្រើនដង តែមិនព្រមកែប្រែ ឬបានប្រព្រឹត្តខុសឆ្គងធ្ងន់បង្គួរ ដែលពិនិត្យឃើញថាមិនសក្តិសមនឹងកាន់មុខតំណែងនោះតទៅទៀត។

  ក្នុងករណីកាន់មុខតំណែងច្រើន ត្រូវពិនិត្យក្របខ័ណ្ឌ ឥទ្ធិពលនៃបទល្មើសខុសឆ្គងនោះដើម្បី សម្រេចដកមុខតំណែងមួយ ឬច្រើន ឬមុខតំណែងទាំងអស់ក្នុងពេលតែមួយ។
- រូបភាពបញ្ចេញពីសមាជិក ត្រូវអនុវត្តចំពោះសមាជិកគណបក្សណាដែល

បានប្រព្រឹត្តខុសឆ្គង ធ្ងន់ធ្ងរហើយពិនិត្យឃើញថា ពុំមានលក្ខណៈសម្បត្តិជាសមាជិកគណបក្សទៀតឡើយ។

ការសម្រេចបញ្ចេញសមាជិកគណបក្ស នាំមកនូវការបញ្ចប់អាណត្តិរបស់សមាជិកនោះនៅក្នុងរាជរដ្ឋាភិបាល និងរដ្ឋសភាដែលគេបានទទួលពីគណបក្ស។

- រូបភាពរំសាយត្រូវអនុវត្តចំពោះអង្គភាពចាត់តាំងគណបក្ស ដែលមានគុណវិបត្តិធ្ងន់ធ្ងរ ស្ថិតក្នុងករណីណាមួយក្នុងចំណោមករណីទាំងពីរខាងក្រោម÷
    - o មានសមាជិកគណបក្សចាប់ពី ២ ភាគ ៣ ឡើងទៅ (ចំពោះសាខាគណបក្ស) ឬ ២ ភាគ ៣ នៃចំនួនសមាជិកគណៈកម្មាធិការគណបក្សដែលប្រព្រឹត្តខុសឆ្គងដល់កម្រិតត្រូវដាក់វិន័យបញ្ចេញពីសមាជិក។
    - o សមូហភាពក្នុងអង្គការចាត់តាំងគណបក្សនោះ មានសកម្មភាពប្រឆាំងនឹងមាគ៌ានយោបាយរបស់គណៈបក្សដោយចេតនា ឬមានភ័ស្តុតាងបញ្ជាក់ថាលែងមានជំនឿទុកចិត្តខាងនយោបាយចំពោះគណបក្ស។
    - o សមាជិក ឬអង្គការចាត់តាំងគណបក្សដែលត្រូវទទួលការត្រួតពិនិត្យដាក់វិន័យ មានសិទ្ធិធ្វើការបញ្ជាក់បំភ្លឺការងារខ្លួនចំពោះមុខសមត្ថកិច្ចដាក់វិន័យ។ ក្នុងករណីមិនសុខចិត្តចំពោះរូបភាពវិន័យដែលត្រូវទទួលសមាជិក ឬអង្គការចាត់តាំងគណបក្សនោះមានសិទ្ធិតវ៉ាទៅគណបក្សថ្នាក់លើ។
    - o សេចក្តីសម្រេចដាក់វិន័យ ត្រូវកត់ត្រាទុកក្នុងសំណុំឯកសារផ្ទាល់របស់សមាជិកគណបក្ស និងសមាជិកគ្រប់រូបនៃអង្គភាពចាត់តាំងគណបក្សដែលត្រូវទទួលវិន័យ។

**ប្រការ៣៦**÷ គណកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ជាស្ថាប័នជំនួយការរបស់គណៈកម្មា-

ធិការនៃគណបក្សថ្នាក់នីមួយៗ មានតួនាទីត្រួតពិនិត្យការអនុវត្តន៍កម្មវិធីនយោបាយ គោលការណ៍ សេចក្ដីសម្រេចចិត្តនានារបស់គណបក្ស និងស្រាវជ្រាវត្រួតពិនិត្យចំពោះសមាជិក និងអង្គការចាត់តាំងគណបក្សដែលបានប្រព្រឹត្តល្មើសខុសឆ្គង។

- គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ត្រូវអនុវត្តតាមភារកិច្ច និងសិទ្ធិអំណាចដែលកំណត់ដោយគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល់។

## ជំពូក១១÷ ហិរញ្ញវត្ថុរបស់គណបក្ស

**ប្រការ៣២÷** ហិរញ្ញវត្ថុរបស់គណបក្ស រួមមានទ្រព្យសម្បត្តិ និងថវិការបស់គណបក្ស។ ហិរញ្ញវត្ថុរបស់គណបក្សបានមកពី÷

- ភាគទានប្រចាំខែរបស់សមាជិក
- ការឧបត្ថម្ភដោយស្ម័គ្រចិត្តរបស់សមាជិក
- ចំណូលផ្សេងៗស្របច្បាប់របស់គណបក្ស
- ការឧបត្ថម្ភដោយស្ម័គ្រចិត្តរបស់សប្បុរសជន
- ទ្រព្យសម្បត្តិផ្ទាល់របស់គណបក្ស

គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល ដឹកនាំណែនាំ និងកំណត់អំពីចំណូល ចំណាយ ការគ្រប់គ្រងហិរញ្ញវត្ថុ និងថវិការបស់គណបក្ស។

**ប្រការ៣៣÷** គណៈកម្មាធិការហិរញ្ញវត្ថុគ្រប់ថ្នាក់ ជាស្ថាប័នជំនួយការរបស់គណៈកម្មាធិការនៃគណបក្សថ្នាក់នីមួយៗ មានតួនាទីរៀបចំគោលការណ៍ ផែនការចំណូលចំណាយវិធានការ ថែរក្សា គ្រប់គ្រង ប្រើប្រាស់ ធ្វើអាជីវកម្មនូវទ្រព្យសម្បត្តិរបស់គណបក្សស្របតាមច្បាប់។

- គណៈកម្មាធិការហិរញ្ញវត្ថុគ្រប់ថ្នាក់ ត្រូវអនុវត្តតាមភារកិច្ច និងសិទ្ធិអំណាចដែលកំណត់ដោយគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្ដាល។

- ប្រធានគណៈកម្មាធិការកណ្តាល ធ្វើរបាយការណ៍ទៀងទាត់អំពីការងារហិរញ្ញវត្ថុរបស់គណបក្ស ជូនអាជ្ញាធរមានសមត្ថកិច្ចតាមការកំណត់នៃច្បាប់។

**ប្រការ៣៤÷** ប្រធាន អនុប្រធានគណបក្ស និងប្រធានគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍ ជាអ្នកបញ្ជាក្នុងការចំណាយ។

ប្រធាន អនុប្រធានគណបក្ស និងប្រធានគណៈប្រចាំនៃគណៈអចិន្ត្រៃយ៍អាចប្រគល់សិទ្ធិនេះឱ្យប្រធានគណៈកម្មាធិការហិរញ្ញវត្ថុ នៃគណៈកម្មាធិការកណ្តាលអនុវត្តជំនួស។

## ជំពូក១២÷ អវសានបញ្ញត្តិ

**ប្រការ៣៥÷** បទបញ្ជាផ្ទៃក្នុងរបស់គណបក្ស ត្រូវបានអនុម័តដោយសន្និបាតគណៈកម្មាធិការកណ្តាលដោយមានការឯកភាពយ៉ាងតិចបំផុត ២ ភាគ ៣ នៃចំនួនសមាជិកគណៈកម្មាធិការកណ្តាល។

**ប្រការ៣៦÷** បទបញ្ជាផ្ទៃក្នុងរបស់គណបក្ស គឺសម្រាប់អនុវត្តលក្ខន្តិកៈគណបក្ស។ នៅពេលដែលលក្ខន្តិកៈគណបក្សត្រូវបានកែសម្រួលបទបញ្ជាផ្ទៃក្នុង ក៏ត្រូវពិនិត្យកែសម្រួលឡើងវិញឱ្យស្របតាមខ្លឹមសារនៃលក្ខន្តិកៈ។ ការកែប្រែបទបញ្ជាផ្ទៃក្នុងរបស់គណបក្សនឹងអាចធ្វើទៅបាន លុះត្រាតែមានការស្នើសុំពីសមាជិកអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលចំនួន ២ ភាគ ៣ យ៉ាងតិច ហើយត្រូវបានសន្និបាតគណៈកម្មាធិការកណ្តាលអនុម័តដោយសម្លេង ២ ភាគ ៣។

**ប្រការ៣៧÷** បទបញ្ជាផ្ទៃក្នុងនេះ ចូលជាធរមានចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខា។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែតុលា ឆ្នាំ ១៩៩៧

ជ-គណៈកម្មាធិការកណ្តាល

ប្រធាន

ជាស៊ីម

បទបញ្ជាផ្ទៃក្នុងនេះត្រូវបានអនុម័តដោយ
សន្និបាតគណៈកម្មាធិការកណ្តាលលើកទី២៣
នៅរាជធានីភ្នំពេញ នាថ្ងៃទី ២៧ ខែតុលា ឆ្នាំ ១៩៩៧

# ២. លក្ខន្តិកៈរបស់គណបក្សប្រជាជនកម្ពុជា

## ជំពូកទី ១ ឈ្មោះ សញ្ញា និងគោលបំណងរបស់គណបក្ស

**មាត្រាទី ១÷**

បក្សប្រជាជនបដិវត្តកម្ពុជាត្រូវបានប្តូរឈ្មោះមកជា គណបក្សប្រជាជនកម្ពុជា សរសេរអក្សរកាត់ "ប្រ.ជ" ។

បទភ្លេង និងចំរៀងរបស់គណបក្សមានឈ្មោះថា: "គណបក្សប្រជាជនកម្ពុជា"។

**មាត្រាទី ២÷**

សញ្ញាគណបក្សមានរាងមូលពងក្រពើ ផ្ទៃពណ៌ស មានកំរងគួរស្រូវពណ៌មាសអមសងខាងរង្វង់ស្មែងក្របីជួបគ្នាខាងចុង ។

ខ្សែបូរ រុំព័ទ្ធផ្នែកខាងក្រោមនៃកំរងគួរស្រូវជាប្រាំថ្នាក់ នៅកណ្តាលខ្សែបូរដែលកាត់ទទឹងផ្នែកខាងក្រោមមានចារឹកអក្សរពណ៌សថា គណបក្សប្រជាជនកម្ពុជា ។

មានក្បាច់ភ្ញីពណ៌មាសជាទម្រនៅចន្លោះក្បាច់ភ្ញី និងខ្សែបូរមានស្លឹគ្រឿងចក្រពណ៌មាស ។

នៅលើផ្ទៃ ស មានរូបទេវតាបាចផ្កាស្ថិតនៅចំកណ្តាលរង្វង់ ។

**មាត្រាទី ៣÷**

គោលបំណងរបស់ គណបក្ស គឺប្រមូលកម្លាំងគ្រប់ជនជាតិកម្ពុជាដែលមានឧត្តមគតិស្នេហាជាតិ មាតុភូមិ ស្រឡាញ់លទ្ធិប្រជាធិបតេយ្យ និងសន្តិភាព ដោយមិនប្រកាន់ឋានៈជីវភាព ជនជាតិ ជំនឿសាសនា អតីតកាល ដើម្បីរួមកម្លាំងគ្នាការពារសមិទ្ធផលសង្គមជាតិ និងកសាងប្រទេសកម្ពុជាមួយ ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ អព្យាក្រឹត និងវឌ្ឍនភាពសង្គម ។

## ជំពូកទី ២ គោលការណ៍កសាងគណបក្ស

**មាត្រាទី ៤÷**

១. គណបក្សប្រកាន់យកលទ្ធិប្រជាធិបតេយ្យ លើកកំពស់មនសិការស្នេហាជាតិ និង

បើកទូលាយទំនាក់ទំនងអន្តរជាតិ ជាមួយបណ្តាប្រទេសទាំងអស់លើសកលលោក ធ្វើជាមូលដ្ឋាននៃកម្មវិធីនយោបាយ និងសកម្មភាពរបស់ខ្លួនដោយផ្អែកលើគោលការណ៍ជាក់ស្តែងក្នុងប្រទេស និងនិន្នាការរួមនៃសកលលោក។

២. គណបក្សមានវិន័យត្រឹមត្រូវ និងមានប្រជាធិបតេយ្យទូលំទូលាយ ចាប់ពីថ្នាក់លើរហូតដល់ថ្នាក់ក្រោមអនុវត្តរបបសមូហភាពដឹកនាំ ម្នាក់ៗទទួលខុសត្រូវ ។ គណបក្សមិនអនុញ្ញាតឲ្យមានសកម្មភាពបំបែកបំបាក់សាមគ្គីភាព ឯកភាពផ្ទៃក្នុងគណបក្ស ។ គណបក្សអនុវត្តវិធីជួយមតិគ្នាទៅវិញទៅមកដើម្បីការរីកចម្រើន។

៣. គណបក្សកសាងឡើង និងរីកចម្រើនក្នុងចលនារបស់ប្រជាជន។ គណបក្សតំណាងឲ្យផលប្រយោជន៍របស់ប្រជាជនកម្ពុជា។ គណបក្សនិងសមាជិកម្នាក់ៗយកចិត្តទុកដាក់កសាងទំនាក់ទំនងល្អជាមួយប្រជាជន ហើយលើកកំពស់សមត្ថភាព និងគុណធម៌ដើម្បីសម្រេចភារកិច្ចជូនជាតិមាតុភូមិ ។

៤. គណបក្សដឹកនាំខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង ។ គណបក្សទទួលស្គាល់តួនាទីរបស់អង្គការសង្គម។ គណបក្សជួយឧបត្ថម្ភ និងសហការជាមួយអង្គការសង្គមដើម្បីបំផុសចលនាប្រជាជន ការពារសមិទ្ធផលសង្គមជាតិ និងកសាងប្រទេសជាតិ ។

៥. គណបក្សបញ្ចូលសមាជិករបស់ខ្លួន នូវប្រភេទជន ដែលល្អប្រពៃក្នុងចលនាប្រជាជន ហើយបញ្ចេញផុតពីគណបក្សនូវសមាជិកណាដែលមិនគ្រប់លក្ខណៈសម្បត្តិ ។

## ជំពូកទី ៣ សមាជិក

### មាត្រាទី ៥÷

លក្ខណៈសម្បត្តិចូលជាសមាជិក

១. ពលរដ្ឋកម្ពុជាទាំងពីរភេទដែលមានអាយុ ១៨ ឆ្នាំ ឡើងទៅ អាចចូលជាសមាជិកគណបក្សបាន។

២. មានឧត្តមគតិស្នេហាជាតិមាតុភូមិ និងលទ្ធិប្រជាធិបតេយ្យ គាំទ្រកម្មវិធីនយោបាយ និងលក្ខន្តិកៈរបស់គណបក្ស។

៣. មានគុណធម៌ និងទំនាក់ទំនងល្អជាមួយប្រជាជន ហើយត្រូវបានប្រជាជនស្រឡាញ់រាប់អានជឿទុកចិត្ត។

៤. មិនមែនជាសមាជិកគណបក្សនយោបាយដទៃ។

**មាត្រាទី ៦÷**

របៀបចូលគណបក្ស

១. សាមីខ្លួនធ្វើពាក្យសុំចូល ដោយភ្ជាប់ជាមួយជីវប្រវត្តិ ជូនគណៈកម្មាធិការសាខាគណបក្សពិនិត្យ។

២. មានសមាជិក ២ នាក់ជាអ្នកឧទ្ទេសនាម។

៣. គណៈកម្មាធិការគណបក្សមូលដ្ឋាន ពិនិត្យសម្រេចបញ្ចូលសមាជិកដោយមានការយល់ព្រមតិចបំផុត ២ ភាគ ៣ នៃសមាជិកក្នុងគណៈកម្មាធិការគណបក្ស ហើយរាយការណ៍ជូនថ្នាក់លើ។

៤. ការបញ្ចូលសមាជិកគណបក្ស ក្នុងករណីពិសេស ឬការទទួលស្គាល់បេក្ខភាពជាសមត្ថកិច្ចរបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល។

**មាត្រាទី ៧÷**

១. ខិតខំប្រតិបត្តិឲ្យបានត្រឹមត្រូវតាមកម្មវិធីនយោបាយ និងលក្ខន្តិកៈរបស់គណបក្ស។

២. កសាងទំនាក់ទំនងល្អជាមួយប្រជាជន និងខិតខំឃោសនាផ្សព្វផ្សាយ អំពីកម្មវិធីនយោបាយរបស់គណបក្ស ច្បាប់របស់រដ្ឋដល់ប្រជាជន។

៣. ត្រូវថែរក្សាឆ្លងសាមគ្គីឯកភាពផ្ទៃក្នុង រក្សាការសម្ងាត់របស់គណបក្ស ជានិច្ចកាលជួយមតិគ្នាទៅវិញទៅមកដើម្បីការរីកចម្រើន។

៤. ខិតខំរៀនសូត្រលើកកំពស់សមត្ថភាព និងគុណធម៌ដើម្បីសម្រេចភារកិច្ចជូនជាតិមាតុភូមិ ។

**មាត្រាទី ៨÷**

សិទ្ធិរបស់សមាជិក

១. ពិភាក្សា និងអនុម័តរាល់កិច្ចការរបស់គណបក្ស ។

២. ឧទ្ទេសនាមបេក្ខជនឈរឈ្មោះជាបេក្ខជន និងបោះឆ្នោតជ្រើសតាំងអង្គការដឹកនាំរបស់គណបក្សគ្រប់ថ្នាក់ ។

៣. ជួយយោបល់ និងលើកមតិតវ៉ារបស់ខ្លួនទៅគណៈកម្មាធិការនៃគណបក្សគ្រប់ថ្នាក់ ។

**មាត្រាទី ៩÷**

សមាជិកណាមិន បានចូលរួមប្រជុំជីវភាព ឬក៏មិនបង់ភាគទានជូនគណបក្សចំនួន ៣ដងជាបន្តបន្ទាប់ដោយគ្មានមូលហេតុត្រឹមត្រូវ គណៈកម្មាធិការសាខាគណបក្សសម្រេចលប់ឈ្មោះចេញពីសមាជិក ហើយរាយការណ៍ឡើងថ្នាក់លើពិនិត្យសម្រេច។ ការផ្លាស់ប្តូរពីកន្លែងមួយ ទៅកន្លែងមួយទៀតរបស់សមាជិក ត្រូវតែមានការផ្ទេរជីវភាពគណបក្ស។

**ជំពូកទី ៤ គោលការណ៍ចាត់តាំង និងខ្សែរយៈចាត់តាំងរបស់គណបក្ស**

**មាត្រាទី ១០÷**

ខ្លឹមសារជាមូលដ្ឋាននៃគោលការណ៍ចាត់តាំងរបស់គណបក្សគឺៈ

១. អង្គការដឹកនាំរបស់គណៈកម្មាធិការនៃគណបក្សគ្រប់ថ្នាក់គឺ ត្រូវបានមហាសន្និបាតបោះឆ្នោតជ្រើសតាំងឡើង ហើយបានថ្នាក់លើមួយថ្នាក់យល់ព្រមទទួលស្គាល់ ។ ក្នុងករណីដែលពុំអាចបើកមហាសន្និបាតបាន ទើបថ្នាក់លើចង្អុលតែងតាំងគណៈកម្មាធិការនៃគណ-បក្សបណ្តោះអាសន្ន។

២. សមូហភាពដឹកនាំ ម្នាក់ៗទទួលខុសត្រូវ។

៣. នៅពេលពិភាក្សារាល់ការងារ ត្រូវគោរពមតិប្រជាធិបតេយ្យពិតប្រាកដ ក្រោយពេលអនុមតិ ភាគតិចត្រូវគោរពភាគច្រើន។

៤. សមាជិកម្នាក់ៗត្រូវគោរពអង្គការចាត់តាំង ថ្នាក់ក្រោមត្រូវគោរពថ្នាក់លើ។ គណ-បក្សទាំងមូលត្រូវគោរពមហាសន្និបាតតំណាងទូទាំងប្រទេសរបស់គណបក្ស និងគណៈ-កម្មាធិការកណ្តាលនៃគណបក្ស។

៥. អង្គការចាត់តាំងរបស់គណបក្សគ្រប់ថ្នាក់ត្រូវខិតខំចាត់តាំងអនុវត្ត ដោយច្នៃប្រឌិតនូវកម្មវិធីនយោបាយរបស់គណបក្សស្របតាមសភាពការណ៍ជាក់ស្តែង នៃមូលដ្ឋានរបស់ខ្លួន ។ ពេលមានការងារសំខាន់ៗត្រូវសុំយោបល់ពីថ្នាក់លើ។

**មាត្រាទី ១១÷**

អង្គការចាត់តាំងរបស់គណបក្សត្រូវបានចាត់តាំងឡើងនៅតាមស្ថាប័ននានា។ ខ្សែរយៈចាត់តាំងរបស់គណបក្សរួមមាន ៤ ថ្នាក់ គឺ៖

1. ថ្នាក់កណ្តាល
2. ថ្នាក់ខេត្ត ក្រុង ក្រសួង- ស្ថាប័ន
3. ថ្នាក់ស្រុក ខណ្ឌ
4. ថ្នាក់មូលដ្ឋាន

**មាត្រាទី ១២÷**

មហាសន្និបាតរបស់គណបក្សគ្រប់ថ្នាក់ មានរូបភាពពីរយ៉ាងគឺ៖ មហាសន្និបាតតំណាង និងមហាសន្និបាតសមាជិកទាំងមូល។

មហាសន្និបាត គឺជាអង្គការដឹកនាំខ្ពស់បំផុតរបស់គណបក្សថ្នាក់និមួយៗ មានភារកិច្ចពិនិត្យពិភាក្សា និងអនុម័តលើរបាយការណ៍នយោបាយរបស់គណៈកម្មាធិការនៃគណបក្សពិភាក្សា និងកំណត់រាល់គោលការណ៍ការងារសំខាន់ៗរបស់គណបក្សថ្នាក់ខ្លួន បោះឆ្នោតជ្រើសតាំងគណៈកម្មាធិការនៃគណបក្សថ្មី ពិភាក្សារាល់គោលការណ៍ ការងារសំខាន់ៗដែលគណៈកម្មាធិការកណ្តាល ឬថ្នាក់លើដាក់ចេញ និងបោះឆ្នោតជ្រើសរើសតំណាងទៅចូលរួមមហាសន្និបាតថ្នាក់លើ (បើមាន)។

មហាសន្និបាតរបស់គណបក្សថ្នាក់ណា អាស្រ័យដោយគណៈកម្មាធិការនៃគណបក្សថ្នាក់នោះកោះប្រជុំតាមការណែនាំរបស់ថ្នាក់លើ។

មហាសន្និបាត ចាត់ទុកជាផ្លូវការបានលុះត្រាតែមានចំនួនតំណាងពេញសិទ្ធិមកពីគណៈកម្មាធិការនៃគណបក្សថ្នាក់ក្រោមចូលរួមលើសពីពាក់កណ្តាល។

ការជ្រើសរើសគណៈកម្មាធិការនៃគណបក្សគ្រប់ថ្នាក់ ត្រូវដំណើរការបោះឆ្នោតដោយផ្ទាល់ និងដោយសំងាត់។

**មាត្រាទី ១៣÷**

ចំនួនសមាជិករបស់គណៈកម្មាធិការនៃគណបក្សគ្រប់ថ្នាក់ អាស្រ័យដោយមហាសន្និបាតសម្រេចកំណត់តាមការណែនាំរបស់ថ្នាក់លើ ។

អនុលោម តាមសំណូមពរចាំបាច់ គណៈកម្មាធិការនៃគណបក្សគ្រប់ថ្នាក់មានសិទ្ធិចាត់តាំងផ្នែកជំនួយការ ដោយកំណត់ភារកិច្ច សិទ្ធិអំណាច និងរបៀបរបបធ្វើការងារនៃអង្គការចាត់តាំងនោះតាមការណែនាំរួមរបស់ ថ្នាក់លើ ។

## ជំពូកទី ៥ អង្គការមូលដ្ឋានរបស់គណបក្ស

**មាត្រាទី ១៤÷**

សាខា គឺជាអង្គការមូលដ្ឋានរបស់គណបក្ស។ អង្គភាពមូលដ្ឋាន ដូចជាអង្គភាពមូលដ្ឋានរដ្ឋបាល អង្គភាពមូលដ្ឋានសេដ្ឋកិច្ចសង្គម និងអង្គការសង្គម បើមានសមាជិកពី ៣នាក់ ឡើងទៅ ត្រូវបង្កើតជាសាខា ។ សាខាអាចបែងចែកជាច្រើនអនុសាខា ។ សាខាដែលមានសមាជិកពី ៣នាក់ ទៅ ៧នាក់ ត្រូវជ្រើសតាំងប្រធាន ហើយអាចជ្រើសតាំងបន្ថែមអនុប្រធានសាខា ។ បើមានសមាជិកពី ៩នាក់ ឡើងទៅ ត្រូវជ្រើសតាំងគណៈកម្មាធិការសាខា ។

មូលដ្ឋានឃុំ សង្កាត់ និងថ្នាក់ប្រហាក់ប្រហែលដែលមានសមាជិកច្រើន ត្រូវបង្កើតជាគណៈកម្មាធិការគណបក្សមូលដ្ឋាន ។

គណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្តាល និងធ្វើការណែនាំជាក់ស្តែងអំពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការគណបក្សមូលដ្ឋាន ។

**មាត្រាទី ១៥÷**

ភារកិច្ចរបស់សាខា

១. ក្តាប់ជាប់នូវកម្មវិធីនយោបាយរបស់គណបក្ស និងច្បាប់របស់រដ្ឋ ដើម្បីចាត់តាំង

អនុវត្តឲ្យបានសមស្របតាមសភាពការណ៍ជាក់ស្តែងនៃ មូលដ្ឋានរបស់ខ្លួន ។

២. សហការជាមួយអង្គការសង្គម ដើម្បីឃោសនាបំផុសចលនាប្រជាជនចូលរួមកសាងពង្រឹងរដ្ឋអំណាច យកចិត្តទុកដាក់ដោះស្រាយជីវភាពរស់នៅ ទាំងស្មារតី និងសំភារៈដល់ប្រជាជន ។

៣. បែងចែក និងត្រួតពិនិត្យការងាររបស់សមាជិកម្នាក់ៗ អប់រំសមាជិក បញ្ចូលសមាជិកថ្មី លើកសរសើរ ដាក់វិន័យសមាជិក កសាងជួរមន្ត្រី និងថែរក្សាសាមគ្គីភាព ។

៤. ធ្វើរបាយការណ៍អំពីសភាពការណ៍ និងសុំយោបល់សម្រេចពីថ្នាក់លើនូវបញ្ហាសំខាន់ៗ ។

ភារកិច្ចជាក់ស្តែងនៃប្រភេទសាខានិមួយៗ នឹងមានការកំណត់ដោយឡែក ។

**មាត្រាទី ១៦÷**

សាខា គណៈកម្មាធិការសាខា គណៈកម្មាធិការគណបក្សមូលដ្ឋាន ប្រជុំមួយខែមួយដង ។ បើមានការចាំបាច់នឹងប្រជុំវិសាមញ្ញ ។ អនុសាខាប្រជុំមួយខែមួយដង ។

មហាសន្និបាត សាខា មហាសន្និបាតគណបក្សមូលដ្ឋាន មួយឆ្នាំប្រជុំមួយដង ។ មហាសន្និបាតមានភារកិច្ចពិនិត្យពិភាក្សា និងអនុម័តលើរបាយការណ៍នយោបាយរបស់សាខាគណបក្សមូលដ្ឋាន ពិភាក្សា និងកំណត់រាល់គោលការណ៍ការងារសំខាន់ៗរបស់ថ្នាក់ខ្លួន និងបោះឆ្នោតជ្រើសតាំងប្រធាន អនុប្រធានសាខា គណៈកម្មាធិការសាខា និងគណៈកម្មាធិការគណបក្សមូលដ្ឋានថ្មី ។

## **ជំពូកទី ៦ គណបក្សថ្នាក់ស្រុក ខណ្ឌ និងថ្នាក់ខេត្ត ក្រុង ក្រសួង ស្ថាប័ន**

**មាត្រាទី ១៧÷**

មហាសន្និបាតតំណាងស្រុក ខណ្ឌ ៥ឆ្នាំ ប្រជុំពីរដង ។ មហាសន្និបាតតំណាងខេត្ត ក្រុង ក្រសួង ស្ថាប័ន ៥ឆ្នាំ ប្រជុំមួយដង ។

ក្នុងករណីចាំបាច់ជាបន្ទាន់ បានទទួលការអនុញ្ញាតពីគណៈកម្មាធិការកណ្តាលនៃគណបក្ស ទើបអាចបើកមហាសន្និបាតវិសាមញ្ញ ។

មហាសន្និបាត ថ្នាក់ណា បោះឆ្នោតជ្រើសតាំងគណៈកម្មាធិការគណបក្សថ្នាក់នោះ ។ សន្និបាតពេញអង្គគណៈកម្មាធិការនៃគណបក្ស បោះឆ្នោតជ្រើសតាំងគណៈអចិន្ត្រៃយ៍ ប្រធាន អនុប្រធានគណៈកម្មាធិការនៃគណបក្ស គណៈកម្មាធិការត្រួតពិនិត្យ ប្រធានគណៈ-កម្មាធិការត្រួតពិនិត្យ គណៈកម្មាធិការហិរញ្ញវត្ថុ និងប្រធានគណៈកម្មាធិការហិរញ្ញវត្ថុ ហើយត្រូវបានថ្នាក់លើយល់ព្រមទទួលស្គាល់ ។

**មាត្រាទី ១៨÷**

គណៈកម្មាធិការ នៃគណបក្សថ្នាក់ស្រុក ខណ្ឌ ថ្នាក់ខេត្ត ក្រុង ក្រសួង ស្ថាប័ន ត្រូវអនុវត្តតាមសេចក្ដីសម្រេចចិត្តរបស់មហាសន្និបាតថ្នាក់ខ្លួន សេចក្ដីសម្រេចចិត្ត សារាចររបស់ថ្នាក់លើ និងដឹកនាំការងារគ្រប់ផ្នែករបស់គណៈកម្មាធិការនៃគណបក្សថ្នាក់ខ្លួន ក្នុងចន្លោះពេលពីមហាសន្និបាតមួយ ទៅមហាសន្និបាតមួយទៀត ។

ក្នុងករណី ពុំទាន់មានលទ្ធភាពបើកមហាសន្និបាតថ្នាក់ ស្រុក ខណ្ឌ ខេត្ត ក្រុង ក្រសួង ស្ថាប័ន បាននោះ គណៈកម្មាធិការនៃគណបក្សថ្នាក់លើចង្អុលតែងតាំងគណៈ-កម្មាធិការនៃគណបក្ស បណ្ដោះអាសន្ន ។

គណៈកម្មាធិការនៃគណបក្សថ្នាក់ស្រុក ខណ្ឌ ខេត្ត ក្រុង ក្រសួង ស្ថាប័ន ប្រជុំមួយខែមួយដង ។

គណៈកម្មាធិការ នៃគណបក្សដែលមានសមាជិក ៩នាក់ ឡើងទៅ ត្រូវជ្រើសតាំងគណៈអចិន្ត្រៃយ៍ ដើម្បីដឹកនាំការងារគ្រប់ផ្នែក ក្នុងចន្លោះពីសន្និបាតពេញអង្គមួយ ទៅសន្និបាតពេញអង្គមួយទៀត ។ គណៈកម្មាធិការនៃគណបក្សថ្នាក់លើត្រូវផ្សព្វផ្សាយសភាពការណ៍ និងការងារសំងាត់ៗឲ្យថ្នាក់ក្រោមបានដឹង ។

## ជំពូកទី ៧ មហាសន្និបាតតំណាងទូទាំងប្រទេសរបស់គណបក្ស និងគណៈកម្មាធិការកណ្ដាលនៃគណបក្ស

**មាត្រាទី ១៩÷**

មហាសន្និបាត តំណាងទូទាំងប្រទេសរបស់គណបក្ស គឺជាអង្គការដឹកនាំខ្ពស់បំផុត

របស់គណបក្ស ហើយប្រជុំជាសាមញ្ញ ៥ឆ្នាំ មួយដង ដោយគណៈកម្មាធិការកណ្តាលកោះអញ្ជើញ ។ ក្នុងករណីពិសេស មហាសន្និបាតនេះអាចប្រជុំមុនឬក្រោយពេលកំណត់ ។ ភារកិច្ចនៃមហាសន្និបាតតំណាងទូទាំងប្រទេសរបស់គណបក្ស គឺពិនិត្យពិភាក្សា និង អនុម័តលើរបាយការណ៍នយោបាយ របស់គណៈកម្មាធិការកណ្តាល អំពីសភាពការណ៍រួមរបស់គណបក្ស ហើយសម្រេចកំណត់ពីគោលនយោបាយក្នុងប្រទេស ក្រៅប្រទេស និងភារកិច្ចរបស់គណបក្សតាមតំណាក់កាលនិមួយៗ បំពេញបន្ថែមឬកែសំរួលលក្ខន្តិកៈ គណបក្សបោះឆ្នោតជ្រើសតាំង គណៈកម្មាធិការកណ្តាលនៃគណបក្ស ។

**មាត្រាទី ២០÷**

ពេលដែលត្រូវ សម្រេចនូវបញ្ហាសំខាន់ៗ តែមិនអាចបើកមហាសន្និបាតសាមញ្ញបាន គណៈកម្មាធិការកណ្តាល នៃគណបក្សចាំបាច់បើកមហាសន្និបាតវិសាមញ្ញ ដែលមានសមាសភាពចូលរួមៈ

គណៈកម្មាធិការកណ្តាលនៃគណបក្ស មន្ត្រីដឹកនាំសំខាន់ៗគ្រប់ខេត្ត ក្រុង និង ក្រសួង ស្ថាប័ន ។

**មាត្រាទី ២១÷**

ភារកិច្ចរបស់គណៈកម្មាធិការកណ្តាលនៃគណបក្ស

១. ដឹកនាំរាល់ការងាររបស់គណបក្ស ក្នុងចន្លោះពេលពីមហាសន្និបាតតំណាងមួយទៅមហាសន្និបាតតំណាងមួយទៀត សំដៅអនុវត្តសេចក្តីសម្រេចចិត្តរបស់មហាសន្និបាត។

២. សម្រេចរាល់បញ្ហាសំខាន់ៗ អំពីគោលនយោបាយក្នុងប្រទេស និងក្រៅប្រទេស របស់គណបក្ស អំពីការងារកសាងគណបក្ស ការងារចាត់តាំងការងារមន្ត្រី ការងារគ្រប់គ្រង ហិរញ្ញវត្ថុ និងថវិការបស់គណបក្ស ។

៣. តាងនាមឲ្យគណបក្សក្នុងការទាក់ទងជាមួយបណ្តាបក្សនៅលើសកលលោក ។

៤. ត្រៀមលក្ខណៈរៀបចំបើកមហាសន្និបាតតំណាងទូទាំងប្រទេសរបស់គណបក្ស។ ៦ខែម្តង ត្រូវផ្សព្វផ្សាយសភាពការណ៍រួមឲ្យថ្នាក់ក្រោមបានដឹង និងលើកបញ្ហាសំខាន់ៗ

ឲ្យថ្នាក់ក្រោមបានចូលរួមមតិ ។

**មាត្រាទី ២២÷**

សន្និបាតពេញអង្គរបស់គណៈកម្មាធិការកណ្តាល បោះឆ្នោតជ្រើសតាំងគណៈអចិន្ត្រៃយ៍ គណៈកម្មាធិការកណ្តាល គណៈកម្មាធិការត្រួតពិនិត្យ គណៈកម្មាធិការហិរញ្ញវត្ថុ នៃគណៈ-កម្មាធិការកណ្តាល ប្រធាន អនុប្រធានគណៈកម្មាធិការកណ្តាល ប្រធានគណៈកម្មាធិការត្រួតពិនិត្យ និងប្រធានគណៈកម្មាធិការហិរញ្ញវត្ថុនៃគណៈកម្មាធិការ កណ្តាល ។ គណៈ-កម្មាធិការកណ្តាលអាចតែងតាំងប្រធានកិត្តិយស ឬទីប្រឹក្សានៃគណៈកម្មាធិការកណ្តាល ។

គណៈអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកណ្តាល ដឹកនាំរាល់ការងាររបស់គណបក្សក្នុងចន្លោះពេលពីសន្និបាតពេញអង្គមួយ ទៅសន្និបាតពេញអង្គមួយទៀតនៃគណៈកម្មាធិការកណ្តាល ។ គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល ត្រូវចាត់តាំងគណៈប្រចាំការដើម្បីដោះស្រាយការងារប្រចាំថ្ងៃ ។

តួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់ប្រធានកិត្តិយស និងទីប្រឹក្សានៃគណៈ-កម្មាធិការកណ្តាល នឹងមានការកំណត់ដោយឡែក ។

គណៈកម្មាធិការកណ្តាលប្រជុំជាសាមញ្ញ ៦ខែម្តង ។

## ជំពូកទី ៨ តួនាទីរបស់គណបក្សចំពោះរដ្ឋ និងអង្គការសង្គម

**មាត្រាទី ២៣÷**

គណបក្សដឹកនាំខាងនយោបាយ ដោយខិតខំចាត់តាំងអនុវត្តកម្មវិធីនយោបាយរបស់គណបក្ស ដើម្បីគ្រប់គ្រងប្រទេសជាតិ ។

០ គណបក្សទទួលស្គាល់តួនាទីរបស់អង្គការសង្គម ដូចជា៖ រណសិរ្ស សមាគមយុវជន សមាគមនារី សមាគមកសិករ សហជីព ។ល។ គណបក្សជួយឧបត្ថម្ភ និងសហការជាមួយអង្គការសង្គមដើម្បីបំផុសចលនាប្រជាជនការពារសមិទ្ធផល សង្គមជាតិ និងកសាងប្រទេសជាតិ ។ គណបក្ស និងអង្គការសង្គមផ្តល់ព័ត៌មានឲ្យគ្នាទៅវិញទៅមកអំពីមតិ និងបំណងប្រាថ្នារបស់ប្រជាជន ដើម្បីមានវិធានការដោះស្រាយ

ទាន់ពេលវេលា ។

## ជំពូកទី ៩ ការលើកសរសើរ និងពិន័យ

### មាត្រាទី ២៤÷

**ការសរសើរ**

សមាជិក និងអង្គការចាត់តាំងគណបក្សដែលបំពេញភារកិច្ចជូនជាតិមាតុភូមិបាន ល្អប្រសើរ លេចធ្លោរជាងគេនោះ ត្រូវបានគណៈកម្មាធិការនៃគណបក្សគ្រប់ថ្នាក់សរសើរ ជូនរង្វាន់តាម គ្រប់រូបភាព ។

### មាត្រាទី ២៥÷

**រូបភាពវិន័យ**

សមាជិក និងអង្គការចាត់តាំងគណបក្សដែលប្រព្រឹត្តល្មើសខុសឆ្គង ត្រូវទទួលពិន័យ ធ្ងន់ ឬស្រាលតាមរូបភាពដូចខាងក្រោមៈ

1. ចំពោះសមាជិកៈ ស្តីបន្ទោស ដកតួនាទី និងបណ្តេញពីសមាជិក ។
2. ចំពោះអង្គការចាត់តាំងគណបក្សៈ ស្តីបន្ទោស និងរំសាយ ។

### មាត្រាទី ២៦÷

**សមត្ថកិច្ចដាក់វិន័យ**

១. ចំពោះសមាជិកៈ

1. សាខាមានសិទ្ធិសម្រេចដាក់វិន័យស្តីបន្ទោស ចំពោះសមាជិកធម្មតាណាដែល ប្រព្រឹត្តល្មើសខុសឆ្គងក្នុងក្របខ័ណ្ឌសាខា ។
2. គណៈកម្មាធិការនៃគណបក្សថ្នាក់លើផ្ទាល់របសសាខា មានសិទ្ធិសម្រេចដាក់ វិន័យស្តីបន្ទោស ឬដកតួនាទីចំពោះប្រធាន អនុប្រធាន និងសមាជិកគណៈ-កម្មាធិការសាខា ។
3. គណៈកម្មាធិការនៃគណបក្សថ្នាក់ណា ដែលមានសិទ្ធិចេញសេចក្តីសម្រេច តែងតាំង ឬយល់ព្រមទទួលស្គាល់ គឺគណៈកម្មាធិការថ្នាក់នោះ មានសិទ្ធិសម្រេច

ដាក់ពិន័យស្តីបន្ទោស ឬដកតួនាទីពីសមាជិកគណៈកម្មាធិការនៃគណបក្ស ។

4. ការដាក់ពិន័យ ដោយរូបភាពបញ្ចេញពីសមាជិកគណៈកម្មាធិការកណ្តាល អាស្រ័យដោយសន្និបាតពេញអង្គនៃគណៈកម្មាធិការកណ្តាល តាមសំណើររបស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ហើយរាយការណ៍ជូនមហាសន្និបាតតំណាងទូទាំងប្រទេសរបស់គណបក្ស ។
5. គណៈកម្មាធិការនៃគណបក្សថ្នាក់លើណា ដែលមានសិទ្ធិសម្រេចបញ្ចូលជាសមាជិក គឺគណៈកម្មាធិការនៃគណបក្សថ្នាក់នោះ មានសិទ្ធិសម្រេចដាក់វិន័យបញ្ចេញពីសមាជិកចំពោះតែសមាជិកធម្មតា ។ ចំពោះសមាជិកណាដែលមានតួនាទីតាមលំដាប់ថ្នាក់អាស្រ័យដោយគណៈកម្មាធិការ នៃគណបក្សថ្នាក់លើគ្រប់គ្រងសមាជិកនោះ ចេញសេចក្តីសម្រេចបញ្ចេញពីសមាជិក ។ ក្នុងករណីបញ្ចេញពីសមាជិក គឺត្រូវមានការឯកភាពតិចបំផុត ២ ភាគ ៣ នៃសមាជិក ឬសមាជិកគណៈកម្មាធិការនៃគណបក្ស ។

២. ចំពោះអង្គការចាត់តាំងគណបក្ស

1. ការដាក់វិន័យដោយរូបភាពស្តីបន្ទោសចំពោះអង្គការចាត់តាំងគណបក្ស ត្រូវបានគណៈកម្មាធិការនៃគណបក្សថ្នាក់លើផ្ទាល់សម្រេច ។
2. ការដាក់ពិន័យដោយរូបភាពរំសាយចំពោះអង្គការចាត់តាំងគណបក្ស ត្រូវបានគណៈកម្មាធិការនៃគណបក្សថ្នាក់លើផ្ទាល់ឯកភាព ហើយស្នើឡើងគណៈកម្មាធិការនៃគណបក្សថ្នាក់លើមួយទៀតសម្រេច និងរាយការណ៍ជូនគណៈកម្មាធិការកណ្តាលនៃគណបក្ស ។

**មាត្រាទី ២៧៖**

គណៈកម្មាធិការត្រួតពិនិត្យ

០ បង្កើតគណៈកម្មាធិការត្រួតពិនិត្យ ចាប់ពីថ្នាក់ស្រុក និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ ។ នៅថ្នាក់មូលដ្ឋាននៃគណបក្ស ត្រូវចាត់តាំងប្រធានសាខាឲ្យទទួល

បន្ទុកការងារត្រួតពិនិត្យផ្ទាល់ ។

- គណៈកម្មាធិការត្រួតពិនិត្យ និងប្រធានគណៈកម្មាធិការត្រួតពិនិត្យថ្នាក់ណា គឺអាស្រ័យដោយគណៈកម្មាធិការនៃគណបក្សថ្នាក់នោះ បោះឆ្នោតជ្រើសតាំង ហើយត្រូវបានគណៈកម្មាធិការនៃគណបក្សថ្នាក់លើផ្ទាល់ ចេញសេចក្តីសម្រេច យល់ព្រមទទួលស្គាល់ ។ អាណត្តិរបស់គណៈកម្មាធិការត្រួតពិនិត្យថ្នាក់ណា គឺស្របទៅនឹងអាណត្តិគណៈកម្មាធិការនៃគណបក្សថ្នាក់នោះ។គណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ ធ្វើការក្រោមការដឹកនាំរបស់គណៈកម្មាធិការនៃគណបក្សថ្នាក់និមួយៗ ។
- បណ្តាសមាជិកគណៈកម្មាធិការត្រួតពិនិត្យនៅថ្នាក់កណ្តាល ខេត្ត ក្រុង ស្រុក និងថ្នាក់ប្រហាក់ប្រហែល គឺអាចរួមមានសមាជិមួយចំនួនជាសមាជិកគណៈកម្មាធិការនៃគណបក្ស និងសមាជិកមួយចំនួនទៀតមិនមែនជាសមាជិកគណៈកម្មាធិការនៃគណបក្សគ្រប់ ថ្នាក់ ។ ចំពោះភារកិច្ច និងសិទ្ធិអំណាចនៃគណៈកម្មាធិការត្រួតពិនិត្យគ្រប់ថ្នាក់ និងកំណត់ដោយគណៈកម្មាធិការកណ្តាលនៃគណបក្ស ។

## ជំពូកទី ១០ ហិរញ្ញវត្ថុរបស់គណបក្ស

### មាត្រាទី ២៨÷

ហិរញ្ញវត្ថុរបស់គណបក្សរួមមានទ្រព្យសម្បត្តិ និថវិការបស់គណបក្ស។ ហិរញ្ញវត្ថុ និងថវិការបស់គណបក្សបានមកពីភាគទានប្រចាំខែរបស់សមាជិក និងបានមកពីប្រាក់ចំណូលផ្សេងៗរបស់គណបក្ស។ ចំពោះចំណូល ចំណាយ និងការគ្រប់គ្រងហិរញ្ញវត្ថុ និងថវិការបស់គណបក្ស អាស្រ័យដោយគណៈកម្មាធិការកណ្តាលកំណត់ដោយឡែក។

### មាត្រាទី២៩÷

- បង្កើតគណៈកម្មាធិការហិរញ្ញវត្ថុ ចាប់ពីថ្នាក់ស្រុក និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ។ នៅថ្នាក់មូលដ្ឋាននៃគណបក្សត្រូវចាត់តាំងអនុប្រធានសាខាឲ្យទទួលបន្ទុកការងារហិរញ្ញវត្ថុផ្ទាល់។
- គណៈកម្មាធិការហិរញ្ញវត្ថុ និងប្រធានគណៈកម្មាធិការហិរញ្ញវត្ថុថ្នាក់ណា គឺអាស្រ័យ

ដោយគណៈកម្មាធិការនៃគណបក្សថ្នាក់នោះបោះឆ្នោតជ្រើសតាំង ហើយត្រូវបានគណៈកម្មាធិការ នៃគណបក្សថ្នាក់លើផ្ទាល់ ចេញសេចក្តីសម្រេចយល់ព្រមទទួលស្គាល់។ អាណត្តិរបស់គណៈកម្មាធិការហិរញ្ញវត្ថុថ្នាក់ណាគឺស្របទៅនឹងអាណត្តិរបស់គណៈកម្មាធិការនៃគណបក្សថ្នាក់នោះ។ គណៈកម្មាធិការហិរញ្ញវត្ថុគ្រប់ថ្នាក់ធ្វើការក្រោមការដឹកនាំរបស់គណៈកម្មាធិការនៃគណបក្សថ្នាក់នីមួយៗ។

០ បណ្តាសមាជិកគណៈកម្មាធិការហិរញ្ញវត្ថុនៅថ្នាក់កណ្តាល ខេត្ត ក្រុង ស្រុក និងថ្នាក់ប្រហាក់ប្រហែល គឺអាចរួមមានសមាជិកមួយចំនួន ជាសមាជិកគណៈកម្មាធិការនៃគណបក្ស និងសមាជិកមួយចំនួនទៀត មិនមែនជាសមាជិកគណៈកម្មាធិការនៃគណបក្សគ្រប់ថ្នាក់។ ចំពោះរចនាសម្ព័ន្ធ ភារកិច្ច និងសិទ្ធិអំណាចនៃគណៈកម្មាធិការហិរញ្ញវត្ថុគ្រប់ថ្នាក់ នឹងកំណត់ដោយគណៈកម្មាធិការកណ្តាលនៃគណបក្ស។

## ជំពូកទី ១១ ការកែសម្រួលលក្ខន្តិកៈរបស់គណបក្ស

### មាត្រាទី ៣០÷

មានតែមហាសន្និបាតតំណាងទូទាំងប្រទេសរបស់គណបក្សទេ ទើបមានសិទ្ធិកែសម្រួលលក្ខន្តិកៈរបស់គណបក្សបាន។

## ជំពូកទី ១២ ការរំលាយ ការរួមបញ្ចូលគ្នា និងការធ្វើសម្ព័ន្ធភាព

### មាត្រាទី ៣១÷

១. គណបក្សប្រជាជនកម្ពុជាអាចរំលាយខ្លួនឯងបាន តាមសេចក្តីសម្រេចរបស់មហាសន្និបាតតំណាងទូទាំងប្រទេសរបស់គណបក្ស។ ក្រៅពីនេះ គ្មានសមត្ថកិច្ចណាមានសិទ្ធិរំលាយគណបក្សប្រជាជនកម្ពុជាបានឡើយ លើកលែងតែគណបក្សនេះត្រូវបានរំលាយតាមសាលក្រម ឬសាលដីកាជាស្ថាពររបស់តុលាការ។

២. បើគណបក្សប្រជាជនកម្ពុជាត្រូវបានប្រកាសរំលាយដូចមានចែងក្នុងចំណុច១ខាងលើនេះ ទ្រព្យសម្បត្តិគណបក្សត្រូវចាត់ចែងចែកជូនសមាជិកគណបក្ស ឬប្រគល់ជូន

រដ្ឋតាមសេចក្តីសម្រេចរបស់មហាសន្និបាតតំណាងទូទាំងប្រទេសរបស់គណបក្ស។

៣. គណបក្សប្រជាជនកម្ពុជាត្រូវជូនដំណឹងជាលាយលក្ខអក្សរ ស្តីពីការរំលាយនេះទៅក្រសួងមហាផ្ទៃ និងផ្សព្វផ្សាយជាសាធារណៈដល់សមាជិករបស់ខ្លួននៅក្នុងប្រទេស និងក្រៅប្រទេស។

៤. គណបក្សប្រជាជនកម្ពុជាអាចប្រកាសរួមបញ្ចូលគ្នាជាមួយគណបក្សនយោបាយផ្សេងទៀតបាន តាមសេចក្តីសម្រេចរបស់មហាសន្និបាតតំណាងទូទាំងប្រទេសរបស់គណបក្ស។

៥. គណបក្សប្រជាជនកម្ពុជាអាចធ្វើសម្ព័ន្ធភាពទ្វេភាគី ឬពហុភាគីជាមួយគណបក្សនយោបាយដទៃទៀតបានដោយសេរី តាមការសម្រេចរបស់គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល។

គណៈកម្មាធិការកណ្តាលអាណត្តិទី៥
នៃគណបក្សប្រជាជនកម្ពុជា

# ៣. ការយល់ដឹងអំពីលក្ខន្តិកៈគណបក្សប្រជាជនកម្ពុជា

## ក. លក្ខន្តិកៈគណបក្សជាអ្វី?

លក្ខន្តិកៈកែប្រែថ្មីរបស់គណបក្សប្រជាជនកម្ពុជា ត្រូវបានអនុម័តដោយមហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសរបស់គណបក្ស នាថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៩១ លើមូលដ្ឋាននៃលក្ខន្តិកៈបក្សប្រជាជនបដិវត្តន៍កម្ពុជា ដែលត្រូវបានអនុម័តក្នុងមហាសន្និបាតលើកទី៤ នាថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៨១។




## ខ. បណ្ដាគោលការណ៍កសាងគណបក្ស

ប្រការសំខាន់ជាចម្បង នៃការកសាងគណបក្សមួយ ដើម្បីបំពេញបេសកកម្មបម្រើប្រទេសជាតិ និងប្រជាជន គឺត្រូវកំណត់ឱ្យបានច្បាស់ និងត្រឹមត្រូវនូវរាល់គោលការណ៍កសាងគណបក្ស។ គោលការណ៍ទាំងនេះមានតួនាទីកំណត់ និងបញ្ចូលលក្ខន្តិកៈទាំងមូល។ ចំណុចផ្សេងៗទៀត នៃលក្ខន្តិកៈ មិនអាចផ្ទុយពីខ្លឹមសារ នៃគោលការណ៍ទាំងនេះបានឡើយ។ គណបក្សនៅគ្រប់ថ្នាក់ មន្ត្រីគណបក្សគ្រប់រូប តាំងពីថ្នាក់ខ្ពស់បំផុតរហូតដល់

មន្ត្រីមូលដ្ឋានត្រូវក្ដាប់ជាប់ និងពុះពារអនុវត្តគោលការណ៍ទាំងនេះយ៉ាងម៉ឺងម៉ាត់មិនអាចខ្ជីខ្ជាបានឡើយ។

គណបក្សប្រជាជនកម្ពុជាត្រូវបានកសាងតាមគោលការណ៍ ៥ យ៉ាង ដូចតទៅ÷ សូមមើលមាត្រា៤ នៃលក្ខន្តិកៈរបស់គណបក្សគោលការណ៍ទាំង ៥ នៃការកសាងគណបក្សមានទំនាក់ទំនងផ្សារភ្ជាប់គ្នា បង្កលក្ខណៈឱ្យគ្នាទៅវិញទៅមក និងមិនអាចខ្វះមួយណាបានឡើយដើម្បីកសាងគណបក្សប្រជាជនកម្ពុជា ឱ្យកាន់តែរឹងមាំ និងមានសមត្ថភាពគ្រប់គ្រាន់ក្នុងការដឹកនាំប្រទេសជាតិ។

### គ. ភារកិច្ច និងសិទ្ធិរបស់សមាជិកគណបក្ស

ក. គណបក្សប្រជាជនកម្ពុជាបញ្ចូលជាសមាជិករបស់ខ្លួន តាមការស្ម័គ្រចិត្តនូវពលរដ្ឋកម្ពុជាទាំងពីរភេទ ដែលមានលក្ខណសម្បត្តិ ដូចខាងក្រោម÷ សូមមើលមាត្រា៥ នៃលក្ខន្តិកៈរបស់គណបក្ស

ខ. ភារកិច្ចរបស់សមាជិកគណបក្ស÷ សូមមើលមាត្រា៧ នៃលក្ខន្តិកៈរបស់គណបក្ស

គ. សិទ្ធិរបស់សមាជិកគណបក្ស÷ សូមមើលមាត្រា៨ នៃលក្ខន្តិកៈរបស់គណបក្ស

### ឃ. គោលការណ៍ចាត់តាំង និងខ្សែរយៈចាត់តាំងរបស់គណបក្ស

**ក.គោលការណ៍ចាត់តាំងរបស់គណបក្ស÷** សូមមើលមាត្រា១០ នៃលក្ខន្តិកៈរបស់គណបក្ស

**ខ.ខ្សែរយៈចាត់តាំងរបស់គណបក្ស÷** សូមមើលមាត្រា១១ នៃលក្ខន្តិកៈរបស់គណបក្ស

**គ.អង្គការមូលដ្ឋានរបស់គណបក្ស÷** សូមមើលមាត្រា១៤ នៃលក្ខន្តិកៈរបស់គណបក្ស

គណៈកម្មាធិការគណបក្សមូលដ្ឋានមានសាខាចំណុះតិច ឬច្រើន ស្របទៅតាមសភាពការណ៍ជាក់ស្ដែងនៃមូលដ្ឋាននីមួយៗ។ ចំពោះសាខាចំណុះនៅមូលដ្ឋាន ឬផ្នែកណាដែលមានសមាជិកគណបក្សច្រើនត្រូវបង្កើតអនុសាខា និងចងក្រងជាក្រុមបក្សចំណុះ

អនុសាខា។

## គណៈកម្មាធិការគណបក្សមូលដ្ឋានមានតួនាទី÷

ក្ដាប់ជាប់នូវ **កម្មវិធីនយោបាយរបស់គណបក្ស** ដើម្បីចាត់តាំងអនុវត្តឱ្យស្របតាមសភាពការណ៍ជាក់ស្ដែងនៅមូលដ្ឋាន។

ដឹកនាំ **ការងារគណបក្ស** អំពីការងារនយោបាយ សតិអារម្មណ៍ និងចាត់តាំងក្នុងក្របខ័ណ្ឌមូលដ្ឋានរបស់ខ្លួន។

**ផ្សារភ្ជាប់ជិតស្និទ្ធ** ជាមួយ **មហាជន ប្រជាជននៅមូលដ្ឋាន** ខិតខំបំផុសមហាជនចូលរួមកសាងពង្រឹងរដ្ឋអំណាច និងកែលម្អជីវភាពរស់នៅ

**ការពារឥទ្ធិពល** និង **ប្រជាប្រិយភាពរបស់គណបក្ស** ខិតខំប្រមូលកម្លាំងមហាជនច្រើនកុះករឱ្យគាំទ្រគណបក្សប្រជាជនកម្ពុជា។

## គណៈកម្មាធិការគណបក្សមូលដ្ឋានមានភារកិច្ច÷

ក្ដាប់ជាប់ **កម្មវិធីនយោបាយ លក្ខន្តិកៈ គោលការណ៍នានា** និង **សេចក្ដីសម្រេចផ្សេងៗ** របស់គណបក្សថ្នាក់លើកសាងទិសដៅ និងផែនការអនុវត្តឱ្យបានសមស្របនឹងសភាពការណ៍ជាក់ស្ដែងនៅមូលដ្ឋាន

យកចិត្តទុកដាក់ **អប់រំសមាជិកគណបក្ស ប្រជាជន មហាជន** ឱ្យបានយល់ជ្រួតជ្រាបច្បាស់អំពីសភាពការណ៍និងសមិទ្ធផលនានារបស់ជាតិ ដើម្បីធ្វើឱ្យសមាជិកគណបក្ស ប្រជាជន មហាជន មានស្មារតីភ្ញាក់រលឹកខ្ពស់និងសមានចិត្តគាំទ្រគណបក្សយ៉ាងសកម្ម

បង្កើន **សាមគ្គីភាព ឯកភាព** ក្នុងជួរសមាជិកគណបក្ស ផ្សារភ្ជាប់ជិតស្និទ្ធជាមួយប្រជាជនមហាជន និងមានទំនាក់ទំនងសហការល្អជាមួយរដ្ឋអំណាច អង្គការសង្គម អង្គការក្រៅរដ្ឋាភិបាល អង្គភាពផលិតកម្ម អង្គភាពជំនាញ ដែលបោះទីតាំងនៅមូលដ្ឋានរបស់ខ្លួន

បែងចែក **ភារកិច្ចទទួលខុសត្រូវ** និង **ត្រួតពិនិត្យការងារ** របស់សមាជិកនៃគណៈកម្មាធិការគណបក្ស។ គ្រប់គ្រងសមាជិកគណបក្សឱ្យបានល្អ អនុវត្តភារកិច្ចលើកសរសើរ និងដាក់វិន័យចំពោះសមាជិកគណបក្ស រួមទាំងជំរុញការងារពង្រីកសមាជិកថ្មី និងការងារពង្រឹងគណបក្ស អនុវត្តរបបប្រជុំជីវភាពគណបក្សទៀងទាត់

លើកកម្ពស់ **ស្មារតីប្រុងប្រយ័ត្ន ការពារមន្ត្រី** គណបក្សដែលស្ថិតក្នុងជួររដ្ឋអំណាច **រក្សាការសម្ងាត់** របស់គណបក្ស ទប់ស្កាត់ឱ្យបានដាច់ខាតនូវការជ្រៀតចូលនៃសមាសភាពឱកាសនិយម ដើម្បីបំផ្លិចបំផ្លាញគណបក្ស

លើកកម្ពស់ **ស្មារតីម្ចាស់ការក្នុងការគ្រប់គ្រង** និង **ថែរក្សាទ្រព្យសម្បត្តិ** របស់គណបក្សនៅថ្នាក់មូលដ្ឋានរបស់ខ្លួនឱ្យបានម៉ត់ចត់ និងអនុវត្តគោលការណ៍សន្សំសំចៃ មិនខ្ជះខ្ជាយ ហើយសមាជិកគណៈ-កម្មាធិការគណបក្សត្រូវប្រកាន់ខ្ជាប់នូវសីលធម៌ថ្លៃថ្នូរ អត្តចរិតស្លូតបូតទំនាក់ទំនងល្អជាមួយប្រជាជន មហាជន

របៀបរបបការងាររបស់គណៈកម្មាធិការគណបក្សមូលដ្ឋានរួមមាន÷ របបសន្និបាត របបប្រជុំ របបចុះមូលដ្ឋាន របបរៀនសូត្រ របបត្រួតពិនិត្យការងារ និងរបបរាយការណ៍សុំយោបល់។

# រចនាសម្ព័ន្ធ និងខ្សែរយៈចាត់តាំងគណបក្សប្រជាជនកម្ពុជា



# ៤. ការកសាងអត្តចរិត សីលធម៌ល្អប្រពៃរបស់មន្ត្រីគណបក្ស

ការងារកសាងមន្ត្រីគណបក្ស គឺជាការងារជាមូលដ្ឋានមួយដែលមានអត្ថន័យកំណត់ចំពោះជោគជ័យរបស់គណបក្ស។ មានមន្ត្រីគណបក្សល្អទើបអង្គការចាត់តាំងគណបក្សរឹងមាំ មានមន្ត្រីគណបក្សល្អទើបប្រជាជនមានជំនឿលើការដឹកនាំរបស់គណបក្ស មានមន្ត្រីគណបក្សល្អ ទើបធានាឱ្យកម្មវិធីនយោបាយរបស់គណបក្ស បានប្រែក្លាយទៅជាការពិត និងរួមចំណែកធ្វើឱ្យកម្មវិធីនយោបាយរបស់គណបក្សកាន់តែសុក្រឹតឡើង។ មហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសរបស់គណបក្ស កាលពីថ្ងៃទី៣០-៣១ ខែមករា ដល់ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១៥ បានកំណត់យុទ្ធសាស្ត្រ "ផ្អែកលើអំពើល្អរបស់មន្ត្រីគណបក្ស គុណភាព និងបរិមាណរបស់សាមជិកគណបក្ស ដើម្បីឈ្នះឆ្នោត"។

## ក. តួនាទីដ៏ថ្លៃថ្លារបស់មន្ត្រីគណបក្សតាំងពីដំណាក់កាលសង្គ្រោះជាតិ ពីរបបប្រល័យពូជសាសន៍ រហូតមកដល់ពេលបច្ចុប្បន្ន

មន្ត្រីគណបក្ស គឺជាកម្លាំងស្នូលក្នុងការអនុវត្តភារកិច្ចនយោបាយ របស់គណបក្ស ក៏ដូចក្នុងការងារកសាងគណបក្សក្នុងដំណាក់កាលនីមួយៗ។ ប្រវត្តិរបស់គណបក្សគឺជាប្រវត្តិនៃចលនាតស៊ូរបស់មន្ត្រីគណបក្ស រួមទាំងយុទ្ធជន យុទ្ធនារីនិងអ្នកស្នេហាជាតិច្រើនឥតគណនាដែលបានធ្វើពលិកម្មយ៉ាងអង់អាចក្លាហានបំផុត ហ៊ានលះបង់សាច់ស្រស់ឈាមស្រស់ អាយុជីវិតដោយឥតរួញរា ក្នុងការតស៊ូ ដើម្បីឯករាជ្យជាតិ ប្រឆាំងរបបអាណានិគមនិយម (ដែលបានដាក់អាណានិគមត្រួតត្រាមកលើប្រទេសកម្ពុជា អស់រយៈពេលជិត ១សតវត្ស) ការតស៊ូរំដោះប្រទេសជាតិពីឆ្នាំ១៩៧០-១៩៧៥ ប្រឆាំងនឹងការឈ្លានពានរបស់បរទេស និងជាពិសេសការផ្ដួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានសង្គ្រោះជាតិឱ្យរស់រានមានជីវិតឡើងវិញ បង្កើតបាននូវបុព្វបទសម្រាប់ការកសាង និងការពារមាតុភូមិកម្ពុជា រហូតមមកដល់ពេលបច្ចុប្បន្ននេះ។

ក្រោយពីបានសម្រេចភារកិច្ចផ្ដួលរំលំរបបប្រល័យពូជសាសន៍ រហូតទទួលបានជ័យជម្នះជាប្រវត្តិសាស្ត្រ នាថ្ងៃទី៧ខែមករា ឆ្នាំ១៩៧៩។ គណបក្សត្រូវបានកសាងឡើង

វិញទាំងខាងនយោបាយ សតិអារម្មណ៍ និងចាត់តាំង សំដៅធានានូវសំណូមពរដឹកនាំនៅក្នុងដំណាក់កាលថ្មីដែលមានចរិតតានតឹង ប្ដូរផ្ដាច់ លំបាកស្មុគស្មាញ និងគ្រោះថ្នាក់ជាទីបំផុត។

## ខ. លក្ខណសម្បត្តិរបស់មន្ត្រីគណបក្ស

ផ្ដើមចេញពីគោលបំណង និងឧត្តមគតិរបស់គណបក្ស និងភារកិច្ចនយោបាយរបស់គណបក្សក្នុងដំណាក់កាលបច្ចុប្បន្ន មន្ត្រីគណបក្សត្រូវមានលក្ខណសម្បត្តិ ដូចខាងក្រោម÷




## គ. ភារកិច្ចរបស់មន្ត្រីគណបក្ស

មន្ត្រីគណបក្សមានភារកិច្ច ដូចខាងក្រោម÷



ក្ដាប់ជាប់ និងប្រតិបត្តិឱ្យបានត្រឹមត្រូវនូវកម្មវិធីនយោបាយ លក្ខន្តិកៈ គោលការណ៍ និងសេចក្តីសម្រេចនានារបស់គណបក្ស។



បម្រើប្រជាជនអស់ពីចិត្តពីថ្លើម គោរពសិទ្ធិ និងផលប្រយោជន៍របស់ប្រជាជន ខិតខំឃោសនា អប់រំប្រជាជននិងចលនាប្រជាជនឱ្យគាំទ្រ និងចូលរួមអនុវត្តកម្មវិធីនយោបាយ និងសេចក្តីសម្រេចនានារបស់គណបក្ស។



គោរពប្រតិបត្តិវិន័យរបស់គណបក្ស និងច្បាប់របស់រដ្ឋ ប្រព្រឹត្តតែអំពើល្អក្នុងជីវភាពរស់នៅ ជីវភាពការងារ និងទំនាក់ទំនងសង្គមផ្សេងៗទៀត។



រក្សាសាមគ្គីភាព ឯកភាពផ្ទៃក្នុងឱ្យបានរឹងមាំ ប្រឆាំងរាល់បាតុភាពបំបែកបំបាក់សាមគ្គីភាព ប្រកាន់បក្សពួកដោយឈរលើមូលដ្ឋានកម្មវិធីនយោបាយ លក្ខន្តិកៈ គោលការណ៍ គោលនយោបាយ និងសេចក្តីសម្រេចនានារបស់គណបក្ស។

## ឃ. តើធ្វើដូចម្តេច ដើម្បីក្លាយខ្លួនជាមន្ត្រីល្អរបស់គណបក្ស?



ត្រូវពង្រឹងស្មារតីពុះពារអប់រំ កសាងខ្លួនជាប្រចាំ គឺជាការតស៊ូមួយសំដៅជម្រុះចោលនូវភាពអសកម្ម និងចំណុចខ្សោយផ្សេងៗដែលនៅជាប់នឹងខ្លួន ហើយពង្រឹងឥតឈប់ឈរនូវកត្តាសកម្មរបស់មន្ត្រីម្នាក់ៗ។



ត្រូវខិតខំរៀនសូត្រជាប្រចាំ មនុស្សម្នាក់ៗ ទោះរៀនសូត្រដល់កម្រិតណាក៏ដោយ ក៏មិនអាចយល់ដឹងគ្រប់បញ្ហា និងគ្រប់ទិដ្ឋភាពនៃសង្គមបានឡើយ។ “មន្ត្រីរៀមច្បងគឺជាគ្រូ ឯការអនុវត្តជាក់ស្តែង គឺជាសាលារៀន”។



ត្រូវមានទំនាក់ទំនងជិតស្និទ្ធជាមួយប្រជាជន មន្ត្រីគណបក្សត្រូវតែមានពេលវេលាចុះដល់មូលដ្ឋានដែលប្រជាជនរស់នៅ និងប្រកបអាជីវកម្ម ស្វែងយល់ពីអ្វីៗដែលបានកើតឡើងក្នុងមូលដ្ឋាន ដោយការសង្កេតផ្ទាល់ភ្នែកផង ការស្តាប់ប្រជាជននិយាយផង ដើម្បីមានព័ត៌មានគ្រប់ជ្រុងជ្រោយសម្រាប់ធ្វើការវិភាគ ធ្វើសំយោគ និងធ្វើសេចក្តីសម្រេចចិត្ត។



ត្រូវចេះស្វ័យត្រួតពិនិត្យ គួបផ្សំនឹងការទទួលយកនូវមតិកែលម្អរបស់សមូហភាព មន្ត្រីគណបក្សត្រូវចេះស្វ័យត្រួតពិនិត្យកែលម្អខ្លួន ដើម្បីបង្ការ និងទប់ស្កាត់កុំឱ្យកំហុសឆ្គង និងចំណុចខ្វះខាតអាចកើតឡើងដដែលៗ ដែលបង្កផលវិបាកដល់ខ្លួនផ្ទាល់ ក៏ដូចសង្គមជាតិ។

# ផ្នែកទី២. កម្មវិធីនយោបាយ

## ១. គោលនយោបាយរបស់គណបក្សប្រជាជនកម្ពុជាសម្រាប់កសាង និងការពារមាតុភូមិ ឆ្នាំ២០១៨-២០២៣

១- ពង្រឹងសាមគ្គីភាពជាតិទាំងមូល គោរពរដ្ឋធម្មនុញ្ញ ការពាររបបរាជានិយម លើកស្ទួយលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ធានាគោរពសិទ្ធិមនុស្ស ការគោរពច្បាប់ និងយុត្តិធម៌សង្គម។

២- ការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី សន្តិភាព និងសន្តិសុខរបស់ជាតិឱ្យរឹងមាំ ស្ថិតស្ថេរគង់វង្ស។

៣- អភិវឌ្ឍសេដ្ឋកិច្ចឱ្យសម្រេចបានកំណើនក្នុងរង្វង់ ៧% ក្នុង១ឆ្នាំ ប្រកបដោយចីរភាព បែងចែកផ្លែផ្កា នៃកំណើនសេដ្ឋកិច្ចដោយសមធម៌ និងកាត់បន្ថយអត្រាភាពក្រីក្រឱ្យបានជាង ១% ក្នុង ១ ឆ្នាំ។

៤- មិនយកពន្ធលើដីកសិកម្ម របស់កសិករដែលបង្កបង្កើនផលជាលក្ខណៈគ្រួសារ ជួយកសិករធានាការពង្រីកផលិតកម្ម និងការរកទីផ្សារលក់កសិផលដោយសមរម្យ។ ប្រជាជនដែលគ្មានដីនិងទទួលបានដីសម្រាប់សង់លំនៅឋាន និងបង្កបង្កើនផលតាមរយៈកម្មវិធីសម្បទានដីសង្គមកិច្ច។

៥- ដំឡើងប្រាក់ឈ្នួលប្រចាំខែរបស់កម្មករ និយោជិត បូកនឹងប្រាក់អត្ថប្រយោជន៍ផ្សេងទៀត លើកកម្ពស់លក្ខខណ្ឌការងារ និងការពារអាជីពរបស់កម្មករនិយោជិត។

៦- ដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងបង្កើនប្រាក់សោធនសម្រាប់និវត្តជន និងអតីតយុទ្ធជន។

៧- អាជីវករលក់ដូរតាមផ្សារលើទីតាំងដីរដ្ឋអាចផ្ទេរសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលទៅកូនចៅ ឬអ្នកដទៃបាន ដោយពុំមានកំណត់អាណត្តិ។

៨- យុវជនគ្រប់រូបទទួលបានឱកាសក្នុងការអប់រំ មានការងារធ្វើ និងចូលរួមធ្វើ

ឧបសម្ព័ន្ធ

សេចក្ដីសម្រេចចិត្តទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ គ្រប់ស្រុកមានវិទ្យាល័យ គ្រប់ឃុំមានអនុវិទ្យាល័យ និងតាមភូមិមានបឋមសិក្សា។ ប្រជាជនទូទៅទទួលបានសេវាសុខភាពកាន់តែប្រសើរនៅមណ្ឌលសុខភាព និងមន្ទីរពេទ្យរដ្ឋ។ ប្រជាជនក្រីក្រ និងអ្នកខ្វះលទ្ធភាពទទួលបានសេវាពិនិត្យ និងព្យាបាលជំងឺដោយឥតបង់ថ្លៃនៅមណ្ឌលសុខភាព និងមន្ទីរពេទ្យរដ្ឋ។

៩- អភិវឌ្ឍ និងពង្រឹងប្រព័ន្ធគាំពារសង្គមប្រកបដោយប្រសិទ្ធភាព និងចីរភាពដែលជួយគាំពារប្រជាជនគ្រប់រូបពីហានិភ័យនានា ដោយមិនទុកឱ្យប្រជាជនណាម្នាក់ស្ថិតនៅក្រៅប្រព័ន្ធគាំពារសង្គមឡើយ។

១០- ពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្ដាញជាតិឱ្យដល់គ្រប់ភូមិទាំងអស់នៅឆ្នាំ ២០២០ និងបញ្ចុះថ្លៃអគ្គិសនី។ តភ្ជាប់ផ្លូវគមនាគមន៍ពីទីប្រជុំជនទៅគ្រប់ភូមិ កែលម្អផ្លូវជនបទពីផ្លូវដីទៅជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុង។

១១- ផ្ដល់សេវាសាធារណៈនៅគ្រប់ថ្នាក់ជូនប្រជាជនប្រកបដោយគុណភាព តម្លាភាព ប្រសិទ្ធភាព និងងាយស្រួល រក្សាសុវត្ថិភាពឃុំ សង្កាត់ឱ្យបានល្អ និងរឹងមាំ។

# ២. កម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា ២០១៨-២០២៣

## បុព្វកថា

ក្នុងរយៈពេល ៣៩ ឆ្នាំកន្លងមកនេះ គណបក្សប្រជាជនកម្ពុជាបានដឹកនាំប្រទេស សម្រេចបានសមិទ្ធផលដ៏វិសេសវិសាលដែលផ្ដើមពីជ័យជម្នះ៧មករា និងដំណើរឆ្ពោះទៅកាន់សុខសន្តិភាពពេញបរិបូរណ៍ ដែលអាចសម្រេចបាននូវការផ្លាស់ប្ដូរសង្គមយ៉ាងធំធេង ដែលប្រែក្លាយកម្ពុជាពីវាលពិឃាតនៃរបបប្រល័យពូជសាសន៍ ពីសមរភូមិនៃសង្គ្រាមដ៏រ៉ាំរ៉ៃ ពីការបែកបាក់ជាតិ និងការបែងចែកទឹកដី ពីគំនរផេះផង់ទៅជាទឹកដីដែលមានសន្តិភាព ឯកភាព ស្ថិរភាព ប្រជាធិបតេយ្យ នីតិរដ្ឋ និងអភិវឌ្ឍន៍លើគ្រប់វិស័យដែលធ្វើឱ្យប្រជាជនគ្រប់រូប រស់នៅប្រកបដោយក្ដីសង្ឃឹមយ៉ាងសុខដុមរមនា ក្រោមដំបូលនៃរដ្ឋធម្មនុញ្ញតែមួយ និងម្លប់ដ៏ត្រជាក់នៃអង្គព្រះមហាក្សត្រជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

នៅលើមាគ៌ានៃជ័យជម្នះ សន្តិភាព ស្ថិរភាព សមិទ្ធផលដែលយើងសម្រេចបានមកដល់ពេលនេះនិងដំណើរឆ្ពោះទៅមុខទៀត គណបក្សចងចាំ និងចារិកទុកជារៀងរហូតនូវស្មារតីលះបង់ និងការចូលរួមយ៉ាងធំធេងរបស់សមាជិក សមាជិកាគណបក្ស និងជនរួមជាតិនៅគ្រប់ទិសទីនៅក្នុងបុព្វហេតុដ៏ឧត្ដុង្គឧត្ដមរបស់ប្រជាជាតិ និងគណបក្ស ហើយគាំទ្រពេញទំហឹងចំពោះបេក្ខភាពសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាសម្រាប់នីតិកាលទី៦នៃរដ្ឋសភាព្រមទាំងនីតិកាលបន្តបន្ទាប់។ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** គឺជាស្នូលរបស់គណបក្សប្រជាជនកម្ពុជា និងជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើម នៃប្រជាជនកម្ពុជា ដែលបានដឹកនាំប្រទេស ប្រកបដោយគតិបណ្ឌិត ភាពឈ្លាសវៃ និងភាពអង់អាច សម្រេចបានជោគជ័យ ដ៏ត្រចះត្រចង់បំផុតជូនជាតិ មាតុភូមិ និងប្រជាជន។

ដើម្បីបន្តបេសកកម្មបម្រើជាតិ និងប្រជាជនឱ្យសម្រេចបានសមិទ្ធផលកាន់តែធំធេងឡើងថែមទៀត **គណបក្សប្រជាជនកម្ពុជា** ប្រកាសកម្មវិធីនយោបាយសម្រាប់ការកសាង និងការពារមាតុភូមិពីឆ្នាំ២០១៨-២០២៣ ដូចតទៅ៖

## ក- គោលដៅជាយុទ្ធសាស្ត្ររបស់គណបក្ស

ក្នុងស្មារតីប្រកាន់ខ្ជាប់ឥតប្រែប្រួលនូវគោលបំណង និងឧត្តមគតិដ៏ថ្លៃថ្លារបស់ខ្លួន និងផ្តើមចេញពីសំណូមពរនៃសភាពការណ៍ទូទៅបច្ចុប្បន្ន គណបក្សប្រជាជនកម្ពុជាប្តេជ្ញាសម្រេចគោលដៅធំៗជាយុទ្ធសាស្ត្រ ដូចខាងក្រោម÷

**គោរព ប្រតិបត្តិ ការពាររដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ការពាររបបរាជានិយម និងរាល់សមិទ្ធផលរបស់ជាតិឱ្យបានស្ថិតស្ថេរ**
លើកកម្ពស់លទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស ធានាសិទ្ធិមនុស្ស ការគោរពច្បាប់ និងយុត្តិធម៌ក្នុងសង្គម ពង្រឹងឆ្លងសាមគ្គីជាតិ

**រក្សា ការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដីឱ្យបានគង់វង្ស ការពារសន្តិភាព ស្ថិរភាព និងសន្តិសុខជាតិយ៉ាងរឹងមាំ**
ដើម្បីធានាដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមដោយចីរភាព និងការរស់នៅដ៏សុខសាន្តរបស់ប្រជាជន

**កសាងព្រះរាជាណាចក្រកម្ពុជា ជារដ្ឋដ៏រឹងមាំ និងជឿនលឿនដោយផ្អែកលើច្បាប់**
ធានាការអនុវត្តច្បាប់ដោយស្មើភាពសម្រាប់ពលរដ្ឋគ្រប់រូប ពលរដ្ឋម្នាក់ៗមានសិទ្ធិពេញលេញ និងមានកាតព្វកិច្ចចូលរួមយ៉ាងសកម្មក្នុងការកសាង និងការពារមាតុភូមិ

**បន្តខិតខំអភិវឌ្ឍប្រទេសឱ្យរីកចម្រើនឥតឈប់ឈរលើគ្រប់វិស័យ និងកាន់តែមានមូលដ្ឋានរឹងមាំ**
សំដៅក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ដោយប្រកាន់ខ្ជាប់ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យមានកំណើនខ្ពស់

**អភិវឌ្ឍប្រព័ន្ធគាំពារសង្គមមួយប្រកបដោយបរិយាប័ន្ន ប្រសិទ្ធភាព និងចីរភាពហិរញ្ញវត្ថុ**
ដែលធានានូវការផ្តល់ការគាំពារ និងការពង្រីកសមត្ថភាពនៃសមាជិកគ្រប់រូបក្នុងសង្គម ក្នុងការឆ្លើយតបចំពោះហានិភ័យសេដ្ឋកិច្ច និងភាពងាយរងគ្រោះផ្សេងៗ

**កសាងទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អប្រសើររវាងព្រះរាជាណាចក្រកម្ពុជា ជាមួយគ្រប់ប្រទេស និងអង្គការអន្តរជាតិ**
ដើម្បីជំរុញការអភិវឌ្ឍប្រទេស ជំរុញសមាហរណកម្មកម្ពុជាក្នុងសហគមន៍អន្តរជាតិ ដោះស្រាយរាល់បញ្ហារវាងរដ្ឋ និងរដ្ឋដោយសន្តិវិធី

## ខ- គោលនយោបាយធំៗជាអាទិភាព

ដើម្បីសម្រេចគោលដៅជាយុទ្ធសាស្ត្រខាងលើនេះ គណបក្សកំណត់គោលនយោបាយធំៗជាអាទិភាពគឺ÷

### ខ.១-ការពារយ៉ាងរឹងមាំនូវឯករាជ្យ សេរីភាព អធិបតេយ្យ បូរណភាពទឹកដី និងសន្តិភាព ដើម្បីធានាការអភិវឌ្ឍប្រទេសជាតិនិងភាពសុខដុមរមនារបស់ប្រជាជន

**ការពារយ៉ាងរឹងមាំ ឯករាជ្យ សេរីភាព អធិបតេយ្យ បូរណភាពទឹកដី និង សន្តិភាព** ដើម្បីធានាការអភិវឌ្ឍប្រទេសជាតិនិងភាពសុខដុមរមនារបស់ប្រជាជន

បន្តប្រោងខ្ពស់ទង់មហាសាមគ្គីជាតិក្រោមដំបូល **រដ្ឋធម្មនុញ្ញ**នៃព្រះរាជាណាចក្រកម្ពុជា និងការពារមិនឱ្យមានការផ្លាស់ប្តូរណាមួយដែលផ្ទុយពីរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន

**ការពាររាល់សមិទ្ធផលនៃសង្គមជាតិ** ធានាដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមដោយចីរភាព និង**ការពារមិនឱ្យកម្ពុជាវិលត្រឡប់ទៅរកគ្រោះមហន្តរាយ**ជាថ្មីម្តងទៀត

បាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ**

សំដៅប្រមូលកម្លាំងប្រជាជាតិទាំងមូលដោយមិនប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀត

**មិនអនុញ្ញាតឱ្យបរទេសណាមកជ្រៀតជ្រែករំលោភបំពានលើឯករាជ្យ អធិបតេយ្យ** និង **បូរណភាពទឹកដីរបស់កម្ពុជា**ឡើយ ដើម្បីការពារសន្តិភាព និងស្ថិរភាពនយោបាយ

យើងប្រឆាំងដាច់ខាតចំពោះ**ខ្សាយកល** និង **សកម្មភាពខុសច្បាប់**របស់មជ្ឈដ្ឋានណាក៏ដោយ ទោះជាបុគ្គល ជាក្រុម ឬជាអង្គការនយោបាយ ដែលព្យាយាម **បំផ្លាញឯកភាពជាតិ បង្កអស្ថិរភាពក្នុងសង្គម** និង**បំផ្លាញលទ្ធិប្រជាធិបតេយ្យ**

## ២.២-លើកកម្ពស់ជីវភាពរបស់ប្រជាជនគ្រប់រូបទាំងខាងសម្ភារៈ និងស្មារតីឱ្យបានសមរម្យប្រកបដោយភាពថ្លៃថ្នូរ

លើកកម្ពស់ **ជីវភាពរបស់ប្រជាជនគ្រប់រូប**ទាំងខាងសម្ភារៈ និងស្មារតីឱ្យបានសមរម្យប្រកបដោយភាពថ្លៃថ្នូរ

បន្តជំរុញការរៀបចំ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៨-២០២៣** ប្រកបដោយភាពប្រាកដនិយម ប្រទាក់ក្រឡាគ្នា និងឈរលើគោលការណ៍ "**មិនទុកឱ្យប្រជាជនកម្ពុជាណាម្នាក់ស្ថិតនៅក្រៅការអភិវឌ្ឍឡើយ**"

**ពង្រឹងសមត្ថភាពរបស់សមាជិកគ្រប់រូបក្នុងសង្គម**ក្នុងការឆ្លើយតបចំពោះហានិភ័យសេដ្ឋកិច្ច ទប់ស្កាត់ កាត់បន្ថយភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព ហើយរួមចំណែកដល់ការអភិវឌ្ឍ និងគាំពារធនធានមនុស្សកាន់តែរឹងមាំទូលំទូលាយ ព្រមទាំងជំរុញកំណើនសេដ្ឋកិច្ច

បន្តផ្តល់អាទិភាពខ្ពស់ដល់ការ **អភិវឌ្ឍធនធានមនុស្ស ទឹក ភ្លើង** និង**ផ្លូវ**ដែលជាកត្តាដ៏សំខាន់ចាំបាច់សម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ចដោយចីរភាព និងបរិយាប័ន្ន និងការបែងចែកផ្លែផ្កានៃកំណើនដោយសមធម៌ដើម្បីលើកម្ពស់ជីវភាពរបស់ប្រជាជន

បន្តអភិវឌ្ឍ និងពង្រឹង**ប្រព័ន្ធគាំពារសង្គម**មួយដែលមានប្រសិទ្ធភាព ចីរភាពហិរញ្ញវត្ថុ និងមានវិសាលភាពគ្របដណ្តប់ ដើម្បីផ្តល់ការគាំពារ

បន្តពង្រឹងបណ្តាលក្ខខណ្ឌចាំបាច់សម្រាប់ធានាឱ្យ**ប្រជាពលរដ្ឋគ្រប់រូបមានការងារធ្វើ** ដែលទទួលបាន**ប្រាក់ចំណូលសមរម្យ**ធ្វើឱ្យការរស់នៅមានស្ថិរភាព និងភាពថ្លៃថ្នូរ

## ២.៣-ការពាររបបរាជានិយម លើកស្ទួយលទ្ធិប្រជាធិបតេយ្យ សិទ្ធិសេរីភាពរបស់ប្រជាជន និងការគោរពច្បាប់

ប្រកាន់ខ្ជាប់**របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ**តាមប្រព័ន្ធនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ឱ្យស្ថិតស្ថេរជានិច្ចនិរន្តរ៍ស្របតាមបេសកកម្មជាប្រវត្តិសាស្ត្ររបស់គណបក្ស និងស្របតាមឆន្ទៈរបស់ប្រជាជនកម្ពុជាដែលគោរពស្រឡាញ់ និងលើកតម្កើង **អង្គព្រះមហាក្សត្រ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដើម្បីព្រះអង្គទ្រង់គង់ជាម្លប់ដ៏ត្រជាក់ត្រជុំនៃប្រជាជាតិខ្មែរទាំងមូល

ការពារ **របបរាជានិយម** លើកស្ទួយ **លទ្ធិប្រជាធិបតេយ្យ សិទ្ធិសេរីភាពរបស់ប្រជាជន** និង **ការគោរពច្បាប់**

ពង្រឹង**ប្រព័ន្ធយុត្តិធម៌**តាមរយៈការបន្តពង្រឹង និងលើកកម្ពស់នីតិរដ្ឋដោយធ្វើការពិនិត្យកែលម្អក្របខ័ណ្ឌច្បាប់ និងតាក់តែងច្បាប់ថ្មីៗបន្ថែមទៀត សំដៅឱ្យប្រទេសយើងមានក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់ និងល្អស្របតាមការវិវត្តន៍រីកចម្រើនរបស់សង្គមដើម្បីការពារផលប្រយោជន៍ប្រជាជន និងផលប្រយោជន៍សាធារណៈ

បន្តពង្រឹងពង្រីក**លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស** ឱ្យចាក់គ្រឹះកាន់តែរឹងមាំពីថ្នាក់ជាតិរហូតដល់មូលដ្ឋាន ដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាជនក្នុងការកសាង និងការពារមាតុភូមិប្រកបដោយភាពជាម្ចាស់លើជោគវាសនាអនាគតប្រទេសជាតិ

គាំទ្រយ៉ាងម៉ឺងម៉ាត់ចំពោះដំណើរការរៀបចំ**ការបោះឆ្នោតទាំងសកល** និង**អសកល** ស្របតាមគោលការណ៍នៃប្រជាធិបតេយ្យ និងនីតិរដ្ឋឱ្យបានទៀងទាត់តាមអាណត្តិដែលកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានសុវត្ថិភាព

ធានាការការពារ និងលើកស្ទួយ**សិទ្ធិសេរីភាព**របស់ប្រជាជនក្នុងការបង្កើត ការជ្រើសរើស និងការចូលរួមសកម្មភាពនយោបាយក្នុងគណបក្សនយោបាយនានាដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិ កតិកាសញ្ញា សន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិនានាស្តីពីសិទ្ធិមនុស្ស

## ២.៤-ពង្រឹងរដ្ឋបាលសាធារណៈនៅគ្រប់ថ្នាក់ ជារដ្ឋបាលរបស់ប្រជាជន និងបម្រើផលប្រយោជន៍របស់ប្រជាជន

បន្តពង្រឹង**រដ្ឋបាលសាធារណៈ** ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជារដ្ឋបាលទំនើប ស្អាតស្អំនិងមានគុណភាព ដើម្បីបម្រើប្រជាជន និងផលប្រយោជន៍សាធារណៈប្រកបដោយប្រសិទ្ធភាពខ្ពស់

ពង្រឹង **រដ្ឋបាលសាធារណៈ** នៅគ្រប់ថ្នាក់ ជារដ្ឋបាលរបស់ប្រជាជន និងបម្រើផលប្រយោជន៍របស់ប្រជាជន

ពង្រឹង**ការទទួលខុសត្រូវ ការដាក់ពិន័យ** និង**ការលើកទឹកចិត្ត** ទាំងចំពោះមន្ត្រី ទាំងចំពោះស្ថាប័នសាធារណៈក្នុងការបម្រើប្រជាជន។ បង្កើន**ប្រាក់បៀវត្ស**ជារៀងរាល់ឆ្នាំជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ព្រមទាំងបង្កើនប្រាក់សោធននិវត្តសម្រាប់និវត្តជន និងអតីតយុទ្ធជនឱ្យមានចីរភាព

ពង្រឹងនិង**លើកកម្ពស់សមត្ថភាព**ស្ថាប័នសាធារណៈគ្រប់ថ្នាក់ដោយធ្វើការពិនិត្យ កែលម្អរចនាសម្ព័ន្ធ តួនាទី ភារកិច្ច ចំនួនក្របខ័ណ្ឌនៅតាមស្ថាប័ននីមួយៗឱ្យបានសមស្របរួមទាំងលើកម្ពស់គុណភាព **សមត្ថភាពមន្ត្រីរាជការ**ប្រកបដោយជំនាញ និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់

បង្កើត**យន្តការទទួលដោះស្រាយ** និង **ទទួលព័ត៌មាន**ត្រឡប់ពីប្រជាជនអំពីការផ្តល់សេវាសាធារណៈគ្រប់ប្រភេទ ដើម្បីធានាឱ្យមានការចូលរួម ការជឿទុកចិត្តពីប្រជាជន និងឆ្លើយតបបានតាមសំណូមពររបស់ប្រជាជន

លើកកម្ពស់**សមត្ថភាពស្ថាប័នសាធារណៈ** គ្រប់ថ្នាក់ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាជនគ្រប់មជ្ឈដ្ឋានឱ្យកាន់តែប្រសើរឡើងទាំងគុណភាព ប្រសិទ្ធភាព និងវិសាលភាព ដោយបង្ខិតការផ្តល់សេវាសាធារណៈ ទៅជិតប្រជាពលរដ្ឋ

## ២.៥- បន្តជំរុញការកែទម្រង់ ដើម្បីអភិបាលកិច្ចល្អ




## ២.៦- ជំរុញការអភិវឌ្ឍសង្គម សេដ្ឋកិច្ចឱ្យមានការរីកចម្រើនប្រកបដោយចីរភាព សមធម៌ និងបរិយាប័ន្ន

**ការគ្រប់គ្រងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ**

*បន្តធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងជំរុញកំណើនសេដ្ឋកិច្ចខ្ពស់*
*រក្សាឱ្យបាននូវចីរភាពថវិកា*
*បង្កើនបរិយាប័ន្ននៃកំណើនសេដ្ឋកិច្ច*
*ពង្រឹងសមត្ថភាពប្រកួតប្រជែង*

**ការអភិវឌ្ឍវិស័យឯកជន**

**ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត**

*ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងដឹកជញ្ជូនអាកាសចរស៊ីវិល*
*ការគ្រប់គ្រងធនធានទឹក និងអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ*
*ការអភិវឌ្ឍទឹកស្អាត*
*ការអភិវឌ្ឍថាមពលអគ្គិសនី*
*ការអភិវឌ្ឍធនធានរ៉ែ ប្រេងកាត និងឧស្ម័ន*
*ការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន*

**ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស**

*ការអភិវឌ្ឍវិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកទេស និងបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ*
*ការលើកកម្ពស់សុខភាពប្រជាជន*

**ការពង្រឹងភាពជាដៃគូក្នុងការអភិវឌ្ឍ**

*ការពង្រឹងវិស័យឯកជនជំរុញវិនិយោគ និងធុរកិច្ច*
*ការអភិវឌ្ឍឧស្សាហកម្ម សិប្បកម្ម និងសហគ្រាសធុនតូចនិងមធ្យម*
*ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងធនាគារ*

**ការអភិវឌ្ឍវិស័យកសិកម្ម អភិវឌ្ឍន៍ជនបទ ពាណិជ្ជកម្ម ការគ្រប់គ្រងដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន**

*ការអភិវឌ្ឍវិស័យកសិកម្ម*
*ការអភិវឌ្ឍជនបទ*
*ការជំរុញពាណិជ្ជកម្ម*
*ការគ្រប់គ្រងដីធ្លី និងសំណង់*
*ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន*

**ការអភិវឌ្ឍទេសចរណ៍ វប្បធម៌ និងសាសនា**

*ការអភិវឌ្ឍទេសចរណ៍*
*ការអភិរក្ស និងអភិវឌ្ឍន៍ វប្បធម៌*
*ការអភិវឌ្ឍវិស័យសាសនា*

**ការអភិវឌ្ឍការងារ និងការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម**

*ការអភិវឌ្ឍការងារ និងមុខរបរ*
*ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម*

**ការលើកកម្ពស់ស្ថានភាពស្ត្រី និងកុមារ ការអភិវឌ្ឍយុវជន និងកីឡា**

*ការលើកកម្ពស់ស្ថានភាពស្ត្រី និងកុមារ*
*ការអភិវឌ្ឍយុវជន និងកីឡា*

## ២.៧-ការការពារជាតិ ការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម

**ការការពារជាតិ ការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គម**

**ការការពារជាតិ ការពារបូរណភាពទឹកដី** គឺជាកាតព្វកិច្ចរបស់ពលរដ្ឋកម្ពុជាគ្រប់រូប ដោយមានកងយោធពលខេមរភូមិន្ទធ្វើជាស្នូល

**រក្សាសន្តិសុខផ្ទៃក្នុង** ប្រឆាំងដាច់ខាតបដិវត្តន៍ពណ៌, លើកកម្ពស់សន្តិសុខ សុវត្ថិភាពសង្គម, រៀបចំសណ្តាប់ធ្នាប់ និងសណ្តាប់ធ្នាប់ចរាចរណ៍ និងធានាការផ្តល់សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណ ឯកសារអត្រានុកូលដ្ឋាន, ពង្រឹងការអនុវត្តច្បាប់ស្តីពីអន្តោប្រវេសន៍ និងលើកកម្ពស់សមត្ថភាពកម្លាំងនគរបាលគ្រប់ជំនាញ គ្រប់ថ្នាក់

បន្តជំរុញ**ការកែទម្រង់កងយោធពលខេមរភូមិន្ទ**, ពង្រឹងកិច្ចការពារអធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាលើដែនដីគោក ដែនអាកាស ដែនទឹក កោះ ឆ្នេរ ដែនសមុទ្រ តំបន់តភ្ជាប់ តំបន់សេដ្ឋកិច្ចផ្តាច់មុខ និងខ្ពង់រាបបាតសមុទ្រ និងលើកកម្ពស់សមត្ថភាពរបស់កងទ័ព

កសាងឱ្យបាន**ចលនាសន្តិសុខមាតុភូមិ** "មាតុភូមិខ្ញុំ សុវត្ថិភាពខ្ញុំ" តាមរយៈការបន្តអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព, បន្តជំរុញអនុវត្តគោលនយោបាយសុខដុមនីយកម្មសង្គម

បន្តធ្វើ**ទំនើបកម្មកងយោធពលខេមរភូមិន្ទ** និង**បង្កើនការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យការពារជាតិ**, បង្កើនកិច្ចសហប្រតិបត្តិការរវាងកងយោធពលខេមរភូមិន្ទនិងកងទ័ពនៃប្រទេសជិតខាងភូមិផងរបងជាមួយ

## ២.៨-ការពង្រឹងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេស ជំរុញសមាហរណកម្មកម្ពុជាក្នុងតំបន់ និងពិភពលោក

ការពង្រឹងពង្រីក**ចំណងមិត្តភាព** និង**កិច្ចសហប្រតិបត្តិការ**ជាមួយបណ្តាប្រទេស ជំរុញសមាហរណកម្មកម្ពុជាក្នុងតំបន់ និងពិភពលោក

ពង្រឹងពង្រីកទំនាក់ទំនង និង**កិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ** តាមរយៈយន្តការទ្វេភាគី និងពហុភាគីក្នុងតំបន់ និងពិភពលោក

**បន្តបញ្ជូនកងកម្លាំងរក្សាសន្តិភាពកម្ពុជាចូលរួមយ៉ាងសកម្មក្នុងការការពារ និងថែរក្សាសន្តិភាព**, បន្តធ្វើការកែទម្រង់នយោបាយការទូតប្រពៃណីនិងបង្កើនការប្រុងប្រយ័ត្នខ្ពស់ចំពោះការប៉ុនប៉ងអនុវត្តបដិវត្តន៍ពណ៌របស់មជ្ឈដ្ឋានខាងក្រៅសំដៅផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់

**បន្តចូលរួមយ៉ាងសកម្មជាមួយប្រទេសនានាទាំងអស់ក្នុងតំបន់ និងពិភពលោក**ក្នុងការរិះរកដំណោះស្រាយបញ្ហាប្រឈមដែលពិភពលោកជួបប្រទះដូចជា ការប្រែប្រួលអាកាសធាតុ ភេរវកម្ម សន្តិសុខស្បៀង គ្រោះមហន្តរាយ ជម្ងឺឆ្លង ។ល។

**ពង្រឹងកិច្ចសហការជាមួយប្រទេសជិតខាង**លើការពន្លឿនការកំណត់ខណ្ឌសីមា និងការបោះបង្គោលព្រំដែន, បន្តប្រកាន់ជំហរអព្យាក្រឹត, ប្រកាន់ខ្ជាប់ "**នយោបាយចិនតែមួយ**"

បន្តសហការយ៉ាងសកម្មជាមួយប្រទេសសមាជិកអាស៊ានស្របតាម "**ទស្សនវិស័យតែមួយ អត្តសញ្ញាណតែមួយ សហគមន៍តែមួយ**"

កម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជាសម្រាប់ការកសាង និងការពារមាតុភូមិ ឆ្នាំ២០១៨-២០២៣ ត្រូវបានកសាងឡើងដោយផ្អែកលើមូលដ្ឋានសមិទ្ធផលដ៏ថ្លៃថ្លានៃសង្គមជាតិរយៈពេល ៣៩ ឆ្នាំកន្លងមក និងបំណងប្រាថ្នាដ៏ឧត្តុង្គឧត្តមរបស់ប្រជាជនកម្ពុជា ព្រមទាំងការវិវត្តន៍នៃសភាពការណ៍ជាតិ និងសភាពការណ៍អន្តរជាតិនៅដំណាក់កាលបច្ចុប្បន្ន ហើយត្រូវបានមហាសន្និបាតវិសាមញ្ញតំណាងទូទាំងប្រទេសអនុម័តនៅថ្ងៃទី ២១ ខែមករា ឆ្នាំ២០១៨។

គណបក្សប្រជាជនកម្ពុជា សូមអំពាវនាវដល់ជនរួមជាតិនៅគ្រប់ទិសទី និងមជ្ឈដ្ឋានទាំងអស់ក្នុងសង្គម សូមផ្តល់ការគាំទ្រ និងចូលរួមអនុវត្តកម្មវិធីនយោបាយនេះប្រកបដោយភាពជឿជាក់ ដើម្បីរួមគ្នាបង្កើតឡើងសមិទ្ធផលថ្មីៗទៀតលើគ្រប់វិស័យ កាន់តែធំធេងឡើងក្នុងបុព្វហេតុកសាង និងការពារមាតុភូមិយើងឆ្ពោះទៅរកអនាគតដ៏ត្រចះត្រចង់។

# ៣. គោលការណ៍គ្រឹះនៃកម្មវិធីនយោបាយរបស់គណបក្ស

ដើម្បីសម្រេចជោគជ័យក្នុងការកសាង និងការពារមាតុភូមិ នៅក្នុងនីតិកាលទី៥ នៃរដ្ឋសភា គណបក្សប្រជាជនកម្ពុជា មានគោលការណ៍ ១១ ចំណុចគឺ÷



# ផ្នែកទី៣. យុទ្ធសាស្ត្រ

## ១. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣

### ក. សាវតារ

រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តប្រកបដោយជោគជ័យនូវ **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ និងទី២**។ សមិទ្ធផលនៃកិច្ចអភិវឌ្ឍរបស់កម្ពុជា ក្នុងរយៈពេលមួយទសវត្សកន្លងទៅនេះ គឺជាសក្ខីភាពនៃការឈានឡើងរបស់កម្ពុជាឆ្ពោះទៅរកសន្តិភាពយូរអង្វែង និងការអភិវឌ្ឍ ប្រកបដោយចីរភាព ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈកំណើនសេដ្ឋកិច្ច គួរឱ្យកត់សម្គាល់ និងការពង្រឹងស្ថាប័នប្រជាធិបតេយ្យ, ការធានាបាននូវអធិបតេយ្យភាពជាតិ និងបូរណភាពទឹកដី ព្រមទាំងការកែលម្អជីវភាពប្រជាពលរដ្ឋ។ វឌ្ឍនភាពនេះ ក៏បានបង្ហាញឱ្យឃើញផងដែរ អំពីការសម្រេចបាននូវបំណងប្រាថ្នារបស់រាជរដ្ឋាភិបាលរបស់រាជរដ្ឋាភិបាលកម្ពុជាថា "**មុនដំណាច់ទសវត្សរ៍ទីមួយនៃសតវត្សទី ២១ នេះ ប្រទេសកម្ពុជាមានបំណងនឹងជណ្តើមកាន់កាប់នូវជោគវាសនារបស់ខ្លួនឡើងវិញឱ្យបានពេញលេញ ហើយក្លាយខ្លួនជាដៃគូពិតប្រាកដ ក្នុងកិច្ចការតំបន់ និងពិភពលោក ព្រមទាំងក្លាយខ្លួនជាប្រជាជាតិដែលមានសេរីភាពពិតប្រាកដ និងរួចចាកពីភាពក្រីក្រ**"។

កម្ពុជាសម្រេចបាននូវសមិទ្ធផលសំខាន់ជាច្រើន ទាំងនយោបាយ, សន្តិសុខ, សណ្តាប់ធ្នាប់សង្គម ទាំងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដែលជាបុរេលក្ខខណ្ឌ សម្រាប់ដំណើការផ្លាស់ប្តូរស៊ីជម្រៅ ក្នុងគ្រប់ទិដ្ឋភាពនៃសង្គម-សេដ្ឋកិច្ចកម្ពុជា ទោះបីជាត្រូវប្រឈមនឹងវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ, ការធ្លាក់ចុះសេដ្ឋកិច្ចសកលលោក, ការគំរាមលើអធិបតេយ្យជាតិ និងបូរណភាពទឹកដី ព្រមទាំងគ្រោះធម្មជាតិផ្ទួនក៏ដោយ។ សមិទ្ធផលដ៏ធំធេងនេះ សម្រេចបានមកតាមរយៈការអនុវត្តនយោបាយ "**ឈ្នះ-ឈ្នះ**" ដែលឈរលើមូលដ្ឋាននៃស្មារតីមហាសាមគ្គីជាតិ និងឯកភាពជាតិក្នុងគោលដៅបង្រួបបង្រួមកម្លាំងប្រជាជាតិទាំងមូលជាធ្លុងមួយ ក្រោមបាវចនា "**ជាតិ សាសនា ព្រះមហាក្សត្រ**" សម្រាប់

ការស្តារ និងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជា។

ដោយផ្អែកលើបទពិសោធ លទ្ធផលសម្រេចបានក្នុងនីតិកាលទី៤ និង "**កម្មវិធីនយោបាយ**" សម្រាប់នីតិកាលទី៥ របស់ខ្លួន, រាជរដ្ឋាភិបាលយល់ឃើញថា យុទ្ធសាស្រ្តចតុកោណ ពិសេសគោលដៅសម្រាប់ **កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព** នៅតែចាំបាច់ និងសមស្រប សម្រាប់កម្ពុជាបន្តអនុវត្តនៅក្នុងនីតិកាលទី៥ (២០១៣-២០១៨) ដោយរក្សាទុកនូវចតុកោណទាំងបួននៅដដែល ប៉ុន្តែពង្រីកវិសាលភាព និងយន្តការមួយចំនួន ឱ្យកាន់តែសុក្រឹតឡើងថែមទៀត។ យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី ៣ នឹងត្រូវប្រកាសអំពីបេសកកម្ម និង ការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់របស់រាជរដ្ឋាភិបាល ក្នុងការធានាចីរភាពនៃការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ ដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជន និងបរិការណ៍ថ្មីៗ ទាំងកម្រិតជាតិ ទាំងកម្រិតអន្តរជាតិ។ ក្នុងន័យនេះ **កម្មវិធីវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា និងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣** រួមជាមួយគ្នា គឺជាឯកសារក្របខណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយសម្រាប់ការរៀបចំ "**ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ**" ដោយកំណត់សូចនាករ និងពេលវេលាច្បាស់លាស់ សម្រាប់អនុវត្តដែលមានសង្គតិភាពជាមួយនឹងឯកសារគោលនយោបាយតាមវិស័យដ៏ទៃទៀតរបស់រាជរដ្ឋាភិបាល។

### ខ. សមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាលនីតិកាលទី៤ នៃរដ្ឋសភា

ជាក់ស្តែង ក្នុងនីតិកាលទី៤ នៃរដ្ឋសភា កន្លងមកនេះ រាជរដ្ឋាភិបាលបានសម្រេចលទ្ធផលធំៗ ដូចតទៅ÷

**ទី១-** ការបន្តពង្រឹងសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ, សណ្តាប់ធ្នាប់សង្គម និងកិច្ចការដំណើរការនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងការបន្តពង្រឹងគោលការណ៍នីតិរដ្ឋ ជាពិសេសការកសាងក្របខណ្ឌច្បាប់ និងការលើកកម្ពស់ការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព ព្រមទាំងការធានានូវការគោរពសិទ្ធិ, សេរីភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស។

**ទី២-** ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ការគ្រប់គ្រងបាននូវអតិផរណា, ការធានាស្ថិរភាពនៃអត្រាប្តូរ ប្រាក់ និងការពង្រឹងសមត្ថភាពប្រកួតប្រជួងនៃសេដ្ឋកិច្ចជាតិ។

**ទី៣-** ការសម្រេចបានកំណើនសេដ្ឋកិច្ចមធ្យម ៦,៧% ក្នុងមួយឆ្នាំ ដោយមិនគិតឆ្នាំ ២០០៩ ដែលជាឆ្នាំទទួលរងឥទ្ធិពលយ៉ាងខ្លាំងពីវិបត្តិកលិយុគហិរញ្ញវត្ថុ និង ការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោក។

**ទី៤-** ការបន្តពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិសេសតាមរយៈការអនុវត្ត "កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី២" ដោយសម្រេចបានរួមមាន ការរៀបចំ និងអនុវត្តកែលម្អការអនុវត្តចំណាយ ត្រូវបានកែលម្អ,ការបង្កើនការវិនិយោគ ដើម្បីជំរុញកំណើន និងដំឡើងប្រាក់បៀវត្ស។

**ទី៥-** ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ក្នុងនោះផ្លូវជាតិ, ផ្លូវកៅស៊ូ, ប្រព័ន្ធធារាសាស្ត្រ, ថាមពល និងទូរគមនាគមន៍។

**ទី៦-** ការអនុវត្តការកែទម្រង់យ៉ាងស៊ីជម្រៅក្នុងវិស័យព្រៃឈើ និងនេសាទ។

**ទី៧-** ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា ដែលក្នុងនោះ គោលដៅចំនួន ៤ ត្រូវបានសម្រេចរួចមុនកាលបរិច្ឆេទកំណត់ ។

- គោលដៅទី៤÷ ការកាត់បន្ថយអត្រាមរណៈភាពកុមារ
- គោលដៅទី៥÷ ការលើកកម្ពស់សុខភាពមាតា
- គោលដៅទី៦÷ ការប្រយុទ្ធប្រឆាំងមេរោគអេដស៍, ជំងឺអេដស៍, ជំងឺគ្រុនចាញ់ និងជំងឺឆ្លង
- គោលដៅទី៨÷ ការបង្កើនភាពជាដៃគូជាសកលសម្រាប់កិច្ចអភិវឌ្ឍ

រីឯ គោលដៅចំនួន ៤ ផ្សេងទៀត កម្ពុជាអាចសម្រេចបានតាមតាមកាលបរិច្ឆេទកំណត់នៅដំណាច់ឆ្នាំ២០១៥ គោលដៅ ដូចតទៅ÷




ដោយឡែកគោលដៅទី៩ ដែលកម្ពុជា បានដាក់ចេញដោយខ្លួនឯង ក៏សម្រេចបានសម្រេចបានសមិទ្ធផលដ៏ធំធេងផងដែរ ជាអាទិ៍÷ ការថយចុះយ៉ាងខ្លាំងនៃចំនួនអ្នកគ្រោះថ្នាក់ពីជាង ៣០០ ករណី នៅឆ្នាំ២០០៨ មកត្រឹម ១៨៦ ករណីនៅឆ្នាំ២០១២, ផ្ទៃដីដែលត្រូវបានបោសសម្អាតមីន និងសំណល់ជាតិផ្ទុះសង្គ្រាម ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១២ មានទំហំជាង ៥៣០ គីឡូម៉ែតក្រឡា រួមបញ្ចូលទាំងការបញ្ជូនកងកម្លាំងដោះមីនរបស់កម្ពុជាចំនួនជាង ១៤០០ នាក់ ទៅចូលរួមក្នុងកងកម្លាំងរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ និងការទទួលធ្វើជាម្ចាស់ផ្ទះរៀបចំ និងកិច្ចប្រជុំលើកទី១១ នៃរដ្ឋភាគីអនុសញ្ញាអូតាវ៉ា នៅចុងឆ្នាំ២០១១ ផង។ យ៉ាងណាក៏ដោយ ការសម្រេចបាននូវគោលដៅទី ៩ នេះ ទាមទារឱ្យមានការប្រឹងប្រែងបន្ថែមទៀត។

**ទី៨-** ការពង្រឹងភាពជាដៃគូបន្ថែមទៀតជាមួយដៃគូអភិវឌ្ឍន៍ផ្លូវការ, វិស័យឯកជន និងសង្គមស៊ីវិល។

**ទី៩-** ការសម្រេចបាននូវជោគជ័យ ក្នុងការធ្វើសមាហរណកម្មព្រះរាជាណាចក្រ

កម្ពុជា ទៅក្នុងសហគមន៍អន្តរជាតិ ទាំងក្នុងក្របខណ្ឌអនុតំបន់, តំបន់និងក្របខណ្ឌអន្តរជាតិ ក៏ដូចជាធានាបាននូវទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ប្រទេស។

## គ. បញ្ហាប្រឈម និងកាលានុវត្តភាពរបស់កម្ពុជា

ទន្ទឹមនឹងទទួលបានជោគជ័យក្នុងការអនុវត្ត “យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ២” កម្ពុជានៅបន្តជួបនឹងបញ្ហាប្រឈមសំខាន់ៗមួយចំនួន រួមមាន ទី១- ការគំរាមដល់កំណើនសេដ្ឋកិច្ចដោយសារភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោក, ទី២- ការអនុវត្តគោលនយោបាយនៅមានកម្រិត ដោយដុល្លារូបនីយកម្មខ្ពស់នៃសេដ្ឋកិច្ចកម្ពុជា, ទី៣- ភាពមិនទាន់ជឿទុកចិត្តពេញលេញពីសំណាក់មហាជនលើការផ្តល់សេវាសាធារណៈ និងសេវាយុត្តិធម៌, ទី៤- បញ្ហាប្រឈមនៃប្រសិទ្ធភាពនៃសេដ្ឋកិច្ច និងភាពប្រកួតប្រជែងរបស់កម្ពុជាដោយសារតែថ្លៃដឹកជញ្ជូនខ្ពស់ធៀបនឹងប្រទេសជិតខាង និងការតភ្ជាប់ប្រព័ន្ធដឹកជញ្ជូនគ្រប់ប្រភេទនៅមានកម្រិត, ទី៥- ឧបសគ្គសម្រាប់ការប្រកួតប្រជែង និងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាសម្រាប់ការទាក់ទាញការវិនិយោគ និងការលើកកម្ពស់ជីវភាពប្រជាជន ដោយសារថ្លៃអគ្គិសនីនៅមានកម្រិតខ្ពស់ធៀបនឹងប្រទេសជិតខាង និងភាពលទ្ធភាពផ្គត់ផ្គង់ថាមពលអគ្គិសនី, ទី៦- ភាពមិនទាន់ឆ្លើយតបពេញលេញនៃប្រព័ន្ធធារាសាស្ត្រ ទាំងប្រព័ន្ធដែលមានស្រាប់និងវិនិយោគបន្ថែម ទៅនឹងសេចក្តីត្រូវការ, ទី៧- បញ្ហានៃការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងសមត្ថភាពដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការចំពោះមុខ និងសម្រាប់អនាគតរយៈពេលវែង, ទី៨- បញ្ហាប្រឈមនៃការគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិ ដើម្បីធានាឱ្យបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងទី៩- កិច្ចសម្របសម្រួលនិងសមត្ថភាពធនធានមនុស្សនិងស្ថាប័ន ព្រមទាំងការកែទម្រង់រចនាសម្ព័ន្ធផ្ទៃក្នុងនានា ដើម្បីឆ្លើយតបនឹងការផ្លាស់ប្តូរសមាហរណកម្មក្នុងតំបន់ និង សកលលោក។

ជាមួយនេះ បរិការណ៍សកល និងក្នុងប្រទេស នាពេលបច្ចុប្បន្ន បានផ្តល់ឱ្យកម្ពុជា

នូវកាលានុវត្តភាពសំខាន់ៗ ដូចជា ទី១- ការប្រែប្រួលស្ថានភាពភូមិសាស្ត្រ-នយោបាយ និងភូមិសាស្ត្រ-សេដ្ឋកិច្ចក្នុងពិភពលោក នាំឱ្យតំបន់អាស៊ីក្លាយទៅជាគោលដៅវិនិយោគផង និងជាទីផ្សារទំនិញផង ដែលនឹងផ្តល់ឱកាសមាសសម្រាប់ការអភិវឌ្ឍនិងទំនើបកម្មនៃវិស័យឧស្សាហកម្ម ផលិតកម្ម និងសេវា ហើយកម្ពុជាស្ថិតនៅចំកណ្តាលនៃតំបន់នេះ, ទី២- ភាពទាក់ទាញចំពោះការវិនិយោគក្នុងតំបន់អាស៊ានដោយសារតែភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ និងភាពជាដៃគូអន្តរប៉ាស៊ីហ្វិក នឹងផ្តល់ផ្តល់ឱកាសដល់កម្ពុជាក្នុងស្រូបយកការវិនិយោគ និងការពង្រីកទីផ្សារនាំចេញឱ្យកាន់តែធំទូលាយ, ទី៣- កាលានុវត្តភាពសម្រាប់កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចកម្រិតកម្រិតខ្ពស់ ដោយសារតែផលលាភប្រជាសាស្ត្រ និងអត្រាទាបនៃអ្នករស់នៅក្នុងបន្ទុក ព្រមទាំងការកើនឡើងនៃចំនួនប្រជាជនមានចំណូលមធ្យម និងវណ្ណៈកណ្តាល និងទី៤- សក្តានុពលយ៉ាងច្រើន នៅក្នុងគ្រប់ផ្នែក គ្រប់វិស័យ របស់កម្ពុជា ដោយសារការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាបានចាប់ផ្តើមពីមូលដ្ឋានមួយទាប។

## ឃ. យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣

សម័យប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នីតិកាលទី៥ នៃរដ្ឋសភា នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសដាក់ឱ្យអនុវត្ត **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣** ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព។

ការរៀបចំយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ នេះ រាជរដ្ឋាភិបាលក៏បានគិតគូរវែងឆ្ងាយផងដែរ អំពីការវិវត្តប្រែប្រួលនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមកម្ពុជា នៅក្នុងរយៈពេលវែងខាងមុខ។ ដូច្នេះ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ នឹងក្លាយទៅជាមគ្គុទេសក៍ច្បាស់លាស់ សម្រាប់តម្រែតម្រង់សកម្មភាពរបស់គ្រប់តួអង្គអភិវឌ្ឍន៍ទាំងអស់ក្នុងគោលដៅបន្ត និងពង្រឹងកិច្ចអភិវឌ្ឍ ប្រកបដោយចីរភាពសម្រាប់រយៈពេលវែង សំដៅជំរុញកំណើនសេដ្ឋកិច្ច, បន្តបង្កើតការងារធ្វើ, បែងចែកផលនៃកំណើនសេដ្ឋកិច្ចប្រកប

ដោយសមធម៌ និងធានាឱ្យបាននូវប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ និងការគ្រប់គ្រងធនធានគ្រប់ប្រភេទ។ ខ្លឹមសារគន្លឹះនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ ត្រូវបានបកស្រាយ ដូចខាងក្រោម÷

យុទ្ធសាស្ត្រចតុកោណមានគោលដៅជាយុទ្ធសាស្ត្រ ៤ គឺ÷

១. ធានាឱ្យបានកំណើនសេដ្ឋកិច្ចក្នុងអត្រាជាមធ្យមប្រចាំឆ្នាំប្រមាណ ៧% ប្រកបដោយចីរភាព បរិយាប័ន្ន សមធម៌ និងធន់នឹងវិបត្តិ។

២. បង្កើតការងារឱ្យបានកាន់តែច្រើនឡើងជូនដល់ប្រជាជន ពិសេសសម្រាប់ស្រទាប់យុវជន។

៣. សម្រេចឱ្យបានគោលដៅនៃការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង ១% ក្នុង ១ឆ្នាំ ក៏ដូចជាគោលដៅផ្សេងៗទៀត ដែលបានកំណត់ក្នុង “គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា”។

៤. បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឱ្យកាន់តែប្រសើរឡើង។

យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ មានធាតុផ្សំសំខាន់ៗ ដូចខាងក្រោម÷

**ក-បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូល**

- ការបន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ
- ការបន្តធានាបរិស្ថានម៉ាក្រូសេដ្ឋកិច្ចដែលមានលក្ខណៈអនុគ្រោះ និងចីរភាពបរិស្ថាន
- ការបន្តពង្រឹងភាពជាដៃគូក្នុងការអភិវឌ្ឍ
- ការបន្តធ្វើសមាហរណកម្មប្រកបដោយប្រសិទ្ធភាពនៅក្នុងតំបន់ និងពិភពលោក។

បរិស្ថានគ្របដណ្តប់ទាំង ៤ ខាងលើ គឺជាបុរេលក្ខខណ្ឌចាំបាច់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

៣ ផ្នែក

## ខ-អភិបាលកិច្ចល្អជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ

ដើម្បីពង្រឹងអភិបាលកិច្ចល្អ រាជរដ្ឋាភិបាលកម្ពុជាបន្តអនុវត្តការកែទម្រង់ក្នុងវិស័យសំខាន់ៗ រួមមាន៖

- ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ
- ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- ការកែទម្រង់រដ្ឋបាលសាធារណៈ
- ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ។

ការកែទម្រង់ទាំង ៤ ខាងលើនេះ រួមជាមួយការកែទម្រង់ដ៏ទៃទៀត ដូចជា ការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការកែទម្រង់ដីធ្លី ការកែទម្រង់ព្រៃឈើ ការកែទម្រង់ជលផល គឺជាការលើកកម្ពស់សមត្ថភាព និងប្រសិទ្ធភាពការងារ ព្រមទាំងពង្រឹងគុណភាពនៃសេវាសាធារណៈឱ្យកាន់តែប្រសើរឡើង សំដៅបង្កើនជំនឿទុកចិត្ត និងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាជន ព្រមទាំងសហគមន៍ធុរកិច្ច។

## គ-ចតុកោណយុទ្ធសាស្ត្រទាំង ៤

- ចតុកោណទី១ “លើកស្ទួយវិស័យកសិកម្ម” មានមុំចំនួន ៤ ដូចខាងក្រោម៖
  - មុំទី១៖ ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្ម
  - មុំទី២៖ ការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្ម
  - មុំទី៣៖ ការកែទម្រង់ដីធ្លី ការបោសសម្អាតមីន និងកាកសំណល់ជាតិផ្ទុះពីសង្គ្រាម
  - មុំទី៤៖ ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ។
- ចតុកោណទី២ “អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត” មានមុំចំនួន ៤ ដូចខាងក្រោម៖
  - មុំទី១៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធទីក្រុង
  - មុំទី២៖ ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ
  - មុំទី៣៖ ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី
  - មុំទី៤៖ ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ។

- ចតុកោណទី៣ "អភិវឌ្ឍន៍វិស័យឯកជន និងការងារ" មានមុំចំនួន ៤ ដូចខាងក្រោម÷
  - មុំទី១÷ ការអភិវឌ្ឍវិស័យឯកជន និងការជំរុញវិនិយោគ និងធុរកិច្ច
  - មុំទី២÷ ការអភិវឌ្ឍឧស្សាហកម្ម និងសហគ្រាសធនតូច និងមធ្យម
  - មុំទី៣÷ ការអភិវឌ្ឍទីផ្សារការងារ
  - មុំទី៤÷ "ការអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុ" ។
- ចតុកោណទី៤"អភិវឌ្ឍន៍សមត្ថភាព និងធនធានមនុស្ស" មានមុំចំនួន ៤ ដូចខាងក្រោម÷
  - មុំទី១÷ ការពង្រឹង និងការលើកកម្ពស់វិស័យអប់រំវិទ្យាសាស្ត្រ បច្ចេកទេស ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស
  - មុំទី២÷ លើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ
  - មុំទី៣÷ ការអភិវឌ្ឍន៍ប្រសិទ្ធភាពការគាំសង្គម
  - មុំទី៤÷ ការជំរុញអនុវត្តគោលនយោបាយជាតិ ប្រជាជន និងសមភាពយេនឌ័រ។

**ឃ-វិស័យជាអាទិភាពនាំង ៤ ក្នុងដំណើការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម**

ទី១÷ ការអភិវឌ្ឍន៍ធនធានមនុស្ស ដែលនឹងធានាបាននូវការប្រកួតប្រជែងក្នុងទីផ្សារពលកម្មក្នុងតំបន់ ដែលកាន់តែបើកចំហ។

ទី២÷ការបន្តវិនិយោគលើវិស័យហេដ្ឋរចនាសម្ព័ន្ធទូរគមនាគមន៍ និងកែលម្អថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម។

ទី៣÷ការបន្តអភិវឌ្ឍន និងបង្កើនតម្លៃបន្ថែមនៃវិស័យកសិកម្ម។

ទី៤÷ ពង្រឹងអភិបាលលកិច្ច និងសមត្ថភាពនៃស្ថាប័នរដ្ឋ សំដៅបង្កើនប្រសិទ្ធភាពនៃសេវាសាធារណៈ និងកែលម្អបរិយាកាសវិនិយោគ។

| ចក្ខុវិស័យ | |
|---|---|
| ឆ្នាំ២០៣០ | ក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ |
| ឆ្នាំ២០៥០ | ក្លាយជាប្រទេសចំណូលខ្ពស់ |
| បេសកកម្ម | |
| ទីមួយ | ការបន្តដំណើរទៅមុខ, ក្នុងជំនឿដ៏មុតមាំ, សំដៅសម្រេចឱ្យបានពេញលេញនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជានៅឆ្នាំ២០១៥ ព្រមទាំងសម្រេចឱ្យបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប។ |
| ទីពីរ | ការបង្កើតឡើងនូវបុរេលក្ខខណ្ឌចាំបាច់ និងបរិស្ថានអនុគ្រោះ សម្រាប់ដំណើរការផ្លាស់ប្ដូរស៊ីជម្រៅរបស់កម្ពុជា ឆ្ពោះទៅរកដំណាក់កាលអភិវឌ្ឍន៍ថ្មីកាន់តែខ្ពស់ថែមទៀត នៅក្នុងរយៈពេលវែងខាងមុខ។ |




## ខ. សេចក្ដីសន្និដ្ឋាន

ការអនុវត្តប្រកបដោយជោគជ័យនូវ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី១ និងទី២ ក្នុងរយៈពេលមួយទសវត្សកន្លងមកនេះ បាននាំកម្ពុជាឱ្យឈានឡើងទៅកាន់ដំណាក់កាលថ្មីមួយទៀត នៅលើវិថីនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។ សមិទ្ធផលសំខាន់ៗដែលមាន

អត្ថន័យជាប្រវត្តិសាស្ត្រដ៏គួរឱ្យកត់សម្គាល់ទាំងនេះរួមមាន÷

ទី១- ការធានាចីរភាពនៃសន្តិភាព, ស្ថិរភាពនយោបាយ, សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ក៏ដូចជាការលើកស្ទួយនីតិរដ្ឋ, ការលើកកម្ពស់សិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស, ការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស, ការលើកស្ទួយកិត្យានុភាពកម្ពុជាឱ្យខ្ពស់ត្រដែតនៅលើឆាកតំបន់ និងអន្តរជាតិ ព្រមទាំងការការពារបានដោយឥតរវាត នូវអធិបតេយ្យជាតិ និងបូរណភាពទឹកដី។

ទី២- ការសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកដោយចីរភាព ក្នុងអត្រា ៨% ជាមធ្យមក្នុងមួយឆ្នាំក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនៅលើមូលដ្ឋានទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងជាងមុននៅក្នុងបរិការណ៍អត្រាអតិផរណាទាប ក្នុងរង្វង់ ៥% ជាមធ្យមក្នុងមួយឆ្នាំ។

ទី៣- ការកាត់បន្ថយអត្រានៃភាពក្រីក្រ បានលើស ១% ក្នុងមួយឆ្នាំ និងការធានាកែលម្អសូចនាករសំខាន់ៗ ក្នុងវិស័យសង្គមកិច្ច ពិសេស ក្នុងវិស័យអប់រំ, សុខាភិបាល និងសមភាពយេនឌ័រ។

ទី៤- ការបង្កើនវិសាលភាព, ប្រសិទ្ធភាព និងគុណភាពនៃសេវាសាធារណៈ ឱ្យកាន់តែប្រសើរឡើង ហើយទទួលបានការជឿទុកចិត្តកាន់តែខ្លាំងឡើង ពីសំណាក់មហាជន។

លើមូលដ្ឋាននេះ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ នេះ ត្រូវបានរចនាដាក់ចេញមក ដើម្បីឆ្លើយតបទៅនឹងបេសកកម្មជាប្រវត្តិសាស្ត្រដ៏ចម្បងពីរយ៉ាងរបស់ជាតិ គឺ ទីមួយ- ការបន្តដំណើរទៅមុខ, ក្នុងជំនឿដ៏មុតមាំ, សំដៅសម្រេចឱ្យបានពេញលេញ នូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជានៅឆ្នាំ២០១៥ ព្រមទាំងសម្រេចឱ្យបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប, និងទីពីរ- ការបង្កើតឡើងនូវបុរេលក្ខខណ្ឌចាំបាច់ និងបរិស្ថានអនុគ្រោះ សម្រាប់ដំណើរការផ្លាស់ប្តូរស៊ីជម្រៅរបស់កម្ពុជា ឆ្ពោះទៅរកដំណាក់កាលអភិវឌ្ឍនថ្មីកាន់តែខ្ពស់ថែមទៀត នៅក្នុងរយៈពេលវែងខាងមុខ ពោលគឺមហិច្ឆតានៃការប្រែក្លាយខ្លួន ឱ្យទៅជាប្រទេសដែលមាន

ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ ហើយឈានឡើងទៅជាប្រទេសមានចំណូលខ្ពស់ក្នុងឆ្នាំ ២០៥០។

ផ្អែកលើសមិទ្ធផលសម្រេចបានកន្លងមក, ផ្អែកលើសក្តានុពលដ៏ធំធេងរបស់កម្ពុជា, ផ្អែកលើឆន្ទៈដ៏មុះមុត និងទេពកោសល្យរបស់ប្រជាជនកម្ពុជា ព្រមទាំងផ្អែកលើសមត្ថភាពក្នុងការរៀនសូត្រ, ការដកស្រង់នូវបទពិសោធ, ការតម្រឹម, ការបន្សាំ និងការចេះជ្រើសរើសយកវិធានការចាំបាច់របស់រាជរដ្ឋាភិបាល និងរបស់ប្រជាជនកម្ពុជាទាំងមូលរួមជាមួយនឹងយុទ្ធសាស្ត្រដ៏ត្រឹមត្រូវដែលបានដាក់ចេញមកនេះ រាជរដ្ឋាភិបាលមានជំនឿយ៉ាងមុតមាំថា កម្ពុជានឹងជំនះបាននូវរាល់បញ្ហាប្រឈម និងឧបសគ្គទាំងឡាយនេះ នៅលើមាគ៌ាឆ្ពោះទៅកាន់វឌ្ឍនភាព, វិបុលភាព និងភាពថ្កុំថ្កើងរុងរឿង។

គំនូរបំព្រួញស្តីពី "យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី ៣"



# ២. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២

## ក. លទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រចតុកោណក្នុងនីតិកាលទី៣ នៃរដ្ឋសភា

### ១. សមិទ្ធផលសំខាន់ៗរបស់រាជរដ្ឋាភិបាល ក្នុងនីតិកាលទី៣

ក្នុងនីតិកាលទី៣ នៃរដ្ឋសភាកន្លងទៅរាជរដ្ឋាភិបាល សម្រេចបាននូវសមិទ្ធផលធំៗជាច្រើន ជាពិសេសរាជរដ្ឋាភិបាលបានពង្រឹងអភិបាលកិច្ចតាមរយៈកំណែទម្រង់រដ្ឋសំខាន់ៗ គឺកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ព្រមទាំងកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។

រាជរដ្ឋាភិបាលបានពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ព្រមទាំងបានអនុវត្តកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការក្នុងគោលដៅពង្រឹងលទ្ធិប្រជាធិបតេយ្យ និងប្រសិទ្ធភាពនៃសេវាសាធារណៈ នៅតាមមូលដ្ឋាន។ ប្រការនេះបានអនុញ្ញាតឱ្យរាជរដ្ឋាភិបាល ធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងកម្រិតពីរខ្ទង់ដែលមិនធ្លាប់មាន ដោយគ្រប់គ្រងបាននូវអតិផរណានិងធានាស្ថិរភាពជារួមនៃអត្រាប្តូរប្រាក់។

ទន្ទឹមនេះរាជរដ្ឋាភិបាល បានពង្រឹងសមត្ថភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ បង្កើនផលិតភាពនៃវិស័យកសិកម្ម កសាងបាននូវមូលដ្ឋានសេដ្ឋកិច្ចជនបទ ពង្រីកវិស័យឧស្សាហកម្ម និងពង្រីកវិស័យសេវា ឱ្យសម្រេចបាននូវការរីកលូតលាស់យ៉ាងឆាប់រហ័ស ដែលប្រការទាំងអស់នេះ បានបង្កើតការងារ និងជំរុញការបណ្តុះបណ្តាលមុខជំនាញដល់ប្រជាពលរដ្ឋ។

បន្ទាប់ពីបានដាក់ឱ្យអនុវត្ត “កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ” មករាជរដ្ឋាភិបាលសម្រេចបានជាមូលដ្ឋាននូវ “ភាពជឿទុកចិត្តបាននៃថវិកា” តាមរយៈការបង្កើនចំណូល និងវិចារណកម្មចំណាយ ជាពិសេសការបង្កើនទុនវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធសង្គម សេដ្ឋកិច្ច ក្នុងគោលដៅពង្រឹងនិងពង្រីកសេវាសាធារណៈ ព្រមទាំងបានស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ជាតិសំខាន់ៗ។ រាជរដ្ឋាភិបាលក៏

បានពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពធនធានមនុស្ស ដោយប្រមូលផ្តុំលើការអភិវឌ្ឍវិស័យអប់រំ និងសុខាភិបាល។ ជាលទ្ធផលជាក់ស្តែង អត្រាចុះឈ្មោះចូលរៀនបានកើនឡើង អត្រាបោះបង់ចោលការសិក្សា និងអត្រាត្រួតថ្នាក់បានធ្លាក់ចុះ ហើយអត្រាមរណៈរបស់ទារក និងកុមារ និងអត្រាអ្នកផ្ទុកមេរោគហ៊ីវ អេដស៍ ក៏ធ្លាក់ចុះដែរ។

រីឯវិស័យឯកជន បានក្លាយទៅជា "ក្បាលម៉ាស៊ីនពិតប្រាកដនៃកំណើនសេដ្ឋកិច្ច" និងបានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសង្គម សេដ្ឋកិច្ចទាំងក្នុងវិស័យសេដ្ឋកិច្ចរូបវន្ត ទាំងក្នុងវិស័យហិរញ្ញវត្ថុ។ ទន្ទឹមនេះ រាជរដ្ឋាភិបាល ក៏បានពង្រឹងភាពជាដៃគូបន្ថែមទៀតជាមួយភាគីពាក់ព័ន្ធទាំងអស់ពិសេសជាមួយដៃគូអភិវឌ្ឍ វិស័យឯកជន និងសង្គមស៊ីវិលតាមរយៈការដាក់ឱ្យដំណើរការប្រកបដោយប្រសិទ្ធភាពនូវយន្តការនានា សម្រាប់កៀរគរ និងសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការនិងការវិនិយោគ។

## ២. បញ្ហាប្រឈម

ទន្ទឹមនឹងជោគជ័យក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណខាងលើ កម្ពុជាក៏បានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ជាសារវន្ត។ ទោះបីជាមានជោគជ័យគួរជាទីកត់សម្គាល់មួយចំនួនលើការងារកែទម្រង់រដ្ឋសំខាន់ៗក្តី ក៏បញ្ហាប្រឈមនៅតែមាន ជាអាទិ៍គុណភាពប្រសិទ្ធភាព និងការផ្តល់សេវាសាធារណៈ នៅមានកម្រិតមិនទាន់អាចឆ្លើយតបបានទៅនឹងតម្រូវការចាំបាច់ជាក់ស្តែង, ស្ថាប័នតុលាការនៅមិនទាន់អាចទទួលបាននូវជំនឿទុកចិត្តពេញលេញពីសំណាក់មហាជន ការងារកសាងក្របខណ្ឌច្បាប់ និងអនុវត្តច្បាប់នៅមានកម្រិត។

មូលដ្ឋាននៃកំណើនសេដ្ឋកិច្ចនៅតូចចង្អៀត ដែលពឹងផ្អែកជាសំខាន់លើសសរទ្រូងបួនគឺវិស័យកាត់ដេរ ទេសចរណ៍ សំណង់ និងកសិកម្ម។ វិស័យកាត់ដេរនិងទេសចរណ៍ងាយរងនូវហានិភ័យពីខាងក្រៅ។ វិស័យកសិកម្មជាមូលដ្ឋានបង្កើតការងារសម្រាប់ប្រជាជនជាង ៦០% មិនទាន់ត្រូវបានប្រើប្រាស់ឱ្យអស់នូវសក្តានុពលនៅឡើយ។

បាតុភូតនៃការប្រែប្រួលអាកាសធាតុ អតុល្យភាពនៃសេដ្ឋកិច្ចពិភពលោក និងវិបត្តិ

ហិរញ្ញវត្ថុ បានបណ្តាលឱ្យមានការធ្លាក់ចុះនៃសេដ្ឋកិច្ចពិភពលោក ដែលបានដាក់មកលើសេដ្ឋកិច្ចកម្ពុជានូវសម្ពាធអតិផរណាដ៏ធ្ងន់ធ្ងរក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ។

តាមការប៉ាន់ស្មានបឋម អត្រានៃភាពក្រីក្រអាចចុះមកនៅត្រឹមប្រមាណ ៣២% នៅឆ្នាំ២០០៧ នេះ ពី៣៥% នៅឆ្នាំ២០០៤ ក៏ដោយ ក៏អត្រានេះ នៅមានកម្រិតខ្ពស់នៅឡើយ ហើយការប្រមូលផ្តុំដីធ្លី និងចំនួនពលរដ្ឋដែលគ្មានដីមាននិន្នាការកើនឡើងដែលជាប្រការដាក់នូវបញ្ហាប្រឈមចំពោះសមធម៌និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ដីធ្លី។

ភាពអនាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ ការរំលោភយកដីរដ្ឋ ការកាប់ទន្ទ្រានដីព្រៃក្នុងតំបន់ការពារធម្មជាតិ និងការកាប់ឈើដោយខុសច្បាប់ នៅតែមានជាអន្លើៗ។

អគ្គិសនីនៅមានថ្លៃខ្ពស់ធៀបនឹងប្រទេសជិតខាង ដែលជាឧបសគ្គដ៏ធំមួយ សម្រាប់ពង្រឹងភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា ក៏ដូចជាសម្រាប់ទាក់ទាញការវិនិយោគ និងលើកកម្ពស់ជីវភាពរបស់ប្រជាជន។ ប្រព័ន្ធធារាសាស្ត្រមិនទាន់ត្រូវបានអភិវឌ្ឍគ្រប់គ្រាន់តាមសេចក្តីត្រូវការនិងមិនទាន់ត្រូវបានប្រើប្រាស់ឱ្យអស់សក្តានុពលនៅឡើយ។

គុណភាពអប់រំនៅមានកម្រិតទាប ទាំងនៅកម្រិតបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា។ រីឯការផ្តល់សេវាសុខាភិបាលសាធារណៈ ប្រកបដោយគុណភាព នៅមានកម្រិតនៅឡើយ ដោយអត្រាមរណៈមាតានៅមានកម្រិតខ្ពស់។

ជារួមសមត្ថភាពស្ថាប័នរបស់យើង នៅមានកម្រិតនៅឡើយដោយសារប្រាក់បៀវត្សនិងការលើកទឹកចិត្តរបស់មន្ត្រីរាជការនៅទាប កិច្ចសហប្រតិបត្តិការអន្តរស្ថាប័ននៅមានកម្រិត លិខិតបទដ្ឋានមួយចំនួន នៅមានចន្លោះប្រហោង និងកង្វះខាតធនធាន ដើម្បីអនុវត្តគោលនយោបាយដែលបានដាក់ចេញ។

## ខ. ខ្លឹមសារនៃយុទ្ធសាស្ត្រចតុកោណ




យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ នេះ រក្សារចនាសម្ព័ន្ធដើម នៃដំណាក់កាលទី១ នៃយុទ្ធសាស្ត្រនេះ ដោយគ្រាន់តែសម្រិតសម្រាំង និងសម្រួចបន្ថែមនូវអាទិភាពគោលនយោបាយ ស្របតាមសេចក្តីត្រូវការជាក់ស្តែងទាំងឡាយ។ ជារួម យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ ត្រូវបានរៀបចំឡើងទៅតាមរចនាសម្ព័ន្ធជាមុំបួន នៃចតុ-កោណដែលប្រទាក់ក្រឡាគ្នា ហើយផ្សារភ្ជាប់គ្នានៅគ្រប់ជ្រុងជ្រោយទាំងអស់ ដោយមានសមាសធាតុ ដូចតទៅ÷

១. **ស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺអភិបាលកិច្ចល្អ** ដែលជាបុរេលក្ខខណ្ឌ

សំខាន់បំផុតមួយ ដើម្បីធានាឱ្យមានការអភិវឌ្ឍសង្គម សេដ្ឋកិច្ចប្រកបដោយចីរភាព សមធម៌ និងយុត្តិធម៌ក្នុងសង្គម។ ក្នុងដំណាក់កាលទី២នេះ ការកែទម្រង់អភិបាលកិច្ចនៃរាជរដ្ឋាភិបាល ផ្តោតការយកចិត្តទុកដាក់លើកំណែទម្រង់បួនយ៉ាង គឺ÷

**ទី១. ការប្រយុទ្ធប្រឆាំងអំពើពុករលួយ÷** ការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅតែជារបៀបវារៈអាទិភាពដ៏សំខាន់ នៃបញ្ជីរបៀបវារៈរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៤ នៃរដ្ឋសភានេះ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនៅតែប្តេជ្ញាចិត្តមោះមុតក្នុងការរៀបចំ និងជំរុញអនុម័តច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងអំពើពុករលួយ ដែលជាមួយដ្ឋានគតិយុត្តគន្លឹះមួយមិនអាចខ្វះបាន សម្រាប់ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនេះ រាជរដ្ឋាភិបាល នឹងបន្តអនុវត្តវិធានការមុតស្រួចជាយុទ្ធសាស្ត្រជាក់ស្តែង សម្រាប់ដោះស្រាយបញ្ហាពុករលួយ គឺ ការបង្ការទប់ស្កាត់ជាមុន តាមរយៈការអប់រំនិងផ្សព្វផ្សាយ, ការអនុវត្តឱ្យមានប្រសិទ្ធភាពនូវគោលការណ៍បញ្ចៀសទំនាស់ផលប្រយោជន៍រវាងឯកជន, ការលើកម្ពស់និងជំរុញការគាំទ្រ និងការចូលរួមពីសាធារណ-ជនក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយ តាមរយៈការលើកកម្ពស់នូវការការពារសេរីភាពនៃការស្វែងរក ទទួល និងផ្សព្វផ្សាយក្នុងបណ្តាញព័ត៌មាននូវករណីពាក់ព័ន្ធអំពើពុករលួយ, ការជំរុញអនុវត្តគោលនយោបាយនិងក្របខណ្ឌច្បាប់ សម្រាប់ការពារសុចរិតភាពនៃវិស័យឯកជន ដើម្បីបញ្ចៀសការឃុបឃិត ក្នុងការប្រព្រឹត្តអំពើពុករលួយ និងការពង្រឹងអនុវត្តច្បាប់ម៉ឺងម៉ាត់ ចំពោះជនស្មើសដែលប្រព្រឹត្តអំពើពុករលួយ។

**ទី២. កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌÷** ការពង្រឹងសមត្ថភាព ឯករាជ្យ និងអព្យាក្រឹតភាព នៃស្ថាប័នតុលាការ គឺជាកត្តាសំខាន់ ក្នុងដំណើរការពង្រឹងនីតិរដ្ឋ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ខ្ពស់ថែមទៀតក្នុងការបន្តនិងជំរុញអនុម័តច្បាប់គោលសំខាន់ៗ ដូចជាក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គការតុលាការ និងច្បាប់ស្តីពីវិសោធន-កម្មច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងបន្តផ្តល់

អាទិភាពបន្ថែមទៀតលើ ការពង្រឹងសមត្ថភាពរបស់ចៅក្រមនិងព្រះរាជអាជ្ញា តាមរយៈការបណ្តុះបណ្តាលបន្ត និងការបណ្តុះបណ្តាលដំបូង, ការកសាងនូវយន្តការផ្សេងៗ ដែលចូលរួមបម្រើឱ្យវិស័យយុត្តិធម៌រួមមានលក្ខន្តិកៈក្រឡាបញ្ជី សារការី និងអាជ្ញាសាលា ព្រមទាំងបង្កើតឱ្យមានសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ត្រីជំនួយឱ្យវិស័យយុត្តិធម៌ទាំងនេះ, ការផ្តល់ជំនួយផ្នែកច្បាប់ ជាពិសេសតាមរយៈការផ្តល់ជំនួយមេធាវីដល់ជនក្រីក្រ និងការបន្តជំរុញលើកកម្ពស់យន្តការនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

**ទី៣. កំណែទម្រង់រដ្ឋបាលសាធារណៈ÷** ក្នុងគោលដៅពង្រឹងសេវាសាធារណៈឱ្យមានប្រសិទ្ធភាព តម្លាភាព និងការទទួលខុសត្រូវខ្ពស់ ដាក់ឱ្យដំណើរការកំណែទម្រង់រដ្ឋបាលសាធារណៈ រួមទាំងកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការផង។ ក្នុងស្មារតីនេះរាជរដ្ឋាភិបាលនឹងបន្តអនុវត្តគោលនយោបាយបង្កើនប្រាក់បៀវត្សមូលដ្ឋានចំនួន ២០% ក្នុងមួយឆ្នាំ, ការពង្រឹងការគ្រប់គ្រងនិងអធិវឌ្ឍសមត្ថភាពមន្ត្រីរាជការ, ការពង្រឹងសេវាសាធារណៈជាមូលដ្ឋាន សេវាពាក់ព័ន្ធការវិនិយោគ និងពាណិជ្ជកម្មធុនតូចនិងមធ្យម តាមរយៈការបន្តពង្រឹងយន្តការ "ច្រកចេញ ចូលតែមួយ" និងការបង្កើតការិយាល័យប្រជាពលរដ្ឋ។ រាជរដ្ឋាភិបាល នឹងបន្តជំរុញអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈការរៀបចំបទដ្ឋានគតិយុត្ត និងវិធានការថ្មីបន្ថែមទៀត ដើម្បីអនុវត្តឱ្យមានប្រសិទ្ធភាពនូវ "ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ" និងជាពិសេសការរៀបចំនិងអនុវត្តលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធការផ្ទេរអំណាចពីរដ្ឋបាលថ្នាក់ជាតិ មករដ្ឋបានថ្នាក់ក្រោមជាតិ។ ទន្ទឹមនេះ ការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបវិសហមជ្ឈការ នឹងត្រូវអនុវត្តដោយភាពទន់ភ្លន់ និងតាមដំណាក់ៗ ក្នុងរយៈពេលមធ្យម ដើម្បីមានពេលគ្រប់គ្រាន់ក្នុងការកសាងសមត្ថភាពថ្នាក់ក្រោមជាតិ សម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារនៈ។

**ទី៤. កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ÷** ក្នុងនីតិកាលទី៤ នេះ នឹងផ្តោតលើការបន្តពង្រឹងកងកម្លាំងប្រដាប់អាវុធ ឱ្យក្លាយជាកងកម្លាំងមានវិជ្ជាជីវៈជំនាញ, ការបន្ត

ជំរុញឱ្យបានកាន់តែប្រសើរថែមទៀត នូវកិច្ចសហប្រតិបត្តិការក្នុងចំណោមកងកម្លាំងប្រដាប់អាវុធ និងរវាងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ព្រមទាំងកិច្ចសហប្រតិបត្តិការជាមួយសហគមន៍អន្តរជាតិ ពិសេសដើម្បីបង្ការទប់ស្កាត់និងបង្ក្រាបអំពើភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ, ការជំរុញកសាងផែនការយុទ្ធសាស្ត្រសម្រាប់កងកម្លាំងនគរបាលជាតិ សំដៅពង្រឹងប្រសិទ្ធភាពដឹកនាំ និងក្នុងការគ្រប់គ្រងនិងប្រើប្រាស់ធនធាន។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងជំរុញកសាងច្បាប់ស្តីពីនគរបាលជាតិ ដែលជាច្បាប់គោលមួយកំណត់អំពីសិទ្ធិ កាតព្វកិច្ច ករណីកិច្ច និងការទទួលខុសត្រូវរបស់នគរបាលជាតិទាំងមូល។

### ២. បរិស្ថានគ្រប់ដណ្តប់សម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណទាំងមូល៖

**ទី១. សុខសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម៖** ការធានាបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម ជាបុរេលក្ខខណ្ឌ សម្រាប់សម្រេចឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ។ ក្នុងន័យនេះ រាជរដ្ឋាភិបាល នឹងប្រើប្រាស់គ្រប់មធ្យោបាយទាំងអស់ដើម្បីពង្រឹងសន្តិសុខ និងកាត់បន្ថយឱ្យបានច្រើននូវឧក្រិដ្ឋកម្ម និងបទល្មើសផ្សេងៗ ពង្រឹង “នីតិរដ្ឋ” ពង្រឹងការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូរបស់មនុស្ស ក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ដែលផ្តល់នូវកាលានុវត្តភាពប្រកបដោយសមធម៌ជូនប្រជាជនគ្រប់រូប។

**ទី២. សមាហរណកម្មកម្ពុជានៅក្នុងតំបន់និងពិភពលោក៖** ដោយពាណិជ្ជកម្មគឺជាប្រភពសំខាន់នៃកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពលើការបន្តធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងសហគមន៍អន្តរជាតិតាមរយៈការជំរុញការងារចូលជាសមាជិក នៃអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ីប៉ាស៊ីហ្វិក (APEC) និងការចូលរួមកសាងសមគមន៍អាស៊ាន។ រាជរដ្ឋាភិបាល នឹងជំរុញគ្រប់ក្រសួងស្ថាប័ន ទាំងអស់ឱ្យយកចិត្តទុកដាក់ក្នុងការបំពេញកាតព្វកិច្ចនៃសមាជិកភាពរបស់កម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក ទន្ទឹមនឹងការបន្តបើកច្រកឱ្យផលិតផលកម្ពុជាអាច

ឈានចូលដោយគ្មានរបាំង និងឧបសគ្គនានាទៅកាន់ទីផ្សារក្នុងតំបន់ និងក្នុងពិភពលោក។

**ទី៣. ភាពជាដៃគូក្នុងការអភិវឌ្ឍន៍ រួមមានភាពជាដៃគូជាមួយវិស័យឯកជន និងដៃគូអភិវឌ្ឍ ព្រមទាំងភាពជាដៃគូជាមួយនឹងសង្គមស៊ីវិល÷** រាជរដ្ឋាភិបាលនឹងបន្តយន្តការ "វេទិកាកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍកម្ពុជា" និង "វេទិការាជរដ្ឋាភិបាលនិងវិស័យឯកជន" ដែលជាយន្តការសម្រាប់ភាគីពាក់ព័ន្ធទាំងឡាយចូលរួមពិភាក្សារាល់បញ្ហានានាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍ ទាំងវិស័យសាធារណៈ ទាំងវិស័យឯកជន។ រាជរដ្ឋាភិបាលនឹងបន្តជំរុញការបង្កើតនិងអនុវត្តច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល និងសមាគម ព្រមទាំងបន្តលើកទឹកចិត្តអង្គការមិនមែនរដ្ឋាភិបាលនិងសមាគមនានា ដែលត្រូវបានបង្កើតឡើងដោយស្របច្បាប់ ឱ្យចូលរួមកិច្ចដំណើរការស្តារនិងអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចកម្ពុជា។ ទន្ទឹមនេះ រាជរដ្ឋាភិបាល ប្តេជ្ញាអនុវត្ត "ផែនការសកម្មភាពទីក្រុងអាក្រា" ដើម្បីបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍដើម្បីពង្រឹងភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ ភាពជាដៃគូ និងតម្លាភាពជាមួយដៃគូអភិវឌ្ឍទាំងអស់ ព្រមទាំងពង្រឹងការគ្រប់គ្រងដោយផ្តោលើលទ្ធផល។

**ទី៤. បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានលក្ខណៈអនុគ្រោះ÷** រាជ-រដ្ឋាភិបាលនឹងបន្តពុះពារ ដើម្បីសម្រេចឱ្យបាននូវគោលដៅនៃកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប អត្រាប្តូរប្រាក់មានស្ថិរភាព និងមានកំណើនទុនបម្រុងជាប្រចាំ។ រាជរដ្ឋាភិបាលនិងបន្តអនុវត្តគោលនយោបាយរូបិយវត្ថុនិងហិរញ្ញវត្ថុសាធារណៈប្រុងប្រយ័ត្ន។ រាជរដ្ឋាភិបាលនិងបន្តវិនិយោគលើហេដ្ឋារចនសម្ព័ន្ធផ្លូវថ្នល់ប្រព័ន្ធធារាសាស្ត្រ និងបណ្តាញចែកចាយថាមពល ដែលអាចកាត់បន្ថយថ្លៃដើមសេដ្ឋកិច្ចលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច និងប្រសិទ្ធភាពសេដ្ឋកិច្ច។ រាជរដ្ឋាភិបាល និងបង្កើតបរិស្ថានអនុគ្រោះដល់ការវិនិយោគ ទាំងវិស័យសាធារណៈ ទាំងវិស័យឯកជនសម្រាប់ការអភិវឌ្ឍវិស័យសំខាន់ៗ។ ទន្ទឹមនេះ រាជរដ្ឋាភិបាល នឹងបន្តអនុវត្តឱ្យកាន់តែស៊ីជម្រៅថែម

ទៀតនូវ “កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសដំណាក់កាលទី២ នៃកម្មវិធីនេះ ដើម្បីពង្រឹងប្រសិទ្ធភាពថវិកា ដែលជាឧបករណ៍គន្លឹះក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍរបស់រាជរដ្ឋាភិបាល។ រាជរដ្ឋាភិបាលបន្តពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋយ៉ាងហ្មត់ចត់, អនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការពង្រឹងការប្រមូលចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងបន្តពង្រឹងប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព នៃការគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការធ្វើអាជីវកម្មរបស់សហគ្រាសសាធារណៈ តាមរយៈការពង្រឹងសមត្ថភាពគ្រប់គ្រងរបស់ស្ថាប័នអាណាព្យាបាល និងតាមរយៈការជម្រុញរៀបចំផែនការធុរកិច្ច។

### ៣. ចតុកោណយុទ្ធសាស្ត្រទាំងបួន សម្រាប់ជម្រុញកំណើន

ចតុកោណទី១. ការលើកស្ទួយវិស័យកសិកម្ម

ចតុកោណទី២. ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

ចតុកោណទី៣. ការអភិវឌ្ឍផ្នែកឯកជន និងការងារ

ចតុកោណទី៤. ការកសាងសមត្ថភាពនិងការអភិវឌ្ឍន៍ធនធានមនុស្ស។

### ៤. ចតុកោណយុទ្ធសាស្ត្រ នីមួយៗ មាន មុំយុទ្ធសាស្ត្រ បួន គឺ÷

**ចតុកោណទី១. ការលើកស្ទួយវិស័យកសិកម្ម÷** ដោយសារកំណើនសេដ្ឋកិច្ចកម្ពុជានៅមានមូលដ្ឋានតូចចង្អៀត ហើយវិស័យកសិកម្ម នៅតែជាវិស័យ ដែលស្រូបពលកម្មច្រើនជាងគេ គួបផ្សំនឹងការកើនឡើងថ្លៃស្បៀងអាហារនៅលើពិភពលោក ការអភិវឌ្ឍវិស័យកសិកម្ម ដែលជាស្នូលនៃសេដ្ឋកិច្ចជនបទ មានអត្ថន័យពីរយ៉ាង គឺការពង្រីកមូលដ្ឋាន និងរក្សាចីរភាពនៃកំណើនសេដ្ឋកិច្ចផង និងការពន្លឿនការកាត់បន្ថយភាពក្រីក្រផង។

**មុំទី១. ការលើកកំពស់ផលិតភាពនិងពិពិធកម្មវិស័យកសិកម្ម÷** រាជរដ្ឋាភិបាលនឹងបន្តយកចិត្តទុកដាក់លើការពង្រីកសមត្ថភាពផលិតលើផ្ទៃដីដែលមានស្រាប់ តាមរយៈ

ការអភិវឌ្ឍតាមបែប "ប្រពលកម្ម" ក្នុងគោលដៅបង្កើនផលិតកម្ម បង្កើតការងារ បង្កើនប្រាក់ចំណូលនៅជនបទ និងធានានូវសន្តិសុខស្បៀង និងបង្កើនការនាំចេញកសិផល ជាពិសេសការនាំចេញអង្ករ។ រាជរដ្ឋាភិបាល ខិតខំពង្រឹងនិងពង្រីកប្រព័ន្ធសេវាបច្ចេកទេស និងព័ត៌មានកសិកម្ម ដោយជំរុញសេវានេះ ឱ្យទៅដល់ថ្នាក់ស្រុក ដោយផ្សារភ្ជាប់ជាមួយនឹងបណ្តាញអ្នកស្ម័គ្រចិត្តថ្នាក់ឃុំ។ រាជរដ្ឋាភិបាលជំរុញបង្កើបរិយាកាសអនុគ្រោះ កាន់តែប្រសើថែមទៀតសម្រាប់ទាក់ទាញវិនិយោគទុនឯកជន និងសហគមន៍ផងដែរ ចំពោះការចូលរួមវិភាគទាន របស់អង្គការមិនមែនរដ្ឋាភិបាល ដើម្បីធានាឱ្យបាននូវការផ្ទេរចំណេះដឹងនិងបច្ចេកវិទ្យាថ្មីៗដល់កសិករ ក្នុងការដាំដុំ និងចិញ្ចឹមសត្វ។

**មុំទី២. កំណែទម្រង់ដីធ្លី និងការបោសសម្អាតមីន÷** បន្តធ្វើកំណែទម្រង់ដីធ្លីក្នុងក្របខ័ណ្ឌច្បាប់ភូមិបាល និងគោលនយោបាយដីធ្លីដែលមានស្រាប់ និងតាមរយៈការរៀបចំក្របខ័ណ្ឌគតិយុត្តបន្ថែមទៀត ដូចជាច្បាប់អសុរាមិករណ៍ ច្បាប់ស្តីពីសិទ្ធិបុព្វក្រែ ក្រមសំនង់ និងនគរូបនីយកម្ម និងស្តង់ដារជាតិខាងសំណង់។ រាជរដ្ឋាភិបាលនឹងជំរុញការធ្វើបញ្ជីសារពើភ័ណ្ឌអចលនទ្រព្យរបស់រដ្ឋ ព្រមទាំងចុះបញ្ជីជាប្រព័ន្ធឱ្យបានទូលំទូលាយ និងកាន់តែលឿនថែមទៀតដោយអនុវត្ត "ច្រកចេញ ចូលតែមួយ" លើការផ្តល់សេវាចុះបញ្ជី។ រាជរដ្ឋាភិបាលជំរុញការរៀបចំផែនការប្រើប្រាស់ដី ដើម្បីបែងចែកដី សម្រាប់ការអភិវឌ្ឍកសិកម្ម ឧស្សាហកម្ម ទេសចរណ៍ តំបន់ទីក្រុង តំបន់ជនបទ លំនៅដ្ឋាន តំបន់បម្រុងទុក និងតំបន់អភិរក្ស។ រាជរដ្ឋាភិបាលបន្តអនុវត្តគោលនយោបាយមិនយកពន្ធលើដីធ្លីកសិកម្មរបស់កសិករ ដែលបង្កបង្កើនផលជាលក្ខណៈគ្រួសារ។ ទន្ទឹមនេះ ការបោសម្អាតមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនៅតែជាអាទិភាពរបស់រាជរដ្ឋាភិបាល ពិសេសនៅតំបន់ដាច់ស្រយាល តំបន់ដែលកសិករខ្វះដី និងតំបន់មានសក្តានុពលខ្ពស់ក្នុងការអភិវឌ្ឍកសិកម្ម និងហេដ្ឋារចនសម្ព័ន្ធ

**មុំទី៣. កំណែទម្រង់ជលផល÷** រាជរដ្ឋាភិបាលបន្តផ្តល់អាទិភាពលើការរៀបចំសហគមន៍នេសាទ ដោយជំរុញសហគមន៍ជនបទ ដោយជំរុញសហគមន៍ជនបទឱ្យចូលរួម

ក្នុងការរៀបចំផែនការ និងគ្រប់គ្រងធនធានជលផលដោយខ្លួនឯង ដោយមានការតម្រង់ទិសពីសំណាក់រាជរដ្ឋាភិបាល។ រាជរដ្ឋាភិបាលនឹងរៀបចំយន្តការទីផ្សារបច្ចជាតិឱ្យបានល្អ ពីព្រោះតម្លៃត្រីជាចំណូលផង និងជាចំណាយផង សម្រាប់ជនក្រីក្រ។ ការបំផុសវារីវប្បកម្ម គឺជាលក្ខខណ្ឌមិនអាចខ្វះបានក្នុងការថែរក្សាធនធានបច្ចជាតិឱ្យបានគង់វង្ស ដោយរាជ-រដ្ឋាភិបាលនឹងជំរុញផ្តល់ជាកញ្ចប់នូវបច្ចេកទេសពូជ ឥណទាន និងទីផ្សារជូនកសិករ។

**មុំទី៤. កំណែទម្រង់ព្រៃឈើ÷** រាជរដ្ឋាភិបាលនឹងយកចិត្តទុកដាក់បន្តក្នុងការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ និងដាក់វិធានការម៉ឹងម៉ាត់ចំពោះបទល្មើសព្រៃឈើ ព្រមទាំងអប់រំប្រជាពលរដ្ឋឱ្យយល់ពីកាតព្វកិច្ចការពារព្រៃឈើ។ រាជរដ្ឋាភិបាល ក៏នឹងបង្កើនប្រសិទ្ធភាពគ្រប់គ្រងព្រៃបម្រុង ដែលត្រូវទទួលបានការការពារ និងអភិវឌ្ឍន៍សមស្រប ដើម្បីបង្កើតការងារ និងប្រភពចំណូលបន្ថែមជូនប្រជាជន ដូចជាការអភិវឌ្ឍទេសចរណ៍ធម្មជាតិជាដើម។ លើសពីនេះរាជរដ្ឋាភិបាលនឹងប្រមូលធនធានការគាំទ្រនិងហិរញ្ញប្បទាននានា ដើម្បីរួមដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុ។

**ចតុកោណទី២. ការបន្តស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធ÷**

**មុំទី១. ការបន្តស្តារនិងកសាងហេដ្ឋរចនាសម្ព័ន្ធគមនាគមន៍ (ផ្លូវគោល ផ្លូវទឹក និងផ្លូវអាកាស)÷** ក្នុងបរិការណ៍កម្ពុជាបច្ចុប្បន្ន បណ្តាញគមនាគមន៍ មានតួនាទីជា “ក្បាលរថភ្លើងនៃកំណើនសេដ្ឋកិច្ច” និងជាសរសៃឈាម សម្រាប់តភ្ជាប់គ្រប់ច្រកល្ហកនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្លាយជាសរីរាង្គសេដ្ឋកិច្ចមួយ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលមានគោលដៅ បន្តស្តារហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ដោយផ្តោតអាទិភាពខ្ពស់លើការថែទាំផ្លូវជាតិ ការបន្តកសាងផ្លូវខេត្ត និងជនបទ ការស្តារនិងពង្រីកសមត្ថភាពរបស់កំពង់ផែធំៗ និងការស្តារ និងកសាងបណ្តាញអយស្ម័យយាន ដើម្បីភ្ជាប់ជាមួយបណ្តាញអយស្ម័យយាននៃប្រទេសជិតខាង។ រាជរដ្ឋាភិបាលនឹងសម្រេចឱ្យបាននូវការធ្វើឯកជនូប-នីយកម្មនៃកិច្ចប្រតិបត្តិការអាជីវកម្ម នៃរាជាយស្ម័យយានកម្ពុជា ព្រមទាំងនឹងបន្តលើកទឹកចិត្តដល់ការចូលរួមពីវិស័យឯកជន ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធនិងការផ្តល់សេវា

ផ្នែក៣

ដឹកជញ្ជូន។ រាជរដ្ឋាភិបាល នឹងបន្តគោលនយោបាយពង្រីកនិងពង្រឹងសេវាព្រលានយន្តហោះ។ រាជរដ្ឋាភិបាលនឹងជំរុញអនុម័តច្បាប់ស្តីពីផ្លូវថ្នល់ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានផ្សេងៗទៀត សម្រាប់គ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនឱ្យកាន់តែមានប្រសិទ្ធភាព។ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ផងដែរដល់ការងារសុវត្ថិភាពចរាចរ និងមានវិធានការម៉ឺងម៉ាត់ចំពោះបទល្មើសដឹកជញ្ជូនលើសទម្ងន់។

**មុំទី២. ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ÷** រាជរដ្ឋាភិបាលនឹងបន្តផ្តល់អាទិភាពខ្ពស់ដល់ការស្តារ ការកសាង ការថែទាំ និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព នូវហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព ដើម្បីបង្កើនផ្ទៃដីស្រោចស្រព និងជំរុញការងារបង្កបង្កើនផល។ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើការធានាសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលបានទឹកស្អាត តាមរយៈការផ្គត់ផ្គង់ទឹកស្អាតគ្រប់គ្រាន់ជូនប្រជាជនគ្រប់រូប។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងបង្កើនប្រសិទ្ធភាពគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ តាមរយៈការពង្រឹងសមត្ថភាពស្ថាប័នពាក់ព័ន្ធ និងការពង្រឹងភាពជាម្ចាស់របស់ប្រជាជនក្នុងការចូលរួមគ្រប់គ្រងនិងប្រើប្រាស់ តាមបែបវិមជ្ឈការ ដើម្បីដោះស្រាយទឹក សម្រាប់បង្កបង្កើនផលផង សម្រួលដល់ការធ្វើដំណើររបស់ប្រជាជនផង និងអនុវត្តវារីវប្បកម្មផង។

**មុំទី៣. ការអភិវឌ្ឍវិស័យថាមពល÷** រាជរដ្ឋាភិបាល នឹងផ្តល់អាទិភាពក្នុងការបន្តពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ និងបញ្ចុះថ្លៃអគ្គិសនីឱ្យបានសមរម្យ តាមរយៈការបង្កើតរោងចក្រផលិតអគ្គិសនីដែលមានថ្លៃដើមថោកប្រើប្រភពថាមពលក្នុងស្រុក គួបផ្សំនឹងការអភិវឌ្ឍរោងចក្រផលិតអគ្គិសនីដែលប្រើបច្ចេកវិទ្យាទំនើប រួមបញ្ចូលនូវការពិនិត្យលទ្ធភាពប្រើប្រាស់ប្រភពថាមពលនុយក្លេអ៊ែរផង។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងផ្តល់អាទិភាពខ្ពស់ ទៅលើការទាក់ទាញឱ្យមានការចូលរួមរបស់វិស័យឯកជន នៅក្នុងការវិនិយោគអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថាមពល ទាំងការផលិត ការបញ្ជូន និងការចែកចាយ។ ការយកចិត្តទុកដាក់ក៏នឹងត្រូវផ្តោតជាសំខាន់ផងដែរ លើការពង្រឹងយន្តការស្ថាប័ន និង

សមត្ថភាពគ្រប់គ្រង ក្នុងវិស័យថាមពលរួមមាន អាជ្ញាធរអគ្គិសនី និងក្រុមហ៊ុនអគ្គិសនីកម្ពុជា។ រាជរដ្ឋាភិបាលចាត់ទុកធនធានប្រេងនិង ឧស្ម័នកម្ពុជាគឺជាសក្តានុពលថ្មីដ៏សំខាន់សម្រាប់ធានាសន្តិសុខថាមពល និងជាប្រភពដ៏មានតម្លៃក្នុងការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលវែង ដោយរាជរដ្ឋាភិបាលនឹងរៀបចំក្របខណ្ឌគោលនយោបាយ និងក្របខ័ណ្ឌគតិយុត្ត សម្រាប់វិស័យនេះ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការប្រើប្រាស់ធនធាននេះ។

**មុំទី៤. ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានគមនាគមន៍÷** រាជរដ្ឋាភិបាលនឹងបន្តជំរុញអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានគមនាគមន៍ទំនើបទាន់សម័យ ប្រកបដោយគុណភាពខ្ពស់ស្របតាមស្តង់ដារអន្តរជាតិ មានតម្លៃថោកសមរម្យ និងមានសេវាគ្របដណ្តប់ទូទាំងប្រទេស ដោយផ្តោតអាទិភាពលើការជំរុញអនុម័តច្បាប់ស្តីពីទូរគមនាគមន៍, កសាងសមត្ថភាពស្ថាប័នវិស័យនេះ, កែលម្អនិងជំរុញទំនើបកម្មមូលដ្ឋានសម្ភារៈបច្ចេកទេសនៃវិស័យនេះ, លើកស្ទួយការប្រកួតប្រជែងនៅក្នុងទីផ្សារសេវាប្រៃសណីយ៍ និងទូរគមនាគមន៍, បន្តពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងរដ្ឋបាលអេឡិចត្រូនិច និងជំរុញកសាងនិងបង្កើនប្រសិទ្ធភាពនៃហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នង សម្រាប់វិស័យបច្ចេកវិទ្យាព័ត៌មានគមនាគមន៍។

### ចតុកោណទី៣. ការអភិវឌ្ឍផ្នែកឯកជន និងការងារ

**មុំទី១. ការពង្រីកវិស័យឯកជន និងការទាក់ទាញទុនវិនិយោគ** រាជរដ្ឋាភិបាលនឹងបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រីកច្រកចូលទៅកាន់ទីផ្សារអន្តរជាតិ តាមរយៈការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវកាតព្វកិច្ចរបស់ខ្លួន ក្នុងក្របខណ្ឌពាណិជ្ជកម្មអន្តរជាតិ ។ បន្ថែមលើនេះ រាជរដ្ឋាភិបាល នឹងបន្តពង្រឹងក្របខណ្ឌគតិយុត្ត សម្រាប់គាំទ្រវិស័យឯកជន, ការលើកកម្ពស់ផលិតភាពការងារតាមរយៈការបណ្តុះបណ្តាលជំនាញ, ការធានាឱ្យមានការប្រកួតប្រជែងដោយយុត្តិធម៌ ការបន្តជម្រុញកិច្ចសម្រួលពាណិជ្ជកម្ម និងការពង្រឹងយន្តការដោះស្រាយវិវាទឱ្យមានប្រសិទ្ធភាព។ ជាចំណែកមួយដ៏សំខាន់នៃគោលនយោបាយ

ពិពិធភាវូបនីយកម្មមូលដ្ឋានសេដ្ឋកិច្ច រាជរដ្ឋាភិបាល នឹងជំរុញបង្កើតនូវបរិស្ថានអំណោយផល សម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្មកែច្នៃ និងម្ហូបអាហារ វិស័យឧស្សាហកម្មគ្រឿងបង្គុំអេឡិចត្រូនិច និងគ្រឿងម៉ាស៊ីន ដោយរាជរដ្ឋាភិបាលនឹងរៀបចំក្របខណ្ឌគតិយុត្តចាំបាច់ ពិសេសច្បាប់សម្រាប់កិច្ចដំណើរការតំបន់សេដ្ឋកិច្ចពិសេស។

**មុំទី២. ការបង្កើតការងារនិងការធានាលក្ខខណ្ឌការងារល្អប្រសើរ ជូនដល់កម្មករនិងនិយោជិត÷** រាជរដ្ឋាភិបាលនិងបន្តអនុវត្តគោលនយោបាយផ្សារភ្ជាប់ពាណិជ្ជកម្មទៅនឹងលក្ខខណ្ឌការងារ តាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវច្បាប់ការងារនិងអនុសញ្ញាអន្តរជាតិនានា រួមទាំងការពង្រឹងសមត្ថភាពជំនាញតាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យស្របតាមតម្រូវការទីផ្សារ។ រាជរដ្ឋាភិបាលនឹងផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវព័ត៌មានស្តីពីតម្រូវការទីផ្សារការងារដើម្បីធានាបាននូវចល័តភាពនៃពលកម្ម និងការពង្រឹងយន្តការដោះស្រាយវិវាទការងារដែលមានស្រាប់ ដូចជាក្រុមប្រឹក្សាអាជ្ញាកណ្តាល និងគណៈកម្មការដោះស្រាយបាតុកម្មគ្រប់ថ្នាក់។ រាជរដ្ឋាភិបាល នឹងពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ តាមរយៈការអប់រំបណ្តុះបណ្តាល និងការធ្វើអធិការកិច្ចការងារតាមរោងចក្រសហគ្រាស ព្រមទាំងកសាង ច្បាប់ស្តីពីសហជីព និងក្របខ័ណ្ឌគតិយុត្តស្តីពីតុលាការងារ។

**មុំទី៣. ការលើកស្ទួយសហគ្រាសធុនតូចនិងមធ្យម÷** រាជរដ្ឋាភិបាលនឹងបន្តពង្រឹងបរិស្ថានធុរកិច្ច ដោយផ្តោតលើទិដ្ឋភាពសំខាន់បួនគឺការកែក្របខណ្ឌច្បាប់និងនិយ័តកម្មដើម្បីសម្រួលការចុះបញ្ជី, ការជំរុញផ្តល់ហិរញ្ញប្បទានតាមរយៈការបង្កើតក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ និងការពង្រឹងអភិបាលកិច្ចនិងរបាយការណ៍ហិរញ្ញវត្ថុ, ការលើកស្ទួយនវានុវត្តនិងបច្ចេកវិទ្យាដល់សហគ្រាសធុនតូចនិងមធ្យម ព្រមទាំងការបញ្ចូលសហគ្រាសធុនតូចនិងមធ្យមទៅក្នុងខ្សែសង្វាក់តម្លៃជាសកល និងទប់ស្កាត់ការរត់ពន្ធគ្រប់ប្រភេទ។ រាជរដ្ឋាភិបាលនឹងជំរុញការបង្កើតមជ្ឈមណ្ឌលផលិតភាពជាតិ ដើម្បីលើកកម្ពស់ផលិតភាព និងកាត់បន្ថយថ្លៃដើមផលិតកម្ម, បង្កើតវិទ្យាស្ថានស្តង់ដារជាតិដើម្បីធានាបាននូវគុណភាព

ផលិតផល និងការបង្កើតមន្ទីរពិសោធន៍ជាតិ ដើម្បីកំណត់គុណភាពនិងលក្ខណៈវិនិច្ឆ័យផលិតផល។ រាជរដ្ឋាភិបាល បន្តជំរុញចលនា "ភូមិមួយ ផលិតផលមួយ" ដោយបណ្តុះគំនិតច្នៃប្រឌិត សហគ្រិនភាព និងជំនឿលើខ្លួនឯងនៅតាមទីជនបទ។

**មុំទី៤. ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម សម្រាប់មន្ត្រី បុគ្គលិក កម្មករ÷** ក្នុងការបន្តជំរុញអនុវត្តគោលនយោបាយស្តីពីសុវត្ថិភាពសង្គម រាជរដ្ឋាភិបាល នឹងផ្តល់អាទិភាពទៅលើការកែលម្អឱ្យកាន់តែប្រសើរឡើងនូវលក្ខខណ្ឌការងាររបស់កម្មករ និងនិយោជិត, ការជំរុញអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម និងធានាឱ្យនិយោជិតទាំងអស់ទទួលបាននូវការធានារ៉ាប់រងចំពោះគ្រោះថ្នាក់ការងារ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងបន្តជួយគាំទ្រដល់យោធិន និងមន្ត្រីរាជការចូលនិវត្តន៍ តាមរយៈការអនុវត្តប្រព័ន្ធសោធននិវត្តន៍មួយដែលមានវិសាលភាពទូលំទូលាយ ដោយជំរុញអនុម័តច្បាប់ស្តីពីបេឡាជាតិសន្តិសុខសង្គមទូលំទូលាយ និងច្បាប់ស្តីពីការបង្កើតបេឡាជាតិសោធនអតីតយុទ្ធជន។

## ចតុកោណទី៤. ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស

**មុំទី១. ការពង្រឹងគុណភាពវិស័យអប់រំ÷** រាជរដ្ឋាភិបាលនឹងបន្តអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងបន្តយកចិត្តទុកដាក់លើការកែលម្អគុណភាពអប់រំ តាមរយៈការលើកទឹកចិត្តគ្រូបង្រៀន ការកែលម្អកម្មវិធីសិក្សា ការលើកទឹកចិត្តសិស្សពូកែ ការបណ្តុះបណ្តាលគ្រូបង្រៀន ការអនុវត្តគោលនយោបាយពង្រាយគ្រូឱ្យមានប្រសិទ្ធភាព និងការបង្កើតការិយាល័យមន្ទីរពិសោធន៍។ ក្នុងទិសដៅធានាកាលានុវត្តភាពប្រកបដោយសមធម៌ រាជរដ្ឋាភិបាលបន្តបង្កើតអន្តេវាសិកដ្ឋានសម្រាប់សិស្ស និស្សិត និងបន្តសាងសង់សាលារៀនគ្រប់កម្រិតសិក្សា ពិសេសនៅតាមតំបន់ជនបទ និងការបង្កើតអាហារូបករណ៍សម្រាប់សិស្សនិស្សិតក្រីក្រ។ រាជរដ្ឋាភិបាល នឹងបន្តពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន ព្រមទាំងសហគមន៍ជាតិនិងអន្តរជាតិ ដើម្បីបង្កើននិងលើកកម្ពស់គុណភាពសេវាអប់រំ ពិសេសក្នុងកម្រិតមធ្យមសិក្សាបច្ចេកទេស និងឧត្តមសិក្សា រាជរដ្ឋាភិបាល បន្តផ្តោតការយកចិត្តទុកដាក់ទៅលើការបណ្តុះបណ្តាលវិស្វករ និងអ្នកបច្ចេកទេស។ រាជរដ្ឋាភិបាល

ជំពូក៣

នឹងបន្តអនុវត្តគោលនយោបាយបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្សារភ្ជាប់ទៅនឹងទីផ្សារពលកម្ម ដោយសហការយ៉ាងជិតស្និទ្ធជាមួយតួអង្គពាក់ព័ន្ធ ដើម្បីកាត់បន្ថយគម្លាតរវាងការផ្គត់ផ្គង់ និងតម្រូវការការងារ។ រាជរដ្ឋាភិបាល នឹងបន្តបង្កើនចំណាយថវិកា និងកៀរគរហិរញ្ញ-ប្បទានឱ្យបានច្រើនថែមទៀត សម្រាប់គាំទ្រការអប់រំឱ្យកាន់តែមានកម្រិតខ្ពស់ និងប្រកបដោយប្រសិទ្ធភាព។

**មុំទី២. ការលើកកម្ពស់សេវាសុខាភិបាល៖** សុខភាពប្រជាពលរដ្ឋគឺជាកត្តាដ៏ចម្បងសម្រាប់ការអភិវឌ្ឍធនធានមនុស្សនិងវឌ្ឍនភាពសង្គម និងសេដ្ឋកិច្ចប្រកបដោយចិរភាព។ ក្នុងន័យនេះ រាជរដ្ឋាភិបាល ផ្តោតការយកចិត្តទុកដាក់លើការអនុវត្តកម្មវិធីបង្ការ និងព្យាបាលជំងឺឆ្លងនានា កសាងមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពនៅទូទាំងប្រទេស។ រាជរដ្ឋាភិបាល ជំរុញកែលម្អការបែងចែកចំនួនវេជ្ជបណ្ឌិត គ្រូពេទ្យមធ្យម ឆ្មបក្នុងប្រព័ន្ធសុខាភិបាល បង្កើនប្រាក់កម្រៃលើកទឹកចិត្តសម្រាប់បុគ្គលិកសុខាភិបាលនៅទីជនបទ។ រាជរដ្ឋាភិបាល បន្តផ្តោតយកចិត្តទុកដាក់លើការអប់រំនិងផ្សព្វផ្សាយព័ត៌មានសុខាភិបាល និងអានាម័យឱ្យបានទូលាយ ពិសេសដល់ជនបទ។ រាជរដ្ឋាភិបាល នឹងបន្តជំរុញឱ្យសេវាសុខាភិបាលកាន់តែឆ្លើយតប និងខិតកាន់តែជិតសាធារណៈ តាមរយៈការអនុវត្តវិមជ្ឈការលើមុខងារផ្តល់សេវា និងការធ្វើវិមជ្ឈការគ្រប់គ្រងទៅឱ្យថ្នាក់ក្រោមជាតិ ដូចជាមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបន្តលើកកម្ពស់ការចូលរួមរបស់វិស័យឯកជន ដើម្បីបង្កើនការវិនិយោគបន្ថែមទៀត ក្នុងវិស័យសុខាភិបាល និងការពង្រឹងអន្តរាគមន៍សុខភាពសាធារណៈ។

**មុំទី៣. ការអនុវត្តគោលនយោបាយសមភាពយេនឌ័រ៖** រាជរដ្ឋាភិបាលចាត់ទុកស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចនិងសង្គមជាតិ។ រាជរដ្ឋាភិបាលក្នុងនីតិកាលទី៤ នេះ នឹងបន្តអនុវត្តគោលនយោបាយបង្កើនកាលានុវត្តភាពឱ្យសិស្ស និស្សិតនារី បានចូលរួមកាន់តែច្រើន តាមរយៈការបង្កើនអាហារូបករណ៍សម្រាប់សិស្ស និស្សិតនារី ការធានាសុវត្ថិភាពសម្រាប់សិស្ស និស្សិតនារី និងការបង្កើនចំនួនគ្រូបង្រៀនជាស្ត្រី។ រាជរដ្ឋាភិបាល នឹង

បង្កើនសមាមាត្រនៃការចូលរួមរបស់ស្ត្រីឱ្យបានជាអតិបរមា ក្នុងស្ថាប័នជាតិគ្រប់ជាន់ថ្នាក់ ដោយបន្តពង្រីកឱកាសការងារ សម្រាប់ស្រី និងណែនាំបណ្តុះបណ្តាលអំពីរបៀបនៃការតស៊ូមតិ។ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តគោលការណ៍ផ្តល់ឥណទានខ្នាតតូច និងមធ្យមដល់ស្ត្រីនិងសហគមន៍ដើម្បីបង្កើតមុខរបរចិញ្ចឹមជីវិត។ ទន្ទឹមនេះ រាជរដ្ឋាភិបាល នឹងអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដោយមានការចូលរួមសហការពីគ្រប់ស្ថាប័នពាក់ព័ន្ធនិងដៃគូនានា។

**មុំទី៤. ការអនុវត្តគោលនយោបាយជាតិប្រជាជន÷** រាជរដ្ឋាភិបាល នឹងបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីបញ្ចូលគោលនយោបាយជាតិប្រជាជន ទៅក្នុងគោលនយោបាយសង្គម សេដ្ឋកិច្ច និងក្នុងផែនការនិងកម្មវិធីនានា នៅគ្រប់កម្រិតទាំងអស់។ រាជរដ្ឋាភិបាលនឹងបន្តដាក់ចេញនូវវិធានការចាំបាច់ ដើម្បីពង្រឹងគុណភាពប្រជាជនដោយកំណត់យកការអភិវឌ្ឍវិស័យអប់រំ សុខាភិបាល សមភាពយេនឌ័រ និងអភិវឌ្ឍជនបទជាគោលដៅអាទិភាព ដោយវិធានការនេះ នឹងប្រែក្លាយយុវជនក្រោមអាយុ ២៤ ឆ្នាំ ដែលមានប្រមាណ ៦០.៨% នៃប្រជាជនសរុប ជាកម្លាំងចលករដ៏សំខាន់សម្រាប់ការអភិវឌ្ឍលើគ្រប់វិស័យ។ រាជរដ្ឋាភិបាល នឹងពង្រឹងការរៀបចំទីក្រុង និងទីប្រជុំជននានា ឱ្យក្លាយជាទីក្រុងស្អាតគ្មានសំរាម ប្រកបដោយអនាម័យ បរិស្ថានខ្យល់អាកាសបរិសុទ្ធ និងមានទីវាលឧទ្យានបៃតង ទីធ្លាសម្រាប់កីឡាលំហាត់ប្រាណ។

## គ. សេចក្តីសន្និដ្ឋាន

ផ្អែកលើសមិទ្ធផលសម្រេចបានកន្លងមក ផ្អែកលើសក្តានុពលដ៏ធំធេងរបស់កម្ពុជា ផ្អែកលើឆន្ទៈដ៏មោះមុត និងទេពកោសល្យរបស់ប្រជាជនកម្ពុជា រួមយុទ្ធសាស្ត្រដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញមកនេះ រាជរដ្ឋាភិបាលមានជំនឿយ៉ាងមុតមាំថា កម្ពុជានឹងជំនះបាននូវរាល់បញ្ហាប្រឈមនិងឧបសគ្គទាំងឡាយ នៅលើមាគ៌ាឆ្ពោះទៅកាន់វឌ្ឍនភាព។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាល ខិតខំពុំពារឱ្យអស់ពីសមត្ថភាព ដើម្បីសម្រេចបាននូវគោលដៅអាទិភាពក្នុងនីតិកាលទី៤ នេះ ដូចខាងក្រោម÷

ទី១. ការធានាឱ្យបាននូវចីរភាពសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម សំដៅលើកស្ទួយនីតិរដ្ឋ ការពារសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។

ទី២. ធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ក្នុងអត្រាប្រមាណ ៧% ក្នុងមួយឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងជាងមុន។

ទី៣. ការធានាសម្រេចឱ្យបាននូវការកាត់បន្ថយអត្រានៃភាពក្រីក្រ ឱ្យបានលើស ១% ក្នុងមួយឆ្នាំ និងការធានាកែលម្អសូចនាករសំខាន់ៗ ក្នុងវិស័យសង្គមកិច្ច ជាពិសេសវិស័យអប់រំ សុខាភិបាល និងសមភាពយេនឌ័រ។

ទី៤. ការធានាបង្កើនវិសាលភាព ប្រសិទ្ធភាព និងគុណភាពនៃសេវាសាធារណៈ ឱ្យកាន់តែប្រសើរឡើង ហើយទទួលបាននូវការជឿទុកចិត្ត។

# ៣. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១

## ក. សេចក្តីផ្តើម

“**យុទ្ធសាស្ត្រចតុកោណ**” ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព នៅកម្ពុជា ដើរតួនាទីនិងជាឧបករណ៍យ៉ាងសំខាន់ សម្រាប់ទ្រទ្រង់ការអនុវត្ត កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៣ នៃរដ្ឋសភា ដែលស្ថិតក្រោម ការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះ រាជាណាចក្រកម្ពុជា ដ្បិតយុទ្ធសាស្ត្រចតុកោណនេះនឹងធានាបាននូវអាទិភាវូបនីយកម្ម បណ្តាវិស័យអាទិភាពសំខាន់ៗ ដោយផ្តោតសំខាន់ទៅលើរបៀបវារៈគោលនយោបាយ សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ដែលមានលក្ខណៈជាប្រព័ន្ធ ស៊ីសង្វាក់ ប្រទាក់ ក្រឡា យោងគ្នាទៅវិញទៅមក ងាយយល់ និងងាយគ្រប់គ្រង។

“**យុទ្ធសាស្ត្រចតុកោណ**” គឺជាឯកសារកំណត់ជោគវាសនា ចក្ខុវិស័យ និងទិសដៅ របស់ព្រះរាជាណា-ចក្រកម្ពុជា ដែលត្រូវបានអនុម័តនិងដាក់ឱ្យប្រើប្រាស់ដោយរាជ-រដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៣ នៃរដ្ឋសភា និងជាការបន្តពីយុទ្ធសាស្ត្រត្រីកោណ ដែលត្រូវបានដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី២ នៃរដ្ឋសភា កន្លងទៅ។ “**យុទ្ធសាស្ត្រចតុកោណ**” គឺជាកម្មវិធីគោលនយោបាយសម្រាប់រាជរដ្ឋាភិបាល នីតិកាលទី៣ នៃរដ្ឋសភា ដែលឆ្លុះបញ្ចាំងកាន់តែច្បាស់ និងមធ្យ៉តបំផុត ពីឆន្ទៈកំណែ ទម្រង់គ្រប់វិស័យ និងកាន់តែស៊ីជម្រៅរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយឈរលើអភិក្រម **“កំណែទម្រង់ គឺជាកិច្ចការស្លាប់រស់របស់កម្ពុជា”** ដែលស្ថិតក្រោមការដឹកនាំដោយ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

### មាតិកាទី១. ខ្លឹមសារនៃយុទ្ធសាស្ត្រចតុកោណ

### ជំពូកទី១. គោលដៅចម្បងរបស់រាជរដ្ឋាភិបាលនីតិកាលទី៣ នៃរដ្ឋសភា

រាជរដ្ឋាភិបាលនីតិកាលទី៣ នៃរដ្ឋសភា ត្រូវបានបោះឆ្នោតគាំទ្រនិងសម្តែងឆន្ទៈ ដោយប្រជាពលរដ្ឋនៃព្រះរាជណាចក្រកម្ពុជា ដោយធានាបាននូវការបោះឆ្នោតមួយប្រកប

ដោយសេរី យុត្តិធម៌ ត្រឹមត្រូវ មានតម្លាភាព និងអាចទទួលយកបាន កាលពីថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៣។ ក្នុងស្មារតីនៃការផ្តល់ជំនឿទុកចិត្តពីប្រជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលនីតិកាលទី៣ នៃរដ្ឋសភាបានដាក់ចេញនូវ "**យុទ្ធសាស្ត្រចតុកោណ**" ដែលជាឧបករណ៍ទ្រទ្រង់ការអនុវត្ត **"កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៣ នៃរដ្ឋសភា"** ដើម្បីឆ្ពោះទៅសម្រេចឱ្យបាននូវការកាត់បន្ថយភាពក្រីក្រ វឌ្ឍនភាព និងវិបុលភាព ព្រមទាំងភាពសុខដុមរមនា សុភមង្គលជូនប្រជាជនកម្ពុជា និងការអភិវឌ្ឍប្រកបដោយចីរភាព។ "**យុទ្ធសាស្ត្រចតុកោណ**" នឹងធានាជំរុញនិងលើកកម្ពស់កំណើនសេដ្ឋកិច្ច ការដោះស្រាយការងារសម្រាប់ពលករកម្ពុជា ការធានាសមធម៌ និងយុត្តិធម៌សង្គម តាមរយៈផែនការសកម្មភាពអភិបាលកិច្ច និងការធានាប្រសិទ្ធភាពការងាររបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តកម្មវិធីកំណែទម្រង់គ្រប់វិស័យ។

## ជំពូកទី២. អត្ថន័យរបស់យុទ្ធសាស្ត្រចតុកោណ

"**យុទ្ធសាស្ត្រចតុកោណ**" ត្រូវបានបង្កប់នូវខ្លឹមសារនិងអត្ថន័យធំៗ ចំនួនបី គឺ÷

**ទី១.** ជាការបន្តសកម្មភាពនិងពង្រឹងសមិទ្ធផលនានាដែលបានសម្រេចដោយរាជ-រដ្ឋាភិបាលនីតិកាលទី២ តាមរយៈការអនុវត្តយុទ្ធសាស្ត្រត្រីកោណ និងការជ្រើសរើសធាតុចូលសំខាន់ៗពី "គោលដៅអភិវឌ្ឍន៍សហវត្សរ៍", "ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ៥ ឆ្នាំ ២០០១-២០០៥", "យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ២០០៣-២០០៥" និងគោលនយោបាយយុទ្ធសាស្ត្រផែនការ និងកម្មវិធីកំណែទម្រង់សំខាន់ៗជាច្រើនទៀត ក្នុងទិសដៅកែលម្អនិងលើកកម្ពស់អភិបាលកិច្ចល្អ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ចជាតិពោលគឺដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជា-ពលរដ្ឋ។

**ទី២.** "**យុទ្ធសាស្ត្រចតុកោណ**" គឺជាមូលដ្ឋានគ្រឹះនៃកម្មវិធីនយោបាយសេដ្ឋកិច្ច និងជាឧបករណ៍ទ្រទ្រង់យ៉ាងពេញលេញក្នុងការអនុវត្ត **"កម្មវិធីនយោបាយរបស់រាជរដ្ឋា-ភិបាល សម្រាប់នីតិកាលទី៣ នៃរដ្ឋសភា"**។

**ទី៣.** “**យុទ្ធសាស្ត្រចតុកោណ**” នឹងឆ្លុះបង្ហាញពីបណ្តាកញ្ចប់វិស័យអាទិភាពសំខាន់ៗ នានា ដែលមានលក្ខណៈជាប្រព័ន្ធ ស៊ីសង្វាក់ ប្រទាក់ក្រឡាគ្នា និងយោងគ្នាទៅវិញទៅមក។ អភិបាលកិច្ចល្អ គឺជាសសរស្តម្ភគ្រឹះនិងស្នូល នៃយុទ្ធសាស្ត្រចតុកោណ ពោលគឺជាខឿនក្នុងការជំរុញនិងលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាព ជាពិសេសការដោះស្រាយការងារសម្រាប់ពលករកម្ពុជា ការធានាសមធម៌និងយុត្តិធម៌សង្គម និងប្រសិទ្ធភាពនៃវិស័យសាធារណៈ។ តាមរយៈនេះ យើងអាចកំណត់បាវចនានៃការអភិវឌ្ឍរបស់រាជរដ្ឋាភិបាលនីតិកាលទី៣ នៃរដ្ឋសភា នេះថាជា “**រាជរដ្ឋាភិបាល ដើម្បីកំណើន ការងារសមធម៌ និងប្រសិទ្ធភាព**”។

## ជំពូកទី៣. រចនាសម្ព័ន្ធនៃយុទ្ធសាស្ត្រចតុកោណ

យុទ្ធសាស្ត្រចតុកោណនេះ ត្រូវបានរៀបចំឡើងតាមរចនាសម្ព័ន្ធមុំបួននៃនៃចតុកោណប្រទាក់ក្រឡាគ្នា ហើយផ្សាភ្ជាប់គ្នាគ្រប់ជ្រុងទាំងអស់ ដូចមានកំណត់ក្នុងគំនូសបំព្រួញខាងក្រោម៖




ផ្នែក៣

## មាតិកាទី២. អាទិភាពគោលនយោបាយសេដ្ឋកិច្ច

### ជំពូកទី១. ស្នូលនៃយុទ្ធសាស្ត្រចតុកោណ គឺអភិបាលកិច្ចល្អ

អភិបាលកិច្ចល្អ គឺជាបុរេលក្ខណៈវិនិច្ឆ័យសំខាន់បំផុត ដើម្បីធានាឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព សមធម៌និងយុត្តិធម៌សង្គម ដោយរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៣ នៃរដ្ឋសភា បានផ្តោតការយកចិត្តទុកដាក់ ទៅលើកំណែទម្រង់សំខាន់ចំនួនបួន គឺ÷

**ទី១. ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ÷** ដើម្បីសម្រេចបានគោលដៅនេះ រាជរដ្ឋាភិបាលនឹងជំរុញការអនុម័តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងការបង្កើតស្ថាប័នឯករាជ្យអព្យាក្រឹត្យមួយ ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ព្រមទាំងជំរុញការលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសតាមរយៈការពង្រឹងការងារសវនកម្ម និងលទ្ធកម្មសាធារណៈ ក៏ដូចជាជំរុញការអនុវត្តកំណែទម្រង់គ្រប់វិស័យ ដើម្បីធានាអភិបាលកិច្ចល្អ ជាពិសេស គឺការអនុវត្តផែនការសកម្មភាពអភិបាលកិច្ចរបស់រាជរដ្ឋាភិបាល ដែលមានការចូលរួមរៀបចំយ៉ាងទូលំទូលាយ ពីសំណាក់ក្រសួងស្ថាប័នរដ្ឋ សង្គមស៊ីវិល និងដៃគូអ្នកផ្តល់ជំនួយ។

**ទី២. កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌÷** រាជរដ្ឋាភិបាលបានផ្តោតសំខាន់លើការកែលម្អនិងរៀបចំប្រព័ន្ធច្បាប់ និងតុលាការប្រកបដោយឯករាជ្យភាពពិតប្រាកដក្នុងទិសដៅពង្រឹងនីតិរដ្ឋ បង្កើនយុត្តិធម៌នៅក្នុងសង្គម ព្រមទាំងពង្រឹងវប្បធម៌សន្តិភាពនិងវប្បធម៌នៃការគោរពច្បាប់។ តាមរយៈនេះ ច្បាប់មួយចំនួននឹងត្រូវបានរៀបចំសម្រាប់រាជរដ្ឋាភិបាលនីតិកាលទី៣នេះ ជាអាទិ៍ ច្បាប់លក្ខន្តិកៈចៅក្រម ច្បាប់ស្តីពីការរៀបចំអង្គភាពតុលាការ ក្រមព្រហ្មទណ្ឌ នីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងក្រមស្តីពីនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសាកាវិ និងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់រដ្ឋអាជ្ញាសាលា ជាដើម។ អាទិភាពដ៏សំខាន់មួយទៀត គឺការពង្រឹងសមត្ថភាព និងការទទួលខុសត្រូវ របស់ចៅក្រម តាមរយៈការបង្កើតលក្ខន្តិកៈចៅក្រម

ការពង្រឹងវិន័យតាមក្រមសីលធម៌ និងតាមការបណ្តុះបណ្តាលដំបូង និងការបណ្តុះបណ្តាលបន្ត។ ម្យ៉ាងវិញទៀត រាជរដ្ឋាភិបាលនឹងបង្កើតសាលាបណ្តុះបណ្តាលក្រឡាបញ្ជី និងសាលាបណ្តុះបណ្តាលអាជ្ញាសាលា និងសារការី។ ទន្ទឹមនេះ នគរបាលយុត្តិធម៌ នឹងត្រូវបានទទួលការបណ្តុះបណ្តាល និងការគ្រប់គ្រងដោយហ្មត់ចត់។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងយកចិត្តទុកដាក់ខ្ពស់ចំពោះការផ្តល់ជំនួយគតិយុត្តិ ដល់ជនក្រីក្រ ព្រមទាំងលើកកម្ពស់យន្តការដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការជូនប្រជាពលរដ្ឋ ពិសេសចំពោះបញ្ហាដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដី។

**ទី៣. កំណែទម្រង់រដ្ឋបាលសាធារណៈ៖** ការពង្រឹងសមត្ថភាពស្ថាប័ន រដ្ឋបាល និងមុខងារសាធារណៈ គឺជាកិច្ចការចំពោះមុខរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៣ នៃរដ្ឋសភា។ ក្នុងន័យនេះ រដ្ឋបាលនិងមុខងារសាធារណៈ ត្រូវរៀបចំមានលក្ខណៈអព្យាក្រឹត្យ តម្លាភាព អាចឆ្លើយតបទាន់ពេលវេលាទៅនឹងតម្រូវការ ហើយត្រូវមានសមត្ថភាព និងការទទួលខុសត្រូវខ្ពស់ ដោយប្រែក្លាយមុខងារសាធារណៈឱ្យក្លាយទៅជាដៃគូដ៏មានប្រសិទ្ធភាព ក្នុងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល។ តាមរយៈនេះ សេវាសាធារណៈអាទិភាពចំនួន ៤ ត្រូវបានដាក់ចេញ គឺ (១) សេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរបស់រដ្ឋ, (២) សេវាពាក់ព័ន្ធទៅនឹងការវិនិយោគ, (៣) សេវាមូលដ្ឋាន និង (៤) សេវាពាក់ព័ន្ធនឹងចំណូលនិងចំណាយរបស់រដ្ឋ។ ទន្ទឹមនេះ សេវាសាធារណៈ នឹងត្រូវបានសម្រួល និងធ្វើឱ្យមានភាពសាមញ្ញ តាមរយៈការលុបបំបាត់ការងារដែលជាន់គ្នា, ការកាត់បន្ថយការិយាធិបតេយ្យ, ការបង្កើតយន្តការ "ច្រកចេញ-ចូលតែមួយ", ការអនុវត្តគោលនយោបាយវិសហមជ្ឈការ វិមជ្ឈការ និងវិមជ្ឈការថ្នាក់ឃុំ-សង្កាត់ ដ្បិតគោលនយោបាយវិមជ្ឈការថ្នាក់ឃុំ-សង្កាត់ គឺជាសសរគ្រឹះសម្រាប់ពង្រឹងលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន។ ទន្ទឹមនេះ នីតិវិធីនៃការផ្តល់សេវាសាធារណៈទាំងអស់នឹងត្រូវបានបញ្ចូលជាជំហានៗ ទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីពង្រឹង តម្លាភាព និងចូលរួមកាត់បន្ថយអំពើពុករលួយ។ ជាមួយគ្នានេះគោលនយោបាយ ដំឡើងប្រាក់បៀវត្សរ៍ ជូនមន្ត្រីរាជការទូទៅជាជំហានៗ គឺជា

កិច្ចការចម្បងផងដែរ ដោយធានា ឱ្យបានចន្លោះពី១០ ទៅ១៥% ក្នុងមួយឆ្នាំៗ ផងដែរ។

**ទី៤. កំណែទម្រង់កងកំលាំងប្រដាប់អាវុធ÷** ដើម្បីសម្រេចកិច្ចការនេះ រាជរដ្ឋាភិបាលបន្តអនុវត្តគោលនយោបាយដែលបានចែងក្នុងសៀវភៅ **"ស"** របស់កងយោធពលខេមរភូមិន្ទ រួមបញ្ចូលទាំងការចែកដីសម្បទានដើម្បីគោលដៅសង្គមកិច្ចដល់យោធិនរំសាយ ដែលខ្វះខាតដី និងមានបំណងសុំដីសម្រាប់សាងសង់លំនៅដ្ឋាន ឬនិងធ្វើកសិកម្មជាលក្ខណៈគ្រួសារ តាមតម្រូវការសមស្របតាមស្មារតីនៃអនុក្រឹត្យស្តីពីសម្បទានដីសង្គមកិច្ច។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបន្តកំណែទម្រង់កងកម្លាំងនគរបាលជាតិឱ្យទៅជាកងកម្លាំងមានវិជ្ជាជីវៈ មានសមត្ថភាព មានបច្ចេកវិទ្យាទំនើបប្រកបដោយស្មារតីទទួលខុសត្រូវ គោរពប្រតិបត្តិច្បាប់ គោរពសិទ្ធិមនុស្ស បម្រើប្រជាជន ដោយស្មោះត្រង់ សម្រេចបានល្អនូវភារកិច្ចគ្រប់គ្រង និងថែរក្សា សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការពារអាយុជីវិត និងទ្រព្យសម្បត្តិរបស់ប្រជាជន ព្រមទាំងរក្សាបាននូវភាពសុខដុមរមនានៅក្នុងសង្គម។

**ជំពូកទី២. បរិស្ថានគ្រប់ដណ្តប់សំរាប់ការអនុវត្តន៍យុទ្ធសាស្ត្រទាំងមូល**

"**យុទ្ធសាស្ត្រចតុកោណ**" ត្រូវបានគ្រប់ដណ្តប់ដោយការងារស្នូលចំនួន ៤ ក្នុងការអនុវត្តយុទ្ធសាស្ត្រទាំងមូល គឺ÷

**ទី១. សុខសន្តិភាព ស្ថិរភាពនយោបាយ និងសណ្តាប់ធ្នាប់សង្គម÷** សន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម គឺជាមូលដ្ឋានគ្រឹះនៃការងារកសាង និងកំណែទម្រង់រដ្ឋ និងជាលក្ខខណ្ឌមិនអាចខ្វះបានសម្រាប់ការពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ ដែលរាជរដ្ឋាភិបាលនឹងបន្តពង្រឹងថែមទៀត នូវសុខសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម ព្រមទាំងប្តេជ្ញាដោះស្រាយឱ្យអស់នូវផលវិបាកនៃសង្គ្រាមរបបប្រល័យពូជសាសន៍ និងជម្លោះផ្ទៃក្នុងដែលបានបំផ្លិចបំផ្លាញកម្ពុជាក្នុងរយៈពេលជិតបីទសវត្សរ៍ កន្លងទៅនេះ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ផងដែរ លើការបង្កើតនូវជំនឿទុកចិត្តពីសំណាក់វិនិយោគិន និងទេសចរ មកលើកម្ពុជា តាមរយៈការបង្កើតបរិយាកាសល្អនិងអំណោយផលជូនវិនិ-

យោគិន និងទេសចរ។

**ទី២. ភាពជាដៃគូនៅក្នុងការអភិវឌ្ឍ៖** រាជរដ្ឋាភិបាលផ្តល់អាទិភាពយ៉ាងខ្លាំងដល់ការពង្រីកភាពជាដៃគូជាមួយតួអង្គអភិវឌ្ឍ ទាំងអស់ដែលក្នុងនោះរួមមាន ភាពជាដៃគូជាមួយនឹងសហគមន៍អ្នកផ្តល់ជំនួយ វិស័យឯកជន និង សង្គមស៊ីវិល។ ដូច្នេះការពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងផ្នែកឯកជន គឺជាកិច្ចការដ៏ចាំបាច់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ដ្បិតផ្នែកឯកជនជាក្បាលម៉ាស៊ីននៃកំណើន។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹង**"វេទិការាជរដ្ឋាភិបាល និងវិស័យឯកជន"** ឱ្យក្លាយទៅជា យន្តការនៃភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជនប្រកបដោយប្រសិទ្ធភាព ។

ទន្ទឹមនេះ ការបន្តពង្រឹងកិច្ចសហប្រតិបត្តិការរវាងរដ្ឋ និងសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ គឺជាគោលការណ៍គ្រឹះដែលរាជរដ្ឋាភិបាល ប្រកាន់យកដើម្បីធានានិងពង្រឹងលទ្ធិប្រជាធិបតេយ្យ សិទ្ធសេរីភាព សណ្តាប់ធ្នាប់សង្គម និងការគោរពច្បាប់។ ជាការពិតសង្គម ស៊ីវិលត្រូវមានតួនាទីជាដៃគូដ៏មានប្រសិទ្ធភាពរបស់រាជ-រដ្ឋាភិបាល ក្នុងដំណើរការស្តារ និងអភិវឌ្ឍន៍សេដ្ឋកិច្ច- សង្គមកិច្ច និងការគាំពារ លើកស្ទួយការអនុវត្តលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញការបង្កើត និងអនុវត្តច្បាប់ស្តីពីអង្គការ មិនមែនរដ្ឋាភិបាល និងសមាគមដោយមានការពិគ្រោះយោបល់ជាមួយនឹងស្ថាប័ន និងអង្គការពាក់ព័ន្ធ។

**ទី៣. បរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះ៖** រាជ-រដ្ឋាភិបាលនឹងប្រកាន់ខ្ជាប់នូវវិន័យនៅក្នុងការគ្រប់គ្រងថវិកា ព្រមទាំងបន្តពុះពារសម្រេចឱ្យបាន នូវគោលដៅនៃកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងអត្រា៦ ទៅ ៧% ក្នុងមួយឆ្នាំ។ ក្នុងន័យនេះរាជរដ្ឋាភិបាល នឹងបន្តអនុវត្តគោលនយោបាយរូបិយវត្ថុប្រុងប្រយ័ត្ន និងអត្រាប្តូរប្រាក់អណ្តែត ដែលផ្អែកលើមូលដ្ឋាននៃគោលការណ៍ទីផ្សារ។ គោលនយោបាយបដិដុល្លារូប-នីយកម្ម នឹងត្រូវបានអនុវត្តបន្តជាជំហានដ៏ប្រុងប្រយ័ត្ន ស្របទៅតាមសភាពការណ៍វិវត្តន៍នៃសេដ្ឋកិច្ចជាតិនិងអន្តរជាតិ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលប្តេជ្ញាបន្តខិតខំពង្រឹងការប្រមូល

ចំណូលគ្រប់ប្រភេទ ទាំងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ ព្រមទាំងយកចិត្តទុកដាក់បំផុតលើការពង្រឹងសមត្ថភាពរបស់រដ្ឋបាលសារពើពន្ធ និងរដ្ឋបាលមិនមែនសារពើពន្ធ។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងជំរុញអនុវត្តកម្មវិធីកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈការពង្រឹងការគ្រប់គ្រងចំណូលនិងចំណាយ ដោយឈរលើគោលការណ៍តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច ដែលរាល់ប្រតិបត្តិការថវិកាទាំងក្នុងផ្នែកចំណូល និងចំណាយ ត្រូវអនុលោមទៅតាមវិធាននិងនីតិវិធីច្បាប់ជាធរមាន។ ឈរលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលសម្រាប់នីតិកាល ទី៣ នៃរដ្ឋសភា បានដាក់ចេញនូវវិន័យដប់យ៉ាង ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចតទៅ÷

**វិន័យទី១÷** ត្រូវបន្តប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវការមិនអនុញ្ញាតឱ្យមាន "វប្បធម៌រួចពន្ធ និងលើកលែងពន្ធ"។

**វិន័យទី២÷** ត្រូវខិតខំប្រមូលចំណូលគ្រប់ប្រភេទឱ្យបានគ្រប់តាមផែនការ ឬលើសផែនការ។

**វិន័យទី៣÷** ត្រូវបង់ចំណូលដែលប្រមូលបានទាំងអស់ចូលរតនាគារជាតិភ្លាមៗឱ្យបានទាន់ពេល។ ហាមដាច់ខាតរក្សាទុកចំណូលសម្រាប់ចំណាយ នៅក្រៅក្របខ័ណ្ឌថវិកាជាតិ។

**វិន័យទី៤÷** ត្រូវក្លាហាន និងដាច់ខាតក្នុងការប្រយុទ្ធប្រឆាំងអំពើរត់គេចពន្ធគ្រប់ប្រភេទ និងក្នុងការតឹងទារ បំណុលពន្ធ។

**វិន័យទី៥÷** ត្រូវតម្រង់ចំណាយឱ្យចំទិសដៅអាទិភាពនៃការអភិវឌ្ឍ ហើយហ្មត់ចត់ក្នុងការត្បិតត្បៀត ចំណាយ ដែលមិនចាំបាច់ ឬមិនទាន់ចាំបាច់ និងត្រូវសន្សំសំចៃក្នុងការចាយវាយ ហើយត្រូវលើកកម្ពស់ស្មារតីប្រឆាំងនឹងភាពខ្ជះខ្ជាយ។

**វិន័យទី៦÷** ត្រូវពង្រឹង និងអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ។

**វិន័យទី៧÷** ត្រូវពង្រឹងសវនកម្មនៅក្នុងការគ្រប់គ្រងថវិកាទាំងចំណូល ទាំងចំណាយ ទាំងអធិការកិច្ចហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាំងសវនកម្មផ្ទៃក្នុងនៃសាមីក្រសួងស្ថាប័ននីមួយៗ និងសវនកម្មឯករាជ្យផ្ទៃក្រៅ។

**វិន័យទី៨÷** ហាមដាច់ខាតនូវការចុះកិច្ចសន្យានានាជាមួយក្រុមហ៊ុនឯកជន ដែលមានការពាក់ព័ន្ធដល់កាតព្វកិច្ចពន្ធដារ និងចំណូល-ចំណាយរដ្ឋ ដោយមិនមានការចូលរួម និងការឯកភាពពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**វិន័យទី៩÷** ហាមដាច់ខាតនូវកម្ចីឥណទានដែលមានលក្ខណៈពាណិជ្ជកម្ម។

**វិន័យទី១០÷** ត្រូវពង្រឹងការគ្រប់គ្រងឱ្យបានហ្មត់ចត់បំផុតនូវទ្រព្យសម្បត្តិរបស់រដ្ឋគ្រប់ប្រភេទ ដោយត្រូវគោរពច្បាប់និងបទប្បញ្ញត្តិទាំងឡាយស្ដីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

ទន្ទឹមនេះ រាជរដ្ឋាភិបាល នឹងបន្តដាក់ចេញវិធានការពង្រឹងប្រព័ន្ធធនាគារក្នុងប្រទេស សំដៅធានាឱ្យបាននូវការគ្រប់គ្រងល្អប្រសើរ មានការត្រួតពិនិត្យហ្មត់ចត់ សមស្រប និងមានសមត្ថភាព និងប្រសិទ្ធភាពគ្រប់គ្រាន់ ក្នុងការផ្ដល់ហិរញ្ញប្បទាន សម្រាប់ពង្រីកសកម្មភាពវិស័យឯកជន និងលើកកម្ពស់នៃកំណើនសេដ្ឋកិច្ច ដ្បិតការបង្កើនសញ្ជ័យធនក្នុងស្រុក គឺជាកិច្ចការមួយដែលមានសារៈសំខាន់ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាក្នុងពេលអនាគតរយៈពេលវែង។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងបង្កើនការយកចិត្តទុកដល់ការរៀបចំប្រព័ន្ធច្បាប់ បទបញ្ញា និងយន្តការស្ថាប័នហិរញ្ញវត្ថុ ផ្សេងៗទៀត ព្រមទាំងបន្តលើកស្ទួយវិស័យឥណទានជនបទ ដើម្បីជួយផ្ដល់សេវាហិរញ្ញវត្ថុនិងប្រាក់កម្ចីធ្វើដើមទុនដែលមានការប្រាក់ទាបបំផុត សម្រាប់ជូនដល់ប្រជាពលរដ្ឋក្រីក្រ និងគ្រួសារដែលមានចំណូលទាប ព្រមទាំងសហគ្រាសធុនតូច និងមធ្យម។

**ទី៤. សមាហរណកម្មកម្ពុជានៅក្នុងតំបន់ និងពិភពលោក÷** រាជរដ្ឋាភិបាល នឹងបន្តជំរុញការធ្វើសមាហរណកម្មប្រទេសកម្ពុជានៅក្នុងសហគមន៍ក្នុងតំបន់ និងពិភពលោក ដោយផ្ដោតអាទិភាពជាពិសេស លើការខិតខំកាត់បន្ថយគម្លាតនៃការអភិវឌ្ឍក្នុងសមាគម

ផ្នែកទី៣

ប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន)។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងបន្តចូលរួមយ៉ាងសកម្មក្នុងការអនុវត្ត **"កម្មវិធីមហាអនុតំបន់មេគង្គ"** ពិសេស គម្រោងអាទិភាពនានា ដែលបានអនុម័តនៅក្នុងកិច្ចប្រជុំកំពូលមហាអនុតំបន់មេគង្គលើកទី១ នៅទីក្រុងភ្នំពេញ នាខែវិច្ឆិកា ២០០២ និងគំនិតផ្តួចផ្តើម **"តំបន់អភិវឌ្ឍន៍ត្រីកោណ"** កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ និង **"យុទ្ធសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ច"** រវាងកម្ពុជា-ឡាវ-មីយ៉ាន់ម៉ារ និងថៃ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងសមត្ថភាពស្ថាប័ន និងដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រសហប្រតិបត្តិការជាមួយប្រទេសជិតខាង ដូចជាការអនុវត្តទស្សនាទាន **"ប្រទេសបួន-សេដ្ឋកិច្ចមួយ"** ការបង្កើតតំបន់ត្រីកោណ នៃកំណើនសេដ្ឋកិច្ច និងការបង្កើតតំបន់សេរីសម្រាប់កែច្នៃបម្រើការនាំចេញ។

រាជរដ្ឋាភិបាលនឹងបន្តដំណើរ ទៅមុខទៀតយ៉ាងស្វាហាប់ នៅលើមាគ៌ានៃការធ្វើសេរីភាវូនីយកម្មពាណិជ្ជកម្ម រវាងប្រទេសកម្ពុជា និងប្រទេសជាដៃគូសំខាន់ៗនៅក្នុងតំបន់និងលើសកលលោក។ ការបើកច្រកឱ្យផលិតផលកម្ពុជាអាចឈានចូលដោយគ្មានរបាំង និងឧបសគ្គនានា ទៅកាន់ទីផ្សារដ៏ធំធេងនៅក្នុងតំបន់ និងក្នុងពិភពលោក នឹងផ្តល់ឱ្យកម្ពុជានូវកាលានុវត្តភាពនៃ **"វិមានសេដ្ឋកិច្ច"** ដ៏វិសេសវិសាល ដែលនឹងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ចកម្ពុជា ជាពិសេសការកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាជន។ ជាមួយគ្នានេះ ក្នុងនាមជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក រាជរដ្ឋាភិបាលនឹងប្រឹងប្រែងអនុវត្តយ៉ាងហ្មត់ចត់នូវកាតព្វកិច្ចរបស់ប្រទេសកម្ពុជា ជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក ផងដែរ។

### ជំពូកទី៣. ចតុកោណយុទ្ធសាស្ត្រទាំងបួនសម្រាប់ជំរុញកំណើន

#### ក.ចតុកោណទី១÷ការលើកស្ទួយវិស័យកសិកម្ម

##### ក.១.មុំទី១÷ការលើកកម្ពស់ផលិតភាពកសិកម្ម និងពិពិធកម្មកសិកម្ម

ជាកត្តាសត្យានុម័តមិនអាចប្រកែកបាន វិស័យកសិកម្ម គឺជាវិស័យមួយស្ថិតក្នុងបណ្តាវិស័យស្នូលដ៏ទៃទៀត ក្នុងការចូលរួមពង្រឹងនិងពង្រីកមូលដ្ឋាននៃកំណើនសេដ្ឋកិច្ច

ជាតិ ដែលវិស័យកសិកម្មនេះ មានសក្ដានុពលកំណើនដ៏ធំធេង ហើយថែមទាំងអាចផ្ដល់ឥទ្ធិពលជាវិជ្ជមានយ៉ាងឆាប់រហ័ស លើការលើកកម្ពស់ជីវភាពរបស់ប្រជាជនរស់នៅតាមទីជនបទទៀតផង។

គោលនយោបាយកសិកម្មរបស់រាជរដ្ឋាភិបាល គឺសំដៅលើកកម្ពស់ផលិតភាពកសិកម្ម និងពិពិធកម្មវិស័យកសិកម្ម ឱ្យក្លាយទៅជាផ្នែកនាំមុខមួយ ដែលអាចចូលរួមវិភាគទានយ៉ាងសំខាន់ ដល់ការកាត់បន្ថយភាពក្រីក្រ។ ក្នុងទិសដៅនេះ រាជរដ្ឋាភិបាលនឹងបង្កើនការប្រើប្រាស់ធនធានក្នុងស្រុកសម្រាប់អនុវត្តពហុវប្បកម្ម និងប្រពលវប្បកម្មកសិកម្ម ដើម្បីធានាបាននិរន្តរភាពនៃកំណើន សេដ្ឋកិច្ច បង្កើតការងារ និងបង្កើនប្រាក់ចំណូលនៅជនបទ ព្រមទាំង ធានាសន្តិសុខស្បៀងសំរាប់ប្រជាជនទូទៅ ហើយធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ និងបង្កើនការនាំចេញកសិផល។ ក្នុងន័យនេះ ការបង្វែរទិសពីការអភិវឌ្ឍន៍តាមបែប **"បើកទូលាយ"** ឬ តាមបែប **"វិបុលកម្ម"** ទៅកាន់ការអភិវឌ្ឍន៍តាមបែប **"ស៊ីជម្រៅ"** ឬ តាមបែប **"ប្រពលកម្ម"** ពោលគឺការពង្រឹងសមត្ថភាពដែលមានស្រាប់តាមរយៈប្រពលកម្ម បានក្លាយទៅជាអាទិភាពដ៏ខ្ពស់បំផុតមួយ របស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងជំរុញបង្កើតបរិយាកាសល្អ សម្រាប់ការចូលរួមរបស់ផ្នែកឯកជន ដើម្បីការលូតលាស់នៃវិស័យកសិកម្ម តាមរយៈការប្រឹងប្រែងពន្លឿនការផ្ដល់កម្មសិទ្ធិដីធ្លីនៅតាមជនបទ ក្នុងទិសដៅពង្រឹង សុវត្ថិភាពនៃការកាន់កាប់ដីធ្លីកសិកម្ម ការពង្រីកនិងបែងចែកដីធ្លីកសិកម្មក្នុងក្របខ័ណ្ឌដីសម្បទានសង្គមកិច្ច ការអភិវឌ្ឍ ប្រព័ន្ធស្រោចស្រពផ្ទៃដី និងការគ្រប់គ្រងធនធានទឹក និងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ជាដើម។

ក្នុងក្របខ័ណ្ឌនេះរាជរដ្ឋាភិបាលនឹងផ្ដល់អាទិភាព ជាពិសេស ទៅលើការការវិនិយោគសាធារណៈ និងការលើកទឹកចិត្តវិនិយោគឯកជនឱ្យឆ្ពោះទៅរកវិស័យកសិកម្ម សំដៅការលើកកម្ពស់កំណើនកសិផល និងធានាគុណភាពកសិផលកម្ពុជាឱ្យឆ្លើយតបទៅនឹងតម្រូវការនៃស្តង់ដារអន្តរជាតិ ព្រមទាំងការអភិវឌ្ឍតំបន់ព្រំដែន និងតំបន់ជនបទដាច់ស្រយាល ដើម្បីទប់ស្កាត់ការធ្វើចំណាកចោលស្រុក តាមរយៈការរៀបចំនិងកសាងតំបន់ទីប្រជុំជន

បទមួយចំនួន ដែលមានបណ្តាញហេដ្ឋារចនាសម្ព័ន្ធសមស្របសម្រាប់សម្រួលដល់ជីវភាពរស់នៅ និងការចូលរួមទៅក្នុង សកម្មភាពសេដ្ឋកិច្ចរបស់ប្រជា ពលរដ្ឋ។

ចលនា **"ភូមិមួយ ផលិតផលមួយ"** ត្រូវបានរាជរដ្ឋាភិបាល យកចិត្តទុកដាក់និងជំរុញ ដោយឈរលើគោលការណ៍សំខាន់ បួន យ៉ាងគឺ ÷ (១) រិះរកវិធីផលិត ដែលសមស្របទៅនឹងស្ថានភាពជាក់ស្តែង និងសមស្របទៅតាមសេចក្តីត្រូវការរបស់ទីផ្សារ, (២) បង្កលក្ខណៈងាយស្រួល និងផ្តល់ការលើកទឹកចិត្តប្រជាពលរដ្ឋ ក្នុងការផលិត ដូចជាការស្វែងរកទីផ្សារ ការផ្តល់ឥណទា ការផ្ទេរបច្ចេកវិទ្យា និងការផ្តល់ពូជ, (៣) ជួយបណ្តុះបណ្តាលសមត្ថភាពគ្រប់គ្រង និងធនធាន មនុស្ស និង (៤) បង្កលក្ខណៈងាយស្រួលឱ្យប្រជាពលរដ្ឋបង្កើតសហគមន៍កសិកម្មក្នុងទិសដៅធានាតម្លៃផលិតផល។

### ក.២. មុំទី២÷ កំណែទម្រង់ដីធ្លី និងការបោសសម្អាតមីន

ដោយផ្អែកលើច្បាប់ភូមិបាល និងគោលនយោបាយដីធ្លី រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការពង្រឹងប្រព័ន្ធគ្រប់គ្រង បែងចែក និងប្រើប្រាស់ដីធ្លីប្រកបដោយសមធម៌ និងដោយធានាបាននូវប្រសិទ្ធភាពសេដ្ឋកិច្ច ជាអាទិ៍តាមរយៈការចុះបញ្ជីដីធ្លី ការបែងចែកដីធ្លី ការធានាសុវត្ថិភាពនៃកម្មសិទ្ធិលើដីធ្លី ការលុបបំបាត់ភាពអានាធិបតេយ្យក្នុងការកាន់កាប់ដីដោយខុសច្បាប់ ជាដើម។

ទន្ទឹមនេះ រាជរដ្ឋាភិបាលយល់ច្បាស់ថាការបោសសម្អាតមីនគឺជាបញ្ហាចំពោះមុខដែលពាក់ព័ន្ធទៅនឹងបញ្ហាសន្តិសុខ បញ្ហាសេដ្ឋកិច្ច និងការអភិវឌ្ឍជារួម។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនឹងអនុវត្តការងារតាមនីតិវិធី ដែលបានរៀបចំដើម្បីធានាសកម្មភាពកំចាត់មីន ដែលកំពុងអនុវត្តនៅកម្ពុជាឱ្យមានសុវត្ថិភាព និងមានផែនការល្អ និងអនុវត្តតាមស្តង់ដារជាតិ និងកាតព្វកិច្ចអន្តរជាតិ។

### ក.៣. មុំទី៣÷ វិស័យនេសាទនិងជលផល

មច្ឆជាតិមានសារៈសំខាន់ណាស់ សម្រាប់ប្រជាជនកម្ពុជារាប់លាននាក់ ដោយផ្តល់ជាស្បៀងអាហារ និងជាចំណូល ក្នុងការរស់នៅ។ ដូចនេះ រាជរដ្ឋាភិបាលបានដាក់ចេញ

នូវវិធានការអភិវឌ្ឍន៍វិស័យជលផល ប្រកបដោយចីរភាពនិងមានសមធម៌ ដោយប្រគល់សិទ្ធិអំណាចទៅឱ្យប្រជាកសិករ ក្នុងការចូលរួមរៀបចំផែនការ និងកម្មវិធីនានា ហើយទទួលខុសត្រូវគ្រប់គ្រងធនធានជលផលដោយខ្លួនឯង។ ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងបង្វែរឡូត៍នេសាទចប់កិច្ចសន្យាមួយចំនួនទុកជាកន្លែងអភិរក្សពូជត្រី សម្រាប់បង្កើនផលស្តុកធម្មជាតិផង និងរក្សាពូជត្រីដែលស្ទើរផុតពូជឱ្យកើតមានសម្បូរឡើងវិញផង ព្រមទាំងជំរុញបង្កើនទំហំដែននេសាទ ជូនប្រជាពលរដ្ឋប្រើប្រាស់ និងជំរុញការអភិវឌ្ឍន៍ផ្នែកវារីវប្បកម្ម ផងដែរ។

**ក.៤.មុំទី៤÷ កំណែទម្រង់ព្រៃឈើ**

យុទ្ធសាស្ត្រចតុកោណ បានចង្អុលបង្ហាញពីការគ្រប់គ្រងព្រៃឈើ ប្រកបដោយចីរភាព ដោយឈរលើមូលដ្ឋាននៃសសរទ្រូងបីសំខាន់ៗ គឺ÷

**ទី១.** គោលនយោបាយគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព ដោយមានការត្រួតពិនិត្យអាជីវកម្មព្រៃឈើ យ៉ាងហ្មឹងម៉ាត់ និងសមស្របតាមនិយាមនៃការគ្រប់គ្រងព្រៃឈើជាអន្តរជាតិ។

**ទី២.** រៀបចំប្រព័ន្ធការពារធនធានធម្មជាតិ ដើម្បីធ្វើការអភិរក្សជីវសាស្ត្រចំរុះ និងប្រភេទដែលកម្រ។

**ទី៣.** អនុវត្តកម្មវិធីអភិវឌ្ឍសហគមន៍ព្រៃឈើ ដែលរឹងមាំ មានតម្លាភាព និងមានការគ្រប់គ្រងដោយផ្ទាល់របស់ប្រជាពលរដ្ឋក្នុងតំបន់ ព្រមទាំងបន្តជំរុញគោលនយោបាយដាំដុះព្រៃឈើឡើងវិញ។ ជាពិសេស រាជរដ្ឋាភិបាលបានពិនិត្យនិងផ្អាកអាជីវកម្មព្រៃឈើសម្បទានដែលនៅសេសសល់ទាំងអស់ឡើងវិញ ដើម្បីវាយតម្លៃស្ថានភាពបច្ចុប្បន្នសំដៅទៅលើការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព។

**ខ.ចតុកោណទី២÷ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត**

**ខ.១.មុំទី១÷ការបន្តស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍**

បណ្តាញគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ត្រូវបានទទួលស្គាល់ជាសសៃ

ឈាមនិងដើរតួនាទីដ៏សំខាន់ជា **"ក្បាលរថភ្លើង នៃកំណើន សេដ្ឋកិច្ច"** និងជាមធ្យោបាយដ៏មានប្រសិទ្ធភាពបំផុត សម្រាប់កាត់បន្ថយភាពក្រីក្រ និងទុក្ខលំបាកវេទនារបស់ប្រជាជន ព្រមទាំងជាធាតុផ្សំយ៉ាងសំខាន់ក្នុងការធានាបាននូវសមាហរណកម្មផ្ទៃក្នុង និងសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាជារួបរវន្តទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក។

ឈរលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនឹងបន្តផ្តល់អាទិភាពខ្ពស់ទៅលើការស្តារ និងកសាង ប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនគ្រប់រូបភាពទាំងក្នុងទីក្រុង និងជនបទ រួមមានថ្នល់ ស្ពាន ផ្លូវដែក ផ្លូវទឹក កំពង់ផែ និង អាកាសយានដ្ឋានដែលតភ្ជាប់រវាងគ្រប់តំបន់នៅទូទាំងប្រទេស ទាំងទីក្រុង ទីប្រជុំជន និងតំបន់ជនបទឆ្ងាយដាច់ស្រយាល និងតភ្ជាប់ជាមួយបណ្តាប្រទេសជិតខាង ដើម្បីធានាបាននូវប្រពន្ធ័គមនាគមន៍ដឹកជញ្ជូនមួយដែលមានភាពងាយស្រួល មានស្ថិរភាព មានសុវត្ថិភាព មានប្រសិទ្ធភាពសេដ្ឋកិច្ច និងមានតម្លៃទាបក្នុងទិសដៅសម្រួលដល់ការធ្វើពាណិជ្ជកម្ម ជំរុញវិស័យទេសចរណ៍ ការអភិវឌ្ឍន៍ជនបទ។

## ខ.២.មុំទី២: ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្ត្រ

យុទ្ធសាស្ត្រចតុកោណផ្តល់អាទិភាពលើកិច្ចការងារពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសស្ត្រ ដូចខាងក្រោម÷

**ទី១.** ពលរដ្ឋគ្រប់រូបនឹងទទួលបាននូវការប្រើប្រាស់ទឹក ដែលមានសុវត្ថិភាព និងប្រកបដោយអនាម័យ

**ទី២.** បញ្ចប់ការគំរាមកំហែងបាត់បង់ជីវិត និងលក្ខខណ្ឌជីវិតរបស់ប្រជាពលរដ្ឋ ដែលបណ្តាលមកពីភាពចៃដន្យដែលទាក់ទងនឹងទឹក

**ទី៣.** ផ្តល់ទឹកគ្រប់គ្រាន់ដល់កន្លែងណាដែលត្រូវធានាបាននូវសន្តិសុខស្បៀង សម្រាប់ការរស់នៅរបស់ប្រជាជន និងសម្រាប់សកម្មភាពសេដ្ឋកិច្ច

**ទី៤.** ធានាបរិស្ថានទឹក ដែលគ្មានជាតិពុល និងការទ្រទ្រង់ ជីវិតមច្ឆា និងប្រព័ន្ធអេកូឡូស៊ីនៅក្នុងទឹក។

ទន្ទឹមនេះរាជរដ្ឋាភិបាលនឹងបន្តអភិវឌ្ឍប្រព័ន្ធស្រោចស្រពផ្ទៃដី និងការគ្រប់គ្រង

ធនធានទឹក ដោយផ្ដោតការយកចិត្តទុកដាក់លើការបង្កើនប្រសិទ្ធភាព ក្នុងការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ការបន្តបង្កើតនិងពង្រឹង គុណភាពសហគមន៍អ្នកប្រើប្រាស់ទឹក និងកាត់បន្ថយភាពងាយរងគ្រោះពីគ្រោះធម្មជាតិ។

**ខ.៣.មុំទី៣៖ ការអភិវឌ្ឍន៍វិស័យថាមពល និងបណ្ដាញអគ្គិសនី**

ការអភិវឌ្ឍន៍វិស័យថាមពល ដើម្បីធានាឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងក្នុងថ្លៃថោកសមរម្យ ទៅនឹងតម្រូវការនៃការប្រើប្រាស់ គឺជារបៀបវារៈដ៏សំខាន់បំផុតមួយនៃគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលនឹងផ្ដល់អាទិភាពខ្ពស់ទៅលើការទាក់ទាញឱ្យមានការចូលរួមរបស់ផ្នែកឯកជន នៅក្នុងការផលិតផ្គត់ផ្គង់អគ្គិសនី ការអនុវត្តគម្រោងអគ្គិសនីភាវូបនីយកម្មតំបន់ជនបទ ប្រកបដោយគុណភាពនិងមានតំលៃទាបសមរម្យ ព្រមទាំងគម្រោងតភ្ជាប់ខ្សែបញ្ជូនថាមពល ពីប្រទេសជិតខាង ដោយគិតគូរពីបញ្ហាបរិស្ថានធម្មជាតិ សង្គម និងសេដ្ឋកិច្ច។

**ខ.៤.មុំទី៤៖ ការអភិវឌ្ឍន៍បច្ចេកវិទ្យាពត៌មាន និង ទូរគមនាគមន៍**

រាជរដ្ឋាភិបាល នឹងបន្តការអភិវឌ្ឍប្រព័ន្ធប្រៃសណីយ៍និងទូរគមនាគមន៍ និងជំរុញការអភិវឌ្ឍន៍បច្ចេកវិទ្យាពត៌មាន ប្រកបដោយគុណភាពខ្ពស់ ស្របតាមស្តង់ដារអន្តរជាតិ មានថ្លៃថោកសមរម្យ និងមានសេវាកម្មទំនើបគ្របដណ្ដប់ទូទាំងប្រទេសតាមរយៈការអនុវត្ត យុទ្ធសាស្ត្រចតុកោណនៃរាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៣ នៃរដ្ឋសភានេះ ដោយបានកំណត់ វិធានការដូចតទៅ៖

**ទី១.** បន្តជំរុញការវិនិយោគ ទៅលើបណ្ដាញហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នង (Backbone infrastructure) សម្រាប់បម្រើឱ្យវិស័យបច្ចេកវិទ្យាពត៌មាននិងទូរគមនាគមន៍ (Information and Communication Technology) ពិសេសបណ្ដាញខ្សែកាប្លអុបទិចដែលមានសមត្ថភាពខ្ពស់ ដែលនឹងចូលរួមបំរើប្រកបដោយប្រសិទ្ធភាពទាំងក្នុងទីក្រុង និងជនបទ។

**ទី២.** បង្កើតឱ្យមានបណ្ដាញទូរគមនាគមន៍នៅក្រុងភ្នំពេញ ក្រុងព្រះសីហនុ និងក្រុងសៀមរាប និងពង្រីកសេវាកម្មនៅតាមក្រុង និងទីរួមខេត្ត។

**ទី៣.** ដាក់ចេញនូវបទដ្ឋានថ្នាក់ជាតិ សម្រាប់ការរៀបចំគម្រោងការសាងសង់ និងកិច្ចប្រតិបត្តិការគ្រប់សេវាទូរគមនាគមន៍ និងសម្រាប់បច្ចេកវិទ្យាពត៌មាន រួមមានប្រព័ន្ធស្តង់ដារ និងបទដ្ឋានសម្រាប់ការប្រើប្រាស់ បច្ចេកវិទ្យាកុំព្យូទ័រ និងអ៊ិនទែរណិតផងដែរ។

**ទី៤.** ពង្រឹងឱ្យបានរឹងមាំនូវរចនាសម្ព័ន្ធប្រៃសណីយ៍ ព្រមទាំងសមត្ថភាពស្ថាប័នដើម្បីធ្វើឱ្យសេវាកម្មនេះ មានភាពរីកចម្រើនប្រសើរឡើង។

**ទី៥.** ពង្រីកបណ្តាញផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ក្នុងគោលដៅបង្កើនប្រសិទ្ធភាព និងសម្រួលដល់ការធ្វើសេវាលើផ្នែកពត៌មាន និងប្រៃសណីយ៍ ។

**គ.ចតុកោណទី៣÷ការអភិវឌ្ឍន៍ផ្នែកឯកជន និងការងារ**

**គ.១.មុំទី១÷ ការពង្រឹងវិស័យឯកជន និងការទាក់ទាញការវិនិយោគ**

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកវិស័យឯកជន គឺជាគន្លឹះសម្រាប់ជំរុញការអភិវឌ្ឍន៍ និងកំណើនសេដ្ឋកិច្ចដ៏រឹងមាំ។ តាមរយៈនេះ អាទិភាពពិសេសក្នុងនីតិកាលទី៣ នេះនឹងត្រូវផ្តោតទៅលើការរៀបចំឱ្យកាន់តែប្រសើរឡើងនូវបរិស្ថានរួម សម្រាប់ការអភិវឌ្ឍវិស័យឯកជន តាមរយៈវិធានការជាក់ស្តែងនានាដែលសំដៅ (១) ពង្រឹងអភិបាលកិច្ច ទាំងក្នុងវិស័យសាធារណៈ (Public Governance) ទាំងក្នុងវិស័យឯកជន (Corporate Governance), (២) សម្រួលពាណិជ្ជកម្ម និងកែលម្អបរិយាកាសវិនិយោគ និង( ៣) ជំរុញការអភិវឌ្ឍធនធានមនុស្ស ឱ្យឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងតម្រូវការនៃទីផ្សារ។

ទន្ទឹមនេះ រាជរដ្ឋាភិបាលនឹងបន្តផ្តោតការយកចិត្តទុកដាក់លើការទាក់ទាញការចូលរួមរបស់វិស័យឯកជន នៅតាមវិស័យអាទិភាពចំនួន ៦ គឺ ÷

**ទី១.** ការអភិវឌ្ឍវិស័យកសិកម្ម និងកសិឧស្សាហកម្ម ដោយផ្តល់អាទិភាពលើការដោះស្រាយទឹក សម្រាប់កសិកម្ម

**ទី២.** ការអភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ដឹកជញ្ជូន និងទូរគមនាគមន៍

**ទី៣.** ការអភិវឌ្ឍវិស័យថាមពល និងអគ្គិសនី

**ទី៤.** វិស័យឧស្សាហកម្មអតិពលកម្ម និងឧស្សាហកម្មកែច្នៃសម្រាប់ការនាំចេញ

**ទី៥.** វិស័យឧស្សាហកម្មទេសចរណ៍ និង

**ទី៦.** ការអភិវឌ្ឍធនធានមនុស្ស។

### គ.២.មុំទី២÷ ការលើកស្ទួយសហគ្រាសធុនតូច និងមធ្យម

រាជរដ្ឋាភិបាល បានលើកទិសដៅជំរុញការអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម (SME) ដោយបានកំណត់ គោលនយោបាយដូចតទៅ÷

**ទី១.** លើកទឹកចិត្តដល់ការរីកលូតលាស់សហគ្រាសធុនតូច និងមធ្យម ជាពិសេសតាមរយៈការផ្តល់ឥណទានរយៈពេលមធ្យម និងរយៈពេលវែង

**ទី២.** ទប់ស្កាត់ការរត់គេចពន្ធគ្រប់ប្រភេទ

**ទី៣.** កាត់បន្ថយបែបបទសម្រាប់ការចុះបញ្ជី និងការរៀបចំដំណើរការក្រុមហ៊ុន

**ទី៤.** សម្រួលដល់ការនាំចេញ នាំចូលតាមរយៈការកាត់បន្ថយបែបបទស្មុគស្មាញ

**ទី៥.** ផ្តល់ការគាំពារដល់ឧស្សាហកម្មក្មេងខ្ចីមួយចំនួន ក្នុងរយៈពេលសមស្របមួយ

**ទី៦.** ជំរុញសម្ព័ន្ធភាពរវាងសហគ្រាសខ្នាតតូច និងមធ្យមជាមួយនឹងឧស្សាហកម្មធុនធំ

**ទី៧.** ជំរុញបង្កើតមជ្ឈមណ្ឌលផលិតភាពជាតិ ដែលជួយដល់ឧស្សាហកម្មធុនតូច និងមធ្យមតាមរយៈការលើកកម្ពស់ផលិតភាព និងការកាត់បន្ថយថ្លៃដើមនៃផលិតកម្ម

**ទី៨.** បង្កើតវិទ្យាស្ថានស្តង់ដារជាតិ ក្នុងទិសដៅធានាគុណភាពផលិតផលក្នុងប្រទេសអាចឆ្លើយតបបានទៅនឹងស្តង់ដារតំបន់ និងអន្តរជាតិ

**ទី៩.** បង្កើតមន្ទីរ ពិសោធន៍ជាតិផ្នែករូបគីមី មីក្រូជីវៈ មេកានិច និងការធ្វើតេស្តដែលអាចកំណត់បាន លើគុណភាព និងលក្ខណៈវិនិច្ឆ័យរបស់ផលិតផល

**ទី១០.** ពង្រឹងយន្តការការពារកម្មសិទ្ធិបញ្ញា

**ទី១១.** ជំរុញដល់ការបណ្តុះបណ្តាលមុខវិជ្ជាជំនាញទាំងនៅក្នុង និងក្រៅប្រទេស

**ទី១២.** បង្កើនចលនាភូមិមួយផលិតផលមួយ និង

**ទី១៣.** ពង្រឹងប្រព័ន្ធច្បាប់ ដោយបង្កើតច្បាប់ជាអាទិ៍ច្បាប់រោងចក្រ ច្បាប់តំបន់ឧស្សាហកម្ម ច្បាប់ប៉ាតង់ និងតក្កកម្មឧស្សាហកម្ម និងច្បាប់សុវត្ថិភាពឧស្សាហកម្ម។

### គ.៣.មុំទី៣÷ការបង្កើតការងារ និងការធានាលក្ខខណ្ឌការងារល្អប្រសើរជូនកម្មករ និងនិយោជិត

រាជរដ្ឋាភិបាលនឹងជំរុញអនុវត្តគោលនយោបាយជាប្រព័ន្ធ និងជាខ្សែសង្វាក់ សំដៅបង្កើតការងារឱ្យបានច្រើនជូនដល់ស្រទាប់យុវវ័យ និងពលករកម្ពុជាទាំងអស់ តាមរយៈការដាក់ចេញនូវវិធានការលើកទឹកចិត្ត ដល់ការវិនិយោគក្នុងស្រុក និងវិនិយោគផ្ទាល់ពីបរទេស និងការបង្កើតបណ្តាញបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ជូនជនក្រីក្រដែលផ្សារភ្ជាប់ជាមួយនឹងមជ្ឈមណ្ឌលសម្រាប់ជួយរកការងារធ្វើឱ្យយុវជន ជាដើម។

ជាការពិត ការវិនិយោគក្នុងទីក្រុង គឺជាគោលនយោបាយដ៏សំខាន់ក្នុងការគាំពារដល់ជនក្រីក្រ ប្រសិនបើវិនិយោគ នេះ បង្កើតការងារផលិតកម្ម ដើម្បីស្រូបយកចំនួនពលករដ៏ច្រើនលើសលប់ដែលមកពីទីជនបទ។ ការរីកលូតលាស់នៃឧស្សាហកម្មអតិពលកម្មដូចជា ឧស្សាហកម្មកាត់ដេរជាដើម បានបង្កើតជាគ្រឹះដ៏រឹងមាំមួយក្នុងការបង្កើនប្រាក់ចំណូលសម្រាប់ប្រជាជនម្នាក់ៗ និងកាត់បន្ថយនូវភាពក្រីក្រ។ ទន្ទឹមនេះ ការអភិវឌ្ឍកម្មន្តសាលអតិពលកម្ម បានស្រូបយកកម្លាំងពលកម្មពីទីជនបទ ហើយអាចបង្កើនប្រាក់ចំណូល ដែលជាកត្តាមួយជួយកាត់បន្ថយភាពក្រីក្រពីដើមទីតែម្តង។

ជាការពិត គោលនយោបាយលើកទឹកចិត្តការនាំចេញពលកម្មជាផ្លូវការ គឺជាកិច្ចការអាទិភាពផងដែរ សំដៅបង្កើនសុខុមាលភាព និងធ្វើឱ្យប្រសើរឡើងនូវជំនាញ ព្រមទាំងកាត់បន្ថយភាពគ្មានការងារធ្វើ និងបង្កើនប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ។

### គ.៤.មុំទី៤÷ ការរៀបចំប្រព័ន្ធសុវត្ថិភាពសង្គម សម្រាប់មន្ត្រី បុគ្គលិក កម្មករ

រាជរដ្ឋាភិបាល នឹងបង្កើនអន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច នៅក្នុងទិសដៅលើកស្ទួយកាលានុវត្តភាពការងារ កាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជនក្រីក្រ បង្កើនសកម្មភាពសង្គ្រោះបន្ទាន់ និងរៀបចំកម្មវិធីលើកកម្ពស់សុខុមាលភាពរបស់ជនចាស់ជរា កុមារកំព្រា ស្ត្រីរងគ្រោះ ជនអនាថាដែលគ្មានទីពឹង អតីតយុទ្ធជន និងគ្រួសារ។ រាជរដ្ឋាភិបាលនឹង

បន្តឧបត្ថម្ភឱ្យបានជិតដល់ចំពោះជនពិការ និងគ្រួសារយុទ្ធជនដែលបានបូជាជីវិតដើម្បីប្រទេសជាតិ ព្រមទាំងជំរុញឱ្យម្ចាស់សហគ្រាស រោងចក្រ ឧបត្ថម្ភប្រាក់បៀវត្ស រួមជាមួយកម្រៃ បេឡាសន្តិសុខសង្គម ដល់កម្មករជាជំហានៗ ឱ្យបានសមស្របតាមកម្រិតលក្ខខណ្ឌទីផ្សារការងារ។

ជាមួយគ្នានេះ រាជរដ្ឋាភិបាលនឹងបន្តអាទិភាពពិសេសលើការកែលម្អឱ្យកាន់តែប្រសើរឡើង នូវលក្ខខណ្ឌការងាររបស់កម្មករ និងនិយោជិត ព្រមទាំងជំរុញការអនុវត្តច្បាប់ស្តីពីការងារ ច្បាប់ស្តីពីរបបសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព។

### ឃ. ចតុកោណទី៤÷ការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស

#### ឃ.១.មុំទី១÷ ការពង្រឹងគុណភាពវិស័យអប់រំ

រាជរដ្ឋាភិបាល បានដាក់ចេញនូវយុទ្ធសាស្ត្រដ៏ទូលំទូលាយមួយសម្រាប់វិស័យអប់រំ ដែលមានចែងលម្អិតក្នុងផែនការយុទ្ធសាស្ត្រសម្រាប់ទ្រទ្រង់វិស័យអប់រំ (ESSP) សម្រាប់ឆ្នាំ ២០០១-២០០៥ ក្នុងគោលដៅលើកស្ទួយសមត្ថភាពធនធានមនុស្សឱ្យមានមុខជំនាញបច្ចេកទេសនិងវិទ្យាសាស្ត្រ ដែលអាចឆ្លើយតបប្រកបដោយប្រសិទ្ធភាព ទៅនឹងតម្រូវការនៃទីផ្សារ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបន្តប្រឹងប្រែងសម្រេចទិសដៅ **“អប់រំសម្រាប់ទាំងអស់គ្នា”** តាមរយៈការធានាសមធម៌ក្នុងការអប់រំមូលដ្ឋាន ព្រមទាំងបង្កើននិងលើកកម្ពស់សេវាអប់រំទាំងក្នុងកំរិតមធ្យមសិក្សាបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេស ទាំងក្នុងកំរិតឧត្តមសិក្សា។

រាជរដ្ឋាភិបាលនឹងបន្តខិតខំបង្កើនចំណាយថវិកាជាតិ ឱ្យបានច្រើនថែមទៀត ក្នុងទិសដៅធានាប្រសិទ្ធភាពនៃការពង្រឹងគុណភាពវិស័យអប់រំ ជាអាទិ៍ការបង្កើនប្រាក់បៀវត្សនិងប្រាក់លើកទឹកចិត្តគ្រូជូនបង្រៀន ការធានាគុណភាពបណ្តុះបណ្តាល ការបង្កើនការផ្គត់ផ្គង់សម្ភារៈសិក្សា បណ្ណាល័យ និងមន្ទីរពិសោធន៍ ជាដើម។

#### ឃ.២.មុំទី២÷ ការលើកកម្ពស់សេវាសុខាភិបាល

ការកសាងមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព នៅទូទាំងប្រទេសដែលអាចផ្គត់ផ្គង់

សេវាសុខាភិបាលមូលដ្ឋាន ប្រកបដោយប្រសិទ្ធភាព សមធម៌ និងនិរន្តរភាព ជូនដល់ប្រជាពលរដ្ឋគ្រប់រូប គឺជាកិច្ចការអាទិភាពដ៏មានសារៈសំខាន់ សម្រាប់រាជរដ្ឋាភិបាល។ តាមរយៈនេះ រាជរដ្ឋាភិបាលនឹងបន្តផ្តោតការយកចិត្តទុកដាក់លើការអនុវត្តកម្មវិធីបង្ការ និងព្យាបាលជម្ងឺឆ្លងនានា ការគាំពារមាតា និងទារក ដើម្បីកាត់បន្ថយអត្រាមរណភាពមាតា និងទារក ការសង្គ្រោះបន្ទាន់ ព្រមទាំងការអប់រំ និងផ្សព្វផ្សាយ ពតិមានសុខាភិបាល និងអនាម័យឱ្យបានទូលំទូលាយ ជាពិសេសដល់ជនបទ។ ជាមួយគ្នានេះប្រជាពលរដ្ឋក្រីក្រត្រូវទទួលបាននូវការពិនិត្យរោគដោយឥតគិតថ្លៃនៅតាមមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព។

រាជរដ្ឋាភិបាលប្តូរផ្តាច់ជំរុញរៀបចំ និងអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងវិស័យសុខាភិបាលឱ្យមានប្រសិទ្ធភាព ដើម្បីធានាសស្តង់ដារគុណភាពខ្ពស់មួយ ក្នុងការផ្គត់ផ្គង់សេវាសុខភាព និងឱសថ និងក្នុងការធានាសុវត្ថិភាពចំណីអាហារ។

**ឃ.៣.មុំទី៣ៈ ការអនុវត្តគោលនយោបាយយេនឌ័រ (Gender Policy)**

រាជរដ្ឋាភិបាលផ្តល់អាទិភាពខ្ពស់ទៅការលើកកម្ពស់តួនាទី និងស្ថានភាពសង្គមរបស់ស្ត្រីកម្ពុជា ដោយបានកំណត់ថាស្ត្រី គឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ និងជា **"នារីរតនៈ"** ឬស្ត្រីគឺជាត្បូងមានតម្លៃ ក្នុងកិច្ចដំណើការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ តាមរយៈនេះ រាជរដ្ឋាភិបាលបន្តជំរុញអនុវត្តយុទ្ធសាស្ត្រយេនឌ័រ ការកសាងសមត្ថភាពស្ត្រីលើគ្រប់ផ្នែក ការកែប្រែឥរិយាបថក្នុងសង្គមដែលមានការរើសអើងចំពោះស្ត្រីភេទ និងការធានាសិទ្ធិដើម្បីឱ្យស្ត្រីភេទមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការចូលរួមយ៉ាងសកម្ម និងដោយស្មើភាពក្នុងដំណើរការកសាងប្រទេស។

ក្នុងន័យនេះស្ត្រីគ្រប់រូបមានសិទ្ធិក្នុងការទទួលបានការថែទាំសុខភាព ការសិក្សា និងការបណ្តុះបណ្តាលមុខជំនាញនៅគ្រប់កម្រិត ការទទួលបានធនធានសេដ្ឋកិច្ចដោយសមធម៌ ឱកាសចូលរួមក្នុងកិច្ចការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចក៏ដូចជាការទទួលបានការការពារតាមផ្លូវច្បាប់ប្រកបដោយយុត្តិធម៌ ដោយស្មើភាព និងការគាំពារគ្រប់កម្រិត។

### ឃ.៤.មុំទី៤÷ការអនុវត្តគោលនយោបាយប្រជាជន

រាជរដ្ឋាភិបាលបានទទួលស្គាល់ថា ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោល-នយោបាយប្រជាជន ពិតជាមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់កាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាជន ពិសេសគឺការសម្រេចឱ្យបានទៅតាមគោលដៅអភិវឌ្ឍសហស្សវត្សរ៍ ដែលកំណត់ឱ្យប្រទេសនីមួយៗ កាត់បន្ថយភាពក្រីក្រឱ្យបានពាក់កណ្តាលនៅឆ្នាំ២០១៥។

តាមរយៈនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្តយ៉ាងសកម្មនូវគោលនយោបាយប្រជាជន ស្របទៅតាមបរិការណ៍សង្គម និងវប្បធម៌កម្ពុជា ដែលសំដៅជាសំខាន់ទៅលើអាទិភាពមួយចំនួន ដូចតទៅ ÷

**ទី១.** គាំទ្រដល់គូស្វាមីភរិយា និងគ្រួសារនីមួយៗ ឱ្យធ្វើការសម្រេចចិត្តដោយសេរី និងដោយទទួលខុសត្រូវ លើចំនួនកូន និងការពន្យារកំណើត ព្រមទាំងធានាការផ្តល់ពត៌មាន ការអប់រំ ការផ្តល់សេវាកម្ម និងមធ្យោបាយពាក់ព័ន្ធផ្សេងៗ

**ទី២.** កាត់បន្ថយអត្រាខ្ពស់ នៃលទ្ធភាពផ្តល់កំណើត និងបង្កើនការប្រើប្រាស់សេវាពន្យារកំណើរ

**ទី៣.** កាត់បន្ថយអត្រានៃ "**ភាពមានជម្ងឺ**" ដែលធ្វើឱ្យស្លាប់ និងអត្រាមរណភាពរបស់ទារក កុមារ និងម្តាយ

**ទី៤.** ជំរុញឱ្យមានសមភាព និងសមធម៌យេនឌ័ និងលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស

**ទី៥.** កាត់បន្ថយផលប៉ះពាល់ នៃសម្ពាធប្រជាជនទៅលើបរិស្ថាន និងធនធានធម្មជាតិ

**ទី៦.** ពង្រឹងបន្ថែមទៀតនូវការទប់ស្កាត់ការរីករាលដាលមេរោគហ៊ីវ/អេសដ៍

**ទី៧.** បញ្ចូលអញ្ញត្តិប្រជាជនទៅក្នុងសមីការ នៃគោលនយោបាយសេដ្ឋកិច្ច សង្គមកិច្ច និងទៅក្នុងផែនការ និងកម្មវិធីនានា នៅគ្រប់កម្រិតទាំងអស់។

### ខ. សេចក្តីសន្និដ្ឋាន

កម្ពុជាបានចំណាយពេលវេលា និងបានខិតខំប្រឹងប្រែងយ៉ាងពេញទំហឹង ដើម្បីស្តារ

និងកសាងប្រទេសឡើងវិញពីការបំផ្លិចបំផ្លាញនៃរបបប្រល័យពូជសាសន៍ និងសង្គ្រាមរ៉ាំរ៉ៃ ទម្រាំសម្រេចបាននូវសុខសន្តិភាពពេញលេញ សេរីភាពនយោបាយ សណ្តាប់ធ្នាប់សង្គម លទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និងស្ថេរភាពសេដ្ឋកិច្ចរឹងមាំដែលត្រូវបានសាធារណៈមតិជាតិ និងអន្តរជាតិកោត សរសើរ និងទទួលស្គាល់។ សមិទ្ធផលទាំងនេះ គឺកើតចេញពីការអនុវត្តកម្មវិធីកំណែទម្រង់គ្រប់វិស័យ ដោយបានឆ្លងកាត់ការ លំបាក និងឧបសគ្គធំតូចច្រើនរាប់មិនអស់ ចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ឆ្នាំទី៨០។

ជាការពិត រាជរដ្ឋាភិបាលយល់ច្បាស់និងបានចាត់ទុកភាពក្រីក្រ គឺជាបញ្ហាចំពោះមុខ និងត្រូវដោះស្រាយជាបន្ទាន់។ តាមរយៈនេះ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ដែលមានគោលដៅគន្លឹះចម្បងដូចខាងក្រោម ÷

**ទី១.** ពង្រឹងសន្តិភាព សន្តិសុខ ស្ថិរភាព និងសណ្តាប់ធ្នាប់សង្គម ក្នុងទិសដៅធានាការអភិវឌ្ឍប្រកបដោយចីរភាព។

**ទី២.** ធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ក្នុងអត្រាខ្ពស់ពី ៦ ទៅ ៧% ក្នុងមួយឆ្នាំ។

**ទី៣.** បែងចែកផ្លែផ្កានៃកំណើនសេដ្ឋកិច្ច ប្រកបដោយសមធម៌។

**ទី៤.** ធានាគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិនិងបរិស្ថានប្រកបដោយចីរភាព និងនិរន្តរភាព ។

តាមរយៈនេះ "**យុទ្ធសាស្ត្រចតុកោណ**" គឺជាឧបករណ៍គោលនយោបាយ ប្រកបដោយប្រសិទ្ធភាពរបស់រាជរដ្ឋា-ភិបាលនីតិកាលទី៣ នៃរដ្ឋសភាសម្រាប់បន្តជំរុញអនុវត្តនូវ "**យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ**" ដែលមានគោលដៅ គន្លឹះចម្បងទាំងបួន ដូចបានគូសបញ្ជាក់ខាងលើ។

ពិតណាស់រាជរដ្ឋាភិបាលទទួលស្គាល់ថា គ្រប់បញ្ហានៃភាពក្រីក្រ ពុំអាចនឹងត្រូវបានដោះស្រាយរួចស្រេចបាច់អស់ក្នុងរយៈពេលតែមួយថ្ងៃ ឬមួយខែ ឬមួយឆ្នាំនោះឡើយ។ ក៏ប៉ុន្តែដោយមានកម្មវិធីច្បាស់លាស់ និងដោយមានការខិតខំប្រឹងប្រែងរួមគ្នានិងដោយ

ស្មោះត្រង់ យើងប្រាកដជាអាចធ្វើឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានយ៉ាងច្រើន ក្នុងរយៈពេល ៤ឆ្នាំ ខាងមុខ។

ក្នុងន័យនេះ ការចូលរួមការគាំទ្រនិងសកម្ម របស់ដៃគូអភិវឌ្ឍន៍ទាំងអស់ រួមមាន សហគមន៍អ្នកផ្តល់ជំនួយ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល ព្រមទាំង ថ្នាក់ដឹកនាំមន្ត្រីរាជការនៅគ្រប់ក្រសួង ស្ថាប័ន និងប្រជាពលរដ្ឋគ្រប់រូប ក្នុងការអនុវត្ត **“កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសំរាប់នីតិកាលទី៣ នៃរដ្ឋសភា”** ពិសេសគឺ “**យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា**” ដែលជារបៀបវារៈគោលនយោបាយសេដ្ឋកិច្ចនៃកម្មវិធីនយោបាយនេះ គឺជាកត្តាកំណត់ នូវភាពជោគជ័យរបស់ដែលមិនអាចប្រកែកបាន ក្នុងទិសដៅកាត់បន្ថយនូវភាពក្រីក្រ របស់ប្រជាជន និងដើម្បីវឌ្ឍនភាព វិបុលភាព និងកិត្យានុភាព ដ៏ខ្ពស់ត្រដែត នៃព្រះរាជាណាចក្រកម្ពុជា។

# ៤. យុទ្ធសាស្ត្រត្រីកោណ

## ក. សេចក្តីផ្តើម

ក្រោយការបោះឆ្នោតឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័ត "**យុទ្ធសាស្ត្រត្រីកោណ**" ដែលដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងទិសដៅជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា ដោយឈរផ្អែកលើមុំចំនួន ៣ គឺមុំទី១ ការពង្រឹងស្ថិរភាព សន្តិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម, មុំទី២ ការធ្វើសមាហរណកម្មកម្ពុជាចូលទៅក្នុងសហគមន៍អន្តរជាតិ និងតំបន់ និងមុំទី៣ គឺការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រ។

មុំទី១÷ពង្រឹងស្ថិរភាព សន្តិភាព សន្តិសុខ
និងសណ្តាប់ធ្នាប់សង្គម



មុំទី២÷សមាហរណកម្មកម្ពុជាចូលទៅក្នុង
សហគមន៍អន្តរជាតិ និងតំបន់

មុំទី៣÷ ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច
និងការកាត់បន្ថយភាពក្រីក្រ

## ខ. ខ្លឹមសារ

ផ្អែកតាមមុំទាំង៣ ខាងលើ ដែលជាយុទ្ធសាស្ត្រ ក្នុងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី២ នៃរដ្ឋសភា យើងអាចកំណត់ខ្លឹមសារគ្រឹះសំខាន់ៗនៃមុំនីមួយៗ ដូចខាងក្រោម÷

**មុំទីមួយ÷** ការនាំសុខសន្តិភាពនិងស្ថេរភាពមកវិញ និងរក្សាបាននូវសន្តិសុខសម្រាប់ប្រទេស និងប្រជាជនខ្លួន តាមរយៈការសម្រេចទាំងស្រុងនៃការនាំមកនូវឯកភាពជាតិទឹកដីជាលើដំបូងនៅក្នុងប្រវត្តិសាស្ត្រក្រោម **"នយោបាយឈ្នះ ឈ្នះ"**។ គួរកត់សម្គាល់ថា **"នយោបាយឈ្នះ ឈ្នះ"** បានធ្វើឱ្យប្រទេសកម្ពុជាឆ្លងកាត់ដំណាក់កាលប្រែប្រួល យ៉ាងធំធេងពីចំណុច មួយនៃផែនទីពិភពលោក ហើយក្លាយទៅជាប្រទេសមួយ ដែលមានសុខសន្តិភាពពេញលេញ មានសុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គម មានការគោរពលទ្ធិប្រជាធិបតេយ្យ គោរពសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្ស ព្រមទាំងមានកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍។

**មុំទីពីរ÷** ការធ្វើសមាហរណកម្មប្រទេសកម្ពុជាចូលក្នុងតំបន់ និងធម្មនីយកម្មនៃទំនាក់ទំនងរបស់ខ្លួន ជាមួយសហគមន៍អន្តរជាតិក៏បានសម្រេចដោយជោគជ័យផងដែរ តាមរយៈការបង្ហាញសមិទ្ធផលខាងក្រោម÷

- ប្រទេសកម្ពុជាបានទទួលអាសនៈរបស់ខ្លួន នៅអង្គការសហប្រជាជាតិមកវិញ ដែលអាសនៈនេះបានបាត់បង់ ពីក្រោយការប្រឈមគ្នាខាងប្រដាប់អាវុធនៅខែកក្កដា ឆ្នាំ១៩៩៧
- នៅឆ្នាំ១៩៩៩ កម្ពុជាបានក្លាយជាសមាជិកទី១០ នៃសហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ដែលបង្ហាញយ៉ាងច្បាស់ថាកម្ពុជា លែងជាប្រទេសឯកោ។ ទន្ទឹមនេះ ចំពោះ**ផ្នែកនយោបាយ** កម្ពុជាអាចឈរស្មើមុខស្មើមាត់ជាមួយប្រទេសដែលជាសមាជិក និងចូលរួមនូវរាល់ការសម្រេចចិត្តនៅក្នុងតំបន់។ ចំពោះ**ផ្នែកសេដ្ឋកិច្ច** កម្ពុជាបានក្លាយជាកន្លែងវិនិយោគទុនដ៏ទាក់ទាញ និងការធ្វើពាណិជ្ជកម្មប្រកបដោយភាពងាយស្រួល។ តាមរយៈនេះ ប្រជាជនអាចរកការងារធ្វើបានយ៉ាងទូលំទូលាយទាំងក្នុងប្រទេស និងក្នុងតំបន់ ព្រមទាំងភ្ញៀវទេសចរ មានការកើនឡើង។ ដូច្នេះការចូលជាសមាជិកអាស៊ានគឺជាផ្នែកមួយដែលជំរុញឱ្យមានការកសាងហេដ្ឋារចនាសម្ព័ន្ធនិងផ្លូវថ្នល់ ព្រមទាំងការលើកលែងទិដ្ឋាការ។ រីឯ

**ផ្នែកសង្គម** កម្ពុជាទទួលបាននូវកិច្ចសហការជាមួយប្រទេសក្នុងតំបន់ក្នុងការថែរក្សាសន្តិភាពនិងសន្តិសុខសង្គម ទប់ស្កាត់ការជួញដូរមនុស្ស ថ្នាំញៀន និងអំពើភេរវកម្ម ព្រមទាំងមានការជួយគ្នាទៅវិញទៅរវាងប្រទេសសមាជិកតាមរយៈការផ្ទេរបទពិសោធន៍ ចំណេះដឹង អាហារូបករណ៍សម្រាប់និស្សិតបានធ្វើឱ្យមន្ត្រីរាជការ ប្រជាជន និងយុវជនកម្ពុជាបានរៀនសូត្រ និងទទួលបាននូវឱកាសល្អៗជាច្រើន។

- នៅខែតុលា ឆ្នាំ២០០៤ កម្ពុជាបានចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក។

**មុំទី៣**÷ ការជំរុញការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច តាមរយៈកម្មវិធីកំណែទម្រង់ទូលំទូលាយដែលពាក់ព័ន្ធនឹងកំណែទម្រង់រដ្ឋបាលសាធារណៈ វិមជ្ឈការ ការកេណ្ឌទាហានឡើងវិញ កំណែទម្រង់ច្បាប់និងតុលាការ សមភាពយេនឌ័រ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។

ជារួម យុទ្ធសាស្ត្រត្រីកោណត្រូវបានអនុវត្តដោយជោគជ័យដោយធានានូវការរក្សាកំណើនខ្ពស់ និងការវិនិយោគកើនឡើង ការគ្រប់គ្រងបានប្រសើរជាងមុនខាងគោលនយោបាយរូបិយវត្ថុ និងសារពើពន្ធ ដែលជាលទ្ធផលនាំឱ្យមានអតិផរណាទាប និងទុនបម្រុងអត្រាប្តូរប្រាក់ខ្លាំង លំហូរចូលនៃការផ្ទេររូបិយវត្ថុបរទេសផ្លូវការ និងមូលធនឯកជនច្រើនជាងមុន និងការអភិវឌ្ឍវិស័យឯកជន មានភាពរីកចម្រើនយ៉ាងលឿនរហ័ស។

# ផ្នែកទី៤. បទពិសោធន៍

## ១. ស្នាដៃធំៗ ៨ យ៉ាង របស់គណបក្សប្រជាជនកម្ពុជា



១. **សង្គ្រោះជាតិឲ្យរស់ឡើងវិញ** រួចផុតពីរបបប្រល័យពូជសាសន៍ នាថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩ ទប់ស្កាត់មិនឲ្យរបបដ៏យង់ឃ្នងនេះវិលត្រឡប់មកវិញ និងបានធ្វើឲ្យអង្គការចាត់តាំងនៃរបបប្រល័យពូជសាសន៍ ត្រូវរលំរលាយទាំងស្រុង ។

២. **សិទ្ធិសេរីភាពគ្រប់យ៉ាង កិត្តិយសសេចក្តីថ្លៃថ្នូរ** និង **លទ្ធិប្រជាធិបតេយ្យ** ត្រូវបានដណ្តើមមកជូនប្រជាជនវិញ និងធ្វើឲ្យមានការរីកចម្រើនឥតឈប់ឈរនូវ និង ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ជាបន្តបន្ទាប់ ទាំងនៅថ្នាក់ជាតិ និងមូលដ្ឋាន ទាំងសកល និងអសកល ។

៣. **កម្លាំងស្នូលក្នុងដំណើរការបង្រួបបង្រួមជាតិ** រហូតបានសម្រេចកិច្ចព្រមព្រៀងទីក្រុងប៉ារីស នាថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១ និងជាកម្លាំងស្នូលក្នុងការកសាងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ កម្ពុជាទី ២ ដែលប្រកាន់យកប្រព័ន្ធនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ។

៤. **សន្តិភាពូបនីយកម្មប្រទេសជាតិទាំងមូល** តាមរយៈនយោបាយ ឈ្នះ ឈ្នះ លើមូលដ្ឋានការបង្រួបបង្រួមជាតិដែលបាននាំមកនូវសន្តិភាព ឯកភាពជាតិ និងឯកភាពទឹកដីទាំងស្រុង

៥. **សមិទ្ធផលរបស់ជាតិ** ដោះស្រាយភាពជាប់គាំងខាងនយោបាយក្រោយពេលបោះឆ្នោត ហើយធ្វើជាកម្លាំងស្នូលក្នុងការដោះស្រាយស្ថិរភាពនៃរាជបល្ល័ង្គ ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញពីប្រព័ន្ធ ២/៣ មកប្រព័ន្ធភាគច្រើនដាច់ខាត និងការរក្សាស្ថិរភាព សន្តិសុខ និងសណ្តាប់ធ្នាប់សង្គមបានរឹងមាំ ធ្វើឲ្យប្រជាជនបានរស់នៅយ៉ាងសុខសាន្ត ។

៦. **ស្តារសេដ្ឋកិច្ចសង្គម**ឡើងវិញជាជំហានៗ តាំងពីលេខសូន្យ រហូតមានការរីកចម្រើនយ៉ាងខ្លាំងដូចបច្ចុប្បន្ន ។

៧. **ការកែទម្រង់រដ្ឋ**ដ៏ស៊ីជម្រៅប្រកបដោយភាពជោគជ័យ ធ្វើឲ្យការងារគ្រប់គ្រងរដ្ឋ គ្រប់គ្រងសង្គម គ្រប់គ្រងសេដ្ឋកិច្ច និងគ្រប់គ្រងធនធានធម្មជាតិកាន់តែមានប្រសិទ្ធភាពឡើង។

៨. **ស្តារកិត្តិយស កិត្យានុភាពជាតិ**នៃព្រះរាជាណាចក្រកម្ពុជាឡើវិញនៅលើឆាកអន្តរជាតិ ធ្វើឲ្យកម្ពុជាបានក្លាយជាប្រទេសដែលមានលក្ខណៈស្មើភាព និងស្មើសិទ្ធិជាមួយបណ្តាប្រទេសលើពិភពលោក មានទំនាក់ទំនងមិត្តភាព និងសហប្រតិបត្តិការល្អជាមួយគ្រប់ប្រទេស និងដៃគូអន្តរជាតិនានា ដែលជំរុញបានខ្លាំងក្លាការអភិវឌ្ឍន៍សង្គមជាតិ ។

ផ្នែកទី៤

# ២. សាវតារ ស្នាដៃធំៗជាប្រវត្តិសាស្ត្រ និងបទពិសោធន៍

## ក.សាវតារ

**គណបក្សប្រជាជនកម្ពុជា** មានឈ្មោះដើមថា **បក្សប្រជាជនបដិវត្តន៍ខ្មែរ** ដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១ ដោយមានប្រភពចេញពីចលនាតស៊ូស្នេហាជាតិរបស់ប្រជាជនកម្ពុជាប្រឆាំងអាណានិគមនិយមបារាំងដើម្បីឯករាជ្យជាតិ។

ប្រវត្តិសាស្ត្របានបង្ហាញច្បាស់ថា ក្នុងរយៈពេល ៦៦ ឆ្នាំ កន្លងមកនេះ គណបក្សប្រជាជនកម្ពុជាបានហែលឆ្លង និងប្រឈមនឹងការវិវត្តន៍ប្រែប្រួលយ៉ាងស្មុគស្មាញបំផុតនៃសភាពការណ៍ជាតិ និងអន្តរជាតិ ក៏គណបក្សបានផ្សារភ្ជាប់ខ្លួនជានិច្ច ជាមួយប្រជាជន និងពុះពារគ្រប់ឧបសគ្គ ក្នុងដំណាក់កាលប្រវត្តិសាស្ត្រជាតិប្រកបដោយវីរភាព។

**ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១**
បក្សប្រជាជនបដិវត្តន៍ខ្មែរ ដែលត្រូវបានបង្កើតឡើង

**១៩៥៣-១៩៧០**
ការតស៊ូប្រឆាំង **របបអាណានិគមនិយម** ដើម្បីឯករាជ្យជាតិ ដើម្បីឯករាជ្យជាតិ, ការពារឯករាជ្យ សន្តិភាព អព្យាក្រឹតភាព និងប្រឆាំងការជ្រៀតជ្រែករបស់បរទេស

**១៩៧០-១៩៧៥**
សង្គ្រាមបង្កដោយ **របបសាធារណរដ្ឋខ្មែរ** និងពួកបរទេសឈ្លានពាន

**១៩៧៥-១៩៧៩**
**របបកម្ពុជាប្រជាធិបតេយ្យ** ជារបបប្រល័យពូជសាសន៍ ឬទំព័រសករាជដ៏ខ្មៅងងឹតដែលបំផ្លាញរចនាសម្ព័ន្ធសង្គមជាតិឱ្យរលាយខ្ទេចខ្ទីដល់ឫសគល់ សិទ្ធិសេរីភាព

**១៩៧៩-១៩៩៣**
**រដ្ឋកម្ពុជា** ទំព័រសករាជថ្មី គឺឯករាជ្យ សេរីភាព ប្រជាធិបតេយ្យ និងវឌ្ឍនភាពសង្គម÷
១. មហាជ័យជម្នះ ៧មករា ឆ្នាំ១៩៧៩
២. សិទ្ធិសេរីភាព លទ្ធិប្រជាធិបតេយ្យ និងសេចក្ដីថ្លៃថ្នូរជូនប្រជាជន
៣. ការស្ដារ និងកសាងសេដ្ឋកិច្ច សង្គមចាប់ពីសូន្យ
៤. កម្លាំងស្នូលនៃការបង្រួបបង្រួមជាតិរហូតសម្រេចបានកិច្ចព្រមព្រៀងទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១

**១៩៩៣-២០១៧**
**ព្រះរាជាណាចក្រកម្ពុជា**
១. បន្ទប់ស្កាត់ការវិលត្រឡប់មកវិញនៃរបបប្រល័យពូជសាសន៍
២. ការពារកម្មសិទ្ធស្របច្បាប់របស់ប្រជាជន ការពារអាជីពរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ និងការពារកិច្ចសន្យាវិនិយោគទុនពីសម័យរដ្ឋកម្ពុជា
៣. ការពារប្រព័ន្ធប្រជាធិបតេយ្យសេរី ពហុបក្ស លើកកម្ពស់សិទ្ធមនុស្ស ការបោះឆ្នោតជាដើម
៤. ជោគជ័យនៃនយោបាយឈ្នះ ឈ្នះ និងការរំលាយទាំងស្រុងនាំអង្គការចាត់តាំងនយោបាយនិងយោធារបស់ ប៉ុល ពត និងការទទួលបានសន្តិភាពពេញលេញ
៥. អនុវត្តកំណែទម្រង់រដ្ឋដ៏ទូលំទូលាយ និងស៊ីជម្រៅ រួមមានកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់គ្រប់វិស័យដូចជា កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធមិ ការប្រឆាំងអំពើពុករលួយ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ...
៦. អភិវឌ្ឍសេដ្ឋកិច្ច សង្គមប្រកបដោយចីរភាព និងសមធមិ
៧. រក្សាសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមបានរឹងមាំ រាំងស្កាត់ឧបាយកលរបស់ពួកប្រឆាំង និងមជ្ឈដ្ឋានអគតិនានា
៨. លើកកម្ពស់កិត្តិយស កិត្យានុភាពនៃព្រះរាជាណាចក្រកម្ពុជាលើឆាកអន្តរជាតិ

## ៦.ស្នាដៃធំៗជាប្រវត្តិសាស្ត្ររបស់គណបក្សប្រជាជនកម្ពុជា

រយៈពេល ៣៦ ឆ្នាំ នៅលើកំណាត់ផ្លូវដ៏បត់បែនលំបាកស្មុគស្មាញ និងតស៊ូប្តូរផ្តាច់ គណបក្សប្រជាជនកម្ពុជា បានដឹកនាំប្រទេសឱ្យឈានទៅមុខជាជំហានៗ បង្កើតបានសមិទ្ធផលធំៗជាប្រវត្តិសាស្ត្រយ៉ាងច្រើន ជូនជាតិក្នុងបុព្វហេតុកសាង និងការពារមាតុភូមិ ការពារការរស់ឡើងវិញរបស់ប្រជាជាតិ និងការពាររាល់សមិទ្ធផលនៃសង្គមជាតិ។ រាល់ការប៉ុនប៉ងរបស់បណ្តាមជ្ឈដ្ឋានអន្តរជាតិ ដែលចង់នាំកម្ពុជាឱ្យវិលទៅរកអស្ថិរភាពវិញ សុទ្ធតែត្រូវទទួលបរាជ័យ។ ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជាប្រទេសជាតិបានឆ្លងកាត់ដំណាក់កាលស្តារឡើងវិញ ដោយជោគជ័យ ហើយកំពុងស្ថិតក្នុងជំហានថ្មីដ៏សំខាន់នៃដំណើរការអភិវឌ្ឍន៍របស់ខ្លួន។

ក្នុងការបំពេញបេសកកម្មបម្រើជាតិ គណបក្សប្រជាជនកម្ពុជាបានសម្រេចស្នាដៃធំៗជាប្រវត្តិសាស្ត្រគឺ៖

**ដំណាក់កាលពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣៖**

- បានវាយរំលំរបបប្រល័យពូជសាសន៍ប៉ុលពត ទទួលបានជ័យជម្នះជាប្រវត្តិសាស្ត្រ នាថ្ងៃ ៧ មករា ឆ្នាំ១៩៧៩ ដែលបានសង្គ្រោះជាតិឱ្យរស់ឡើងវិញ ទាន់ពេលវេលា ហើយបានប្រយុទ្ធទប់ស្កាត់មិនឱ្យរបបដ៏យង់ឃ្នងនេះ អាចវិលត្រឡប់មកវិញបាន ដើម្បីការពារការរស់ឡើងវិញរបស់ប្រជាជាតិ។
- បាននាំមកជូនប្រជាជនវិញ នូវសិទ្ធិសេរីភាពលទ្ធិប្រជាធិបតេយ្យកិត្តិយស និងសេចក្តីថ្លៃថ្នូរ ដែលត្រូវបាត់បង់ទាំងស្រុងក្នុងរបបប៉ុលពត។
- បានស្តារនិងកសាងសេដ្ឋកិច្ចសង្គមឡើងវិញ ចាប់ពីលេខសូន្យ ធ្វើឱ្យគ្រប់វិស័យបានរស់ឡើងវិញ ជីវភាពប្រជាជនត្រូវបានស្តារឱ្យមានស្ថិរភាពជាជំហានៗ ហើយបង្កបាននូវបុព្វបទ និងលក្ខណសម្បត្តិជាមូលដ្ឋានបំផុត សម្រាប់ការបន្តស្តារកសាង និងអភិវឌ្ឍប្រទេស រហូតមកដល់បច្ចុប្បន្ន។
- បានធ្វើជាកម្លាំងស្នូល ក្នុងដំណើរការស្វែងរកសន្តិភាព និងការបង្រួបបង្រួមជាតិ

រហូតសម្រេចបានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ស្តីពីដំណោះស្រាយនយោបាយបញ្ហាកម្ពុជា នាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ និងជាកម្លាំងបង្អែកដែលមិនអាចខ្វះបាន ក្នុងការអនុវត្តកិច្ចព្រមព្រៀងនេះ ព្រមទាំងការបង្កើតរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទីពីរ។

**ដំណាក់កាលពីឆ្នាំ១៩៩៣-២០១៤÷**

- បានការពារយ៉ាងគត់មត់ នូវរាល់សមិទ្ធផល នៃសង្គមជាតិ ការពាររដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទប់ស្កាត់ការប៉ុនប៉ងវិលត្រឡប់មកវិញ នៃរបបប្រល័យពូជសាសន៍ ថែរក្សាស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងនិរន្តរភាពនៃគ្រប់ស្ថាប័នរដ្ឋ។
- បានការពារកម្មសិទ្ធិស្របច្បាប់របស់ប្រជាជន ការពារអាជីពរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ និងការពាររាល់កិច្ចសន្យាវិនិយោគទុន ពីសម័យរដ្ឋកម្ពុជា។
- បានការពារ ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា ឱ្យរីកចម្រើនឥតឈប់ឈរ លើកកម្ពស់ការគោរពសិទ្ធិមនុស្ស សមភាពយេនឌ័រ សម្រេចបានការបោះឆ្នោតជាបន្តបន្ទាប់ ប្រកបដោយលក្ខណៈសេរីត្រឹមត្រូវ និងយុត្តិធម៌។ ការពារលទ្ធផលនៃការបោះឆ្នោត រក្សាស្ថិរភាពនៃរាជបល្ល័ង្ក និងសម្រេចការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលបានធានាឱ្យប្រទេសជាតិមានស្ថិរភាព និងបន្តឈានទៅមុខយ៉ាងត្រឹមត្រូវ តាមគន្លងនៃលទ្ធិប្រជាធិបតេយ្យនិងនីតិរដ្ឋ។
- បានធ្វើឱ្យទឹកដីទាំងមូល ទទួលបានសន្តិភាពពេញលេញ និងការបង្រួបបង្រួមជាតិ ចាប់ពីចុងឆ្នាំ១៩៩៨ មក តាមរយៈនយោបាយឈ្នះឈ្នះ ដឹកនាំដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដែលបានធ្វើឱ្យអង្គការចាត់តាំង នៃរបបប៉ុលពត ត្រូវរលាយទាំងស្រុង ទាំងខាងនយោបាយ និងយោធា បញ្ចប់ទាំងស្រុងនូវសង្គ្រាមដ៏រ៉ាំរ៉ៃ ហើយបានធ្វើសមាហរណកម្មប្រជាជនកម្ពុជា ដែលបែកបាក់ព្រាត់ប្រាសក្នុងសង្គ្រាមឱ្យបានវិលត្រឡប់ មករួមរស់ក្នុងសង្គមជាតិវិញ ប្រកប

ដោយភាពសុខដុមរមនា មានស្ថិរភាពនិងការអភិវឌ្ឍ។

- បានអនុវត្តប្រកបដោយផ្លែផ្កា នូវកំណែទម្រង់រដ្ឋដ៏ស៊ីជម្រៅ និងទូលំទូលាយដែលរួមមានកំណែទម្រង់រដ្ឋបាលសាធារណៈ ការប្រឆាំងអំពើពុករលួយ កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់ជលផល ដីធ្លី ការគ្រប់គ្រងព្រៃឈើធនធានធម្មជាតិនិងបរិស្ថាន ប្រកបដោយនិរន្តរភាព។
- បានស្តារនិងអភិវឌ្ឍសេដ្ឋកិច្ច ឱ្យសម្រេចបានកំណើនជារៀងរាល់ឆ្នាំ ប្រកបដោយចីរភាព ធ្វើឱ្យជីវភាពរបស់ប្រជាជនបានប្រសើរឡើងជាលំដាប់ ហើយភាពក្រីក្រត្រូវបានកាត់បន្ថយជាបន្តបន្ទាប់។ ទាក់ទាញបានអ្នកវិនិយោគកាន់តែច្រើនមកបណ្តាក់ទុក ដែលបានបង្កើនការងារ មុខរបរ និងចំណូលជូនប្រជាជន។ កសាងសមិទ្ធផល លើគ្រប់វិស័យយ៉ាងច្រើនអនេកនៅគ្រប់ទិសទី។ កម្ពុជាត្រូវបានវាយតម្លៃថាជាប្រទេសទី៥ ក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍ ដែលអាចនឹងសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ឆ្នាំ២០១៥ និងស្ថិតក្នុងចំណាត់ថ្នាក់ទី១ នៅអាស៊ីប៉ាស៊ីហ្វិក ដែលបានសម្រេចវឌ្ឍនភាពល្អប្រសើរ ក្នុងការកែលម្អសូចនាករផ្នែកសង្គមកិច្ច។ ថ្មីៗនេះ ធនាគារពិភពលោកបានចាត់បញ្ចូលប្រទេសកម្ពុជានៅក្នុងក្រុមប្រទេស ដែលមានកំណើនគួរឱ្យស្ងប់ស្ងែង ដោយសម្រេចបានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យម ៧,៧ % ក្នុងរយៈពេល ២ ទសវត្សចុងក្រោយ និងបានធ្វើឱ្យកម្ពុជា ក្លាយជាប្រទេសមានកំណើនសេដ្ឋកិច្ចលឿនបំផុតលំដាប់ទី៦នៅលើពិភពលោក។ ក្នុងរយៈពេលមធ្យមទៅមុខទៀត សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងបន្តកើនក្នុងរង្វង់ ៧ % ក្នុងមួយឆ្នាំ។

សរុបមករយៈពេល ៣៦ ឆ្នាំ កន្លងមកនេះ ផ្តើមពីជ័យជម្នះ ៧មករា ព្រះរាជាណាចក្រកម្ពុជាមានការផ្លាស់ប្តូរយ៉ាងធំធេង ដែលមិននឹកស្មានដល់។ ពីទឹកដីមួយដែលនៅសល់តែ

គំនរផេះផង់ ស្លាកស្នាមនៃសង្គ្រាម និងអំពើប្រល័យពូជសាសន៍ បានក្លាយមកជាទឹកដីកំពុងមានការអភិវឌ្ឍប្រកបដោយល្បឿនលឿននិងចីរភាព។ កម្ពុជាដែលធ្លាប់ត្រូវគ្របដណ្តប់ ដោយអស្ថិរភាព សង្គ្រាមរ៉ាំរ៉ៃ ឧក្រិដ្ឋកម្ម និងការបែកបាក់ បានប្រែក្លាយជាទឹកដីប្រកបដោយសន្តិភាព ស្ថិរភាព ការរួបរួមជាតិ ប្រជាធិបតេយ្យ និងនីតិរដ្ឋ ធ្វើឱ្យប្រជាជនបានរស់នៅយ៉ាងសុខដុមរមនា។ ព្រមជាមួយនេះ កិត្យានុភាពជាតិ ដែលត្រូវបាត់បង់ក៏ត្រូវបានស្តារ និងលើកកម្ពស់ឡើងវិញ ប្រកបដោយមោទនភាព។

**គ.ភ្ជាប់ជាប់មេរៀនពិសោធន៍នៃការដឹកនាំរបស់គណបក្ស**

ឆ្លងតាមជ័យជម្នះដ៏ត្រចះត្រចង់ ក្នុងរយៈពេល ៣៦ ឆ្នាំ មកនេះ គណបក្សដកស្រង់បាននូវមេរៀនពិសោធន៍ធំៗនៃជ័យជម្នះ ដូចខាងក្រោម÷

**ទី១.** គណបក្សត្រូវខិតខំកសាងខ្លួន ឱ្យបានរឹងមាំទាំងខាងនយោបាយសតិអារម្មណ៍ និងចាត់តាំង ដោយចាត់ទុកការងារនេះជាការងារដែលមានអត្ថន័យកំណត់ចំពោះជោគជ័យរបស់គណបក្ស។ គណបក្សនយោបាយឈានមុខមួយ គឺត្រូវមានកម្មវិធីនយោបាយត្រឹមត្រូវ មានយុទ្ធសាស្ត្ររឹងមាំ និងយុទ្ធវិធីដ៏រស់រវើក មានភាពនឹងនរនៅគ្រប់កាលៈទេសៈ និងស្ថានភាព មានសេចក្តីសម្រេចចិត្តលើបញ្ហានីមួយៗបានត្រឹមត្រូវ ដែលឆ្លើយតបទៅនឹងសភាពការណ៍ជាក់ស្តែង។ នយោបាយគណបក្សទាំងក្នុងប្រទេស និងក្រៅប្រទេស ផ្អែកលើមូលដ្ឋានឧត្តមគតិស្នេហាជាតិ ស្រឡាញ់ប្រជាជន មនសិការ លើកស្ទួយលទ្ធិប្រជាធិបតេយ្យ និងការបើកទូលាយទំនាក់ទំនងជាមួយគ្រប់ប្រទេស ហើយត្រូវអនុលោមតាមលក្ខណៈពិសេសជាក់ស្តែងរបស់កម្ពុជា និងសភាពការណ៍អន្តរជាតិ។ មាននយោបាយត្រឹមត្រូវ ហើយគណបក្សទាំងមូលត្រូវមានការឯកភាពខ្ពស់ ខាងទស្សនៈសតិអារម្មណ៍ ដោយឈរលើមូលដ្ឋានកម្មវិធីនយោបាយ លក្ខន្តិកៈ គោលការណ៍ និងសេចក្តីសម្រេចចិត្តផ្សេងៗរបស់គណបក្ស។ ព្រមជាមួយនេះ គណបក្សត្រូវមានអង្គការចាត់តាំងរឹងមាំនៅគ្រប់ថ្នាក់គ្រប់ផ្នែក ដើម្បីចាត់តាំងសកម្មភាព ប្រែក្លាយការឯកភាពទស្សនៈសតិអារម្មណ៍ទៅជាកម្លាំងសាមគ្គីភាពដ៏ខ្លាំងក្លា ក្នុងការអនុវត្តរាល់ទិសដៅភារកិច្ចរបស់គណបក្ស។

**ទី២.** គណបក្សត្រូវផ្សារភ្ជាប់ជាមួយប្រជាជន បម្រើប្រជាជនអស់ពីចិត្តពីថ្លើម ខិតខំចលនាប្រជាជនឱ្យចូលរួមអនុវត្តទិសដៅភារកិច្ចរបស់គណបក្ស ពីព្រោះប្រជាជនជាប្រភពកម្លាំងមិនចេះរីងស្ងួត និងជាកត្តាសម្រេចនៃជោគជ័យរបស់គណបក្ស នៅគ្រប់កាលៈទេសៈ។ បុព្វហេតុរបស់គណបក្ស គឺបម្រើផលប្រយោជន៍ជាតិនិងប្រជាជន គ្មានអ្វីក្រៅពីនេះឡើយ។ ប៉ុន្តែបុព្វហេតុនេះធំធេងណាស់ បើគ្មានការចូលរួមពីសំណាក់ប្រជាជនមហាជនដ៏ច្រើនកុះករទេនោះ ទោះបីគណបក្សមានកម្មវិធីនយោបាយល្អត្រឹមត្រូវយ៉ាងណាក្តី ក៏គណបក្សមិនអាចនិងសម្រេចគោលបំណងរបស់ខ្លួនបានដែរ។ អាស្រ័យហេតុនេះ ជានិច្ចកាល គណបក្សតែងអប់រំណែនាំដល់មន្ត្រីគ្រប់រូប ត្រូវស្មោះត្រង់និងផ្សារភ្ជាប់ជាមួយមហាជនប្រជាជន នៅគ្រប់ស្រទាប់គ្រប់មូលដ្ឋាន យល់ដឹងអំពីសុខទុក្ខបំណងប្រាថ្នារបស់ប្រជាជន ខិតខំអប់រំប្រជាជន ឱ្យយល់ច្បាស់អំពីនយោបាយរបស់គណបក្ស ហើយបំផុសលើកទឹកចិត្តនិងចាត់តាំងមហាជនចូលរួមអនុវត្ត ប្រកបដោយមនសិការភ្ញាក់រលឹក។ ពីមុនក៏ដូចបច្ចុប្បន្ន គណបក្សអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវទិសស្លោក÷ "ទីណាប្រជាជនមានការលំបាក ទីនោះមានគណបក្សប្រជាជនកម្ពុជានៅជាមួយ"។ អាស្រ័យហេតុនេះហើយទើបគណបក្សបានទទួលការជឿជាក់ និងការគាំទ្រយ៉ាងទូលំទូលាយពីប្រជាជន។

**ទី៣.** គណបក្សត្រូវមានវិន័យម៉ឺងម៉ាត់ និងរបៀបរបបធ្វើការច្បាស់លាស់ ទើបធានាបាននូវកម្លាំងប្រយុទ្ធនិងប្រសិទ្ធភាព ក្នុងការអនុវត្តរាល់គោលការណ៍ គោលនយោបាយរបស់គណបក្ស។ គណបក្សនយោបាយមួយ ដែលខ្វះវិន័យ គឺមិនអាចសម្រេចកិច្ចការរបស់ខ្លួនបានឡើយ សូម្បីតែកិច្ចការមួយដ៏តូចដ៏ដោយ។ ភារកិច្ចរបស់គណបក្សមានទំហំធំធេងមានចរិតលំបាកស្មុគស្មាញ និងប្តូរផ្តាច់ណាស់ ដែលថ្នាក់នីមួយ និងមន្ត្រីម្នាក់ៗ មិនអាចធ្វើលំៗ ដោយគ្មានការយល់ដឹង គ្មានការព្យាយាម តាំងចិត្ត និងមិនគោរពគោលការណ៍របស់គណបក្សនោះបានឡើយ។ ប្រសិនបើមន្ត្រីម្នាក់ៗ ឬអង្គការចាត់តាំងនៅថ្នាក់នីមួយៗធ្វើអ្វីៗ តាមតែទំនើងចិត្តនោះ វានឹងបង្កើតស្ថានភាពអនាធិបតេយ្យ ក្នុងគណបក្សធ្វើឱ្យគណបក្សចុះខ្សោយហើយប្រជាជននឹងបាត់បង់ជំនឿទុកចិត្ត។ វិន័យគណបក្សមិនរារាំង

ការអនុវត្តប្រជាធិបតេយ្យផ្ទៃក្នុងបក្សឡើយ ផ្ទុយទៅវិញគឺធានាប្រជាធិបតេយ្យនៅក្នុងបក្ស។ វិន័យគណបក្សជាវិន័យភ្ជាក់រលឹកផ្នែកលើមូលដ្ឋានលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង គោលការណ៍ និងសេចក្តីកំណត់នានារបស់គណបក្ស។ ទន្ទឹមនេះ គណបក្សគ្រប់ថ្នាក់ គ្រប់ផ្នែក ត្រូវមានរបៀបរបបធ្វើការច្បាស់លាស់ រួមមាន របបសន្និបាត របបប្រជុំ របបរៀនសូត្រ របបចុះមូលដ្ឋាន របបត្រួតពិនិត្យការងារ និងរបបរាយការណ៍សុំមតិ។

**ទី៤.** គណបក្សត្រូវផ្អែកលើអំពើល្អរបស់មន្ត្រី បរិមាណនិងគុណភាពរបស់សមាជិកគណបក្សដើម្បីឈ្នះឆ្នោត។ ក្នុងប្រព័ន្ធនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ការបោះឆ្នោត គឺជាសមរភូមិប្រកួតប្រជែងខាងនយោបាយដ៏ស្រួចស្រាល់បំផុត ដើម្បីទទួលបាននូវតួនាទីដឹកនាំសង្គមជាតិ តាមរយៈឆន្ទៈរបស់ប្រជាជន។ ជោគជ័យនៅក្នុងការបោះឆ្នោតមួយ គឺបានមកពីការរួមផ្សំ នៃកត្តាធំៗជាច្រើន ជាពិសេសគឺភាពរឹងមាំនៃជួរសមាជិកនិងអំពើល្អរបស់មន្ត្រីគណបក្ស ក្នុងការអនុវត្តរាល់ភារកិច្ចដែលបានប្រគល់ឱ្យ។ គណបក្សមានសមាជិករាប់លាននាក់ និងជួរមន្ត្រីដ៏ច្រើនកុះករ ប៉ុន្តែបើសមាជិកបក្សគ្មានគោលជំហររឹងមាំ ហើយមន្ត្រីខ្វះភាពស្មោះត្រង់ ចំពោះគណបក្ស ចំពោះប្រជាជននិងមិនចេះសម្រេចភារកិច្ចរបស់ខ្លួន ក្នុងការអនុវត្តគោលនយោបាយរបស់គណបក្សទេនោះ គឺគណបក្សពិតជាមិនអាចទទួលជោគជ័យក្នុងការបោះឆ្នោតបានឡើយ។ អាស្រ័យហេតុនេះ ត្រូវយកចិត្តទុកដាក់ការងារគ្រប់គ្រងសមាជិកគណបក្សឱ្យបានរឹងមាំ ទាំងខាងនយោបាយសតិអារម្មណ៍ និងចាត់តាំង ហើយខិតខំលើកកម្ពស់គុណធម៌ និងសមត្ថភាពរបស់មន្ត្រីគណបក្សឱ្យបានជាប្រចាំ ត្រូវទប់ស្កាត់ឱ្យទាន់ពេលវេលា ចំពោះសកម្មភាពរបស់មន្ត្រីណា ដែលធ្វើខុសពីគោលការណ៍គណបក្ស បំពានលើច្បាប់រដ្ឋ ប៉ះពាល់ផលប្រយោជន៍សាធារណៈនិងប្រជាជន។ មន្ត្រីដែលប្រព្រឹត្តខុសគោលការណ៍គណបក្ស ត្រូវទទួលរងវិន័យរបស់គណបក្ស មន្ត្រីណាដែលប្រព្រឹត្តខុសច្បាប់រដ្ឋ ត្រូវទទួលទោសតាមច្បាប់របស់រដ្ឋ ធ្វើដូច្នេះទើបអាចការពារគណបក្សបាន។

**ទី៥.** គណបក្សត្រូវថែរក្សាសាមគ្គីភាពឯកភាពផ្ទៃក្នុង ឱ្យបានរឹងមាំនៅគ្រប់កាលៈទេសៈ

ផ្នែកទី១

និងគ្រប់ស្ថានភាព។ សាមគ្គីភាព ឯកភាពផ្ទៃក្នុងមុនបង្អស់ក្នុងក្បាលម៉ាស៊ីនដឹកនាំ របស់គណបក្សជាកត្តាស្លាប់រស់សម្រាប់គណបក្ស ជាមូលហេតុចម្បងនៃជោគជ័យរបស់គណ-បក្សនៅគ្រប់ដំណាក់កាល និងជាស្នូលនៃកម្លាំងមហាសាមគ្គីរបស់ប្រជាជនទាំងមូល គ្រប់ជនជាតិដើម្បីកសាងនិងការពារមាតុភូមិ។ ពួកអមិត្តបានចិញ្ចឹមទុកជានិច្ចនូវគោលបំណងផ្តួលរំលំគណបក្សយើង ពួកគេតែងព្យាយាមរកគ្រប់វិធីដើម្បីបំផ្លាញផ្លូងសាមគ្គីភាពឯកភាពផ្ទៃក្នុងគណបក្សយើង។ ចំពោះយើង សាមគ្គីភាព ឯកភាពផ្ទៃក្នុងគណបក្ស ត្រូវផ្អែកលើមូលដ្ឋានកម្មវិធីនយោបាយ លក្ខន្តិកៈ បទបញ្ញាផ្ទៃក្នុង គោលការណ៍ និងសេចក្តីសម្រេចចិត្តនានារបស់គណបក្ស ព្រមទាំងត្រូវខិតខំថែរក្សាពួនជ្រំជានិច្ច នូវមនោសញ្ចេតនាគោរពស្រឡាញ់ ចេះយោគយល់អធ្យាស្រ័យគ្នា និងជួយដោះស្រាយទុក្ខធុរៈគ្នា ក្នុងជួរមន្ត្រីនិងសមាជិកគណបក្ស។ ក្នុងនោះ ប្រការមួយយ៉ាងសំខាន់ គឺការអនុវត្តយ៉ាងម៉ត់ចត់នូវរបបសមូហភាពដឹកនាំម្នាក់ៗទទួលខុសត្រូវ ដែលធ្វើឱ្យគណបក្សគ្រប់ថ្នាក់ គ្រប់ផ្នែក ពង្រឹងពង្រីកបានឥតឈប់ឈរ នូវបញ្ញាញាណរួមប្រជាធិបតេយ្យផ្ទៃក្នុង និងវិន័យដ៏ម៉ឺងម៉ាត់។

**ទី៦.** គណបក្សត្រូវចេះគួបផ្សំឱ្យបានល្អ រវាងផលប្រយោជន៍ជាតិនិងផលប្រយោជន៍អន្តរជាតិ ទាំងក្នុងក្របខ័ណ្ឌតំបន់ ក៏ដូចពិភពលោក ដោយឈរលើមូលដ្ឋានការពារឯករាជ្យនិងអធិបតេយ្យជាតិ ឱ្យបានគត់មត់ សំដៅពង្រីកកម្លាំងសម្រេចភារកិច្ចរបស់គណបក្សនៅក្នុងដំណាក់កាលនីមួយៗ។ ទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ស្មោះសរជាមួយគ្នារវាងប្រជាជាតិយើង និងបណ្តាប្រជាជាតិ ជាពិសេសប្រជាជាតិជិតខាងភូមិផងរបងជាមួយ ដែលធ្លាប់មានប្រពៃណីដ៏យូរលង់ គឺជាកត្តាសំខាន់ចាំបាច់មិនអាចខ្វះបានដើម្បីធានាការស្ថិតស្ថេរនិងរីកចម្រើនរបស់ជាតិយើង។ ការពិតជាក់ស្តែង បានបង្ហាញច្បាស់ថា ជ័យជម្នះដែលយើងសម្រេចបានក្នុងរយៈពេល ៣៦ ឆ្នាំ តាំងពីដំណាក់កាលសង្គ្រោះជាតិ ពីរបបប្រល័យពូជសាសន៍មក គឺមិនអាចកាត់ផ្តាច់ពីការជួយឧបត្ថម្ភគាំទ្ររបស់បណ្តាប្រទេសជាមិត្ត និងសហគមន៍អន្តរជាតិបានឡើយ។ ព្រមជាមួយនោះ ប្រវត្តិសាស្ត្រក៏បានបង្រៀនឱ្យយើងយល់ច្បាស់ថា នៅពេលដែលប្រជាជាតិយើងត្រូវបាត់បង់ឯករាជ្យ

និងអធិបតេយ្យជាតិ នៅពេលនោះប្រជាជាតិយើងត្រូវធ្លាក់ចូលក្នុងភ្លើងសង្គ្រាមដ៏មហន្តរាយបំផុត។ អាស្រ័យហេតុនេះ ត្រូវខិតខំពង្រឹងខឿនឯករាជ្យ អធិបតេយ្យជាតិ ថែរក្សាពួនជ្រំចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការ ជាមួយបណ្តាប្រទេសនិងអង្គការអន្តរជាតិនានា ឱ្យកាន់តែរឹងមាំ ស្រស់បំព្រងឡើងជានិច្ច ដើម្បីជោគជ័យនៃបុព្វហេតុកសាងនិងការពារមាតុភូមិយើងផង និងរួមចំណែកយ៉ាងសកម្មដល់កិច្ចការអន្តរជាតិផង។

# ៣. សភាពការណ៍កម្ពុជា និងបណ្ដាភារកិច្ចចំពោះមុខ

ឯកសារនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងបង្កើនចំណេះដឹងចាំបាច់បន្ថែមមួយចំនួនអំពីសភាពការណ៍កម្ពុជាតាមដំណាក់កាលធំៗពីឆ្នាំ១៩៧៩ (ឆ្នាំនៃមហាជ័យជម្នះជាប្រវត្តិសាស្ត្រនៃការផ្ដួលរំលំរបបប្រល័យពូជសាសន៍ប៉ុលពត) ដល់បច្ចុប្បន្នព្រមទាំងបណ្ដាភារកិច្ចចំពោះមុខ។

## ក. ដំណាក់កាលធំៗបី នៃសភាពការណ៍កម្ពុជា ពីឆ្នាំ១៩៧៩ មកដល់បច្ចុប្បន្ន



## ២. ចំណុចសំខាន់ៗនៃសភាពការណ៍កម្ពុជាឆ្នាំ ២០១៣-២០១៥

ផ្អែកតាមលទ្ធផលនៃការបោះឆ្នោត រដ្ឋសភានីតិកាលទី៥ ត្រូវបានបង្កើតឡើង ដោយសម័យប្រជុំលើកដំបូងរបស់ខ្លួនប្រព្រឹត្តទៅតាមការកំណត់នៃរដ្ឋធម្មនុញ្ញទោះពុំមានវត្តមានគណបក្សប្រឆាំងក៏ដោយ។ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ រដ្ឋសភា បានបោះឆ្នោតជ្រើសតាំងក្បាលម៉ាស៊ីនរបស់ខ្លួន ដែលមាន **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ជាប្រធាន និងបានអនុម័តផ្តល់សេចក្តីទុកចិត្តលើរាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥ ដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រី។

សភាពការណ៍កម្ពុជាឆ្នាំ២០១៣-២០១៤ មានលក្ខណៈតានតឹងស្មុគស្មាញ និងប្រកបដោយគ្រោះថ្នាក់ ដោយសារ ក្រុមប្រឆាំងដែលមានការគាំទ្រនិងលើកទឹកចិត្តពីមជ្ឈដ្ឋានអគតិខាងក្រៅ បានជំរុញសកម្មភាពប្រឆាំងយ៉ាងខ្លាំងក្លា សំដៅបំផ្លាញរាល់សមិទ្ធផលរបស់រាជរដ្ឋាភិបាល ក្នុងចេតនារំលំរាជរដ្ឋាភិបាល និងធ្វើឱ្យចុះខ្សោយនូវមូលដ្ឋានគាំទ្ររបស់គណបក្សប្រជាជនកម្ពុជា ដោយប្រើយុទ្ធសាស្ត្រជំរុញឱ្យមាន "ការផ្លាស់ប្តូរ" របស់ពួកគេ ជាពិសេស "បដិវត្តន៍ពណ៌ ឬអំណាចប្រជាជនតាមដងផ្លូវ" រហូតកើតមានចលនាកុប្បកម្មដ៏ហិង្សា ដែលបានបំផ្លាញទ្រព្យសម្បត្តិសាធារណៈ និងឯកជនព្រមទាំងបង្កឱ្យមានមនុស្សស្លាប់និងរបួសជាច្រើននាក់។

ប្រឈមនឹងសភាពការណ៍ស្មុគស្មាញក្រោយពេលបោះឆ្នោត គណបក្សប្រជាជនកម្ពុជា បានដាក់ចេញនូវយុទ្ធសាស្ត្រ ៣ ចំណុច គឺ **យុទ្ធសាស្ត្រផ្នែកកិច្ចការនយោបាយសន្តិសុខសណ្តាប់ធ្នាប់សង្គម យុទ្ធសាស្ត្រផ្នែកការងារបរទេស និងយុទ្ធសាស្ត្រផ្នែកសេដ្ឋកិច្ចសង្គមកិច្ច**" ព្រមទាំងប្រឹងប្រែងស្វែងរកដំណោះស្រាយជាមួយគណបក្សប្រឆាំងដោយប្រកាន់ជំហរប្រកបដោយសុឆន្ទៈ និងអត់ធ្មត់ ខិតខំធ្វើការសម្របសម្រួល និងសម្បទានយ៉ាងច្រើន រហូតដល់សម្រេចបានកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយនាថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ។

តាមរយៈការអនុវត្តកិច្ចព្រមព្រៀងខាងលើនេះ គណបក្សទាំងពីរ បានសម្រេចធ្វើ

វិសោធនកម្មរដ្ឋធម្មនុញ្ញនិងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ការបង្កើតយន្តការងាររវាងគណបក្សសំឡេងភាគច្រើន និងគណបក្សសំឡេងភាគតិចក្នុងរដ្ឋសភា ការកសាងច្បាប់គ្រឹះមួយចំនួនពាក់ព័ន្ធការបោះឆ្នោត។ នៅថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៥ សម្ដេចតេជោ ហ៊ុន សែន បានប្រកាសថា "នយោបាយទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី ត្រូវបញ្ចប់ ដែលយើងគ្មានជម្រើសណាក្រៅពីរួមរស់ជាមួយគ្នា ទោះយើងមានទស្សនៈខុសគ្នា ប៉ុន្តែយើងជាខ្មែរដូចគ្នា ដែលត្រូវរស់នៅលើទឹកដីដ៏កម្សត់នេះ ហើយមានភារកិច្ចកសាងទឹកដីនេះ ឱ្យក្លាយទៅជាទឹកដីសម្បូរសប្បាយ ប្រជាជនទទួលសេចក្ដីសុខ។

បន្តបន្ទាប់មកទៀត គណបក្សប្រឆាំង ដែលមានការលើកទឹកចិត្តពីមជ្ឈដ្ឋានអគតិមួយចំនួន នៅតែមានឧបាយកលដ៏ពិសពុលប៉ុនប៉ងផ្ដួលរំលំគណបក្សប្រជាជនកម្ពុជា ដើម្បីសម្រេចយុទ្ធសាស្ត្រផ្លាស់ប្ដូររបស់ពួកគេ ជាអាទិ៍ ការវាយប្រហារមកលើគណបក្សប្រជាជនកម្ពុជា តាមបណ្ដាញសង្គម តាមវេទិកាសាធារណៈ ការបំផុសគំនិតឱ្យមានកំហឹងវណ្ណៈសង្គម ការគុំកួននៅផ្ទៃក្នុងសង្គមជាតិ និងបំផុតគំនិតជាតិនិយម ជាពិសេសការឃោសនាមួលបង្កាច់លើបញ្ហាផែនទី និងព្រំដែន ព្រមទាំងព្យាយាមប្រើហិង្សាដើម្បីកុំឱ្យមានការបោះឆ្នោតសកលឆ្នាំ២០១៨ និងអំពាវនាវសហគមន៍អន្តរជាតិគាបសង្កត់រាជរដ្ឋាភិបាល តាមវិធីសាស្ត្រមួលបង្កាច់។ ប៉ុន្តែ ឧបាយកលទាំងនេះ មិនបានសម្រេចឡើយ ដោយធ្វើឱ្យពួកប្រឆាំងកាន់តែចុះខ្សោយ។

ទោះបីត្រូវប្រឈមនឹងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល គ្រោះធម្មជាតិ និងការរំខានខ្លះពីស្ថានទនយោយបាយក្នុងប្រទេសក្ដី ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ឆ្នាំ២០១៣-២០១៤ ទទួលបានលទ្ធផលល្អ ដែលសេដ្ឋកិច្ចកម្ពុជាមានកំណើនជាមធ្យម ៧ % ក្នុងមួយឆ្នាំ។

## គ. បណ្ដាភារកិច្ចចំពោះមុខ

ដើម្បីសម្រេចភារកិច្ចរួមជាយុទ្ធសាស្ត្រជាអាទិ៍ ការពង្រឹងរាល់អង្គការចាត់តាំងបក្ស, ការខិតខំចលនាមហាជនក្នុងការការពារសមិទ្ធផលនៃសង្គមជាតិ, ការទប់ស្កាត់ឧបាយកល

បំផ្លិចបំផ្លាញពីគ្រប់មជ្ឈដ្ឋានអគតិ, ការពង្រឹងការឯកភាពផ្ទៃក្នុងគណបក្ស, ការខិតខំអនុវត្តកំណែទម្រង់ដ៏ទូលំទូលាយនិងស៊ីជម្រៅ ព្រមទាំងការប្ដេជ្ញាជាយុទ្ធសាស្ត្ររបស់គណបក្សគឺការបង្កើនប្រៀបឈ្នះក្នុងការបោះឆ្នោតជាតិនីតិកាលទី៦ នាឆ្នាំ២០១៨ ខាងមុខនេះ សន្និបាតគណៈកម្មាធិការកណ្ដាលលើកទី៣៩ បានណែនាំគណបក្សគ្រប់ថ្នាក់ គ្រប់ផ្នែក មន្ត្រីគណបក្សគ្រប់រូបត្រូវយកចិត្តទុកដាក់អនុវត្តបណ្ដាទិសដៅភារកិច្ចសំខាន់ៗ ចំពោះមុខ ដូចខាងក្រោម÷

**ទិសដៅទាក់ទងនឹងការងារទូទៅ**

១. បន្តពង្រឹងខឿនការពារជាតិឱ្យកាន់តែរឹងមាំ ដើម្បីធានាការពារសន្តិភាព ឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី ព្រមទាំងខិតខំកសាងតំបន់ព្រំដែនជាតំបន់មានសន្តិភាព មិត្តភាព សហប្រតិបត្តិការ និងអភិវឌ្ឍន៍។

២. លើកកម្ពស់លទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស និងសិទ្ធិសេរីភាពប្រជាពលរដ្ឋ ដោយឈរលើមូលដ្ឋាននីតិរដ្ឋ។

៣. បន្តជំរុញការអនុវត្តកំណែទម្រង់នានារបស់រាជរដ្ឋាភិបាល ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ តាមអភិក្រម "ឆ្លុះកញ្ចក់ មុជទឹក ដុសក្អែល និងព្យាបាល"។

៤. ជំរុញដំណើរអភិវឌ្ឍសេដ្ឋកិច្ចឱ្យសម្រេចបានទិសដៅកំណើនក្នុងរង្វង់ ៧% ដោយជំរុញការបែងចែកផ្លែផ្កានៃកំណើនប្រកបដោយសមធម៌ និងកាត់បន្ថយភាពក្រីក្រជាង ១% ក្នុងមួយឆ្នាំ។

៥. បន្តយកចិត្តទុកដាក់ពង្រឹងប្រព័ន្ធគាំពារសង្គម និងបង្កើតឱ្យមានប្រព័ន្ធគាំពារសង្គមផ្លូវការមួយ។

**ទិសដៅការងារគណបក្ស**

១. បន្តជំរុញការអនុវត្ត "កិច្ចព្រមព្រៀងស្ដីពីដំណោះស្រាយនយោបាយ ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ និងវប្បធម៌សន្ទនា រវាងគណបក្សដែលមានអាសនៈក្នុងរដ្ឋសភា ក៏ដូចជាជំរុញកិច្ចសហប្រតិបត្តិការជាមួយគណបក្សនយោបាយនានា អង្គការសង្គមស៊ីវិល

និងមជ្ឈដ្ឋានផ្សេងៗក្នុងសង្គម។

២. បង្កើនការងារអប់រំនយោបាយ សតិអារម្មណ៍ ដើម្បីឱ្យសមាជិកបក្ស ក៏ដូចជាប្រជាពលរដ្ឋ មានជំនឿជាក់មកលើការដឹកនាំរបស់គណបក្ស។

៣. បន្តកសាងពង្រឹងអង្គការចាត់តាំងគណបក្សគ្រប់ថ្នាក់ឱ្យមានរចនាសម្ព័ន្ធគ្រប់គ្រាន់ទាំងក្នុងនិងក្រៅប្រទេស និងមានសមត្ថភាពអនុវត្តបានល្អនូវតួនាទី ភារកិច្ច សិទ្ធិ និងរបៀបរបបការងាររបស់ខ្លួន។ ពង្រីកប្រជាធិបតេយ្យផ្ទៃក្នុង ដោយប្រកាន់ខ្ជាប់គោលការណ៍សមូហភាពដឹកនាំ ម្នាក់ៗទទួលខុសត្រូវ។

៤. បង្កើនការងារចលនាមហាជនឱ្យបានខ្លាំងក្លា នៅគ្រប់ស្រទាប់ប្រជាជន និងគ្រប់មជ្ឈដ្ឋានក្នុងសង្គម។

៥. ក្តាប់ជាប់សារៈសំខាន់នៃការបោះឆ្នោត ដើម្បីធានារក្សាប្រៀបឈ្នះរបស់គណបក្ស។

សម្រាប់កិច្ចការនេះ ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជា ប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមការដឹកនាំរបស់ឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន** ប្រធានក្រុមការងារយុវជន បានដឹកនាំ និងសម្របសម្រួល ដើម្បីសម្រេចបានសមិទ្ធផលនេះឡើង ដែលមានសមាសភាព ដូចតទៅ÷

| | |
|---|---|
| ១. ឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន** | ប្រធាន |
| ២. ឯកឧត្តម **មាស សុខសេនសាន** | អនុប្រធាន |
| ៣. ឯកឧត្តម **វង្ស ប៊ុនឥន្ទ្រាវុធ** | អនុប្រធាន |
| ៤. ឯកឧត្តម **ម៉ិញ ឃានកុសល** | អនុប្រធាន |
| ៥. លោក **ហាក់ សុទ្ធា** | អនុប្រធាន |
| ៦. ឯកឧត្តម **យ៉េត វីណែល** | អនុប្រធានប្រចាំការ |
| ៧. លោក **នុប សុធនវិចិត្រ** | សមាជិក |
| ៨. ឯកឧត្តម **នេត មុន្នី** | សមាជិក |
| ៩. ឯកឧត្តម **អ៊ឹម សិទ្ធីរ៉ា** | សមាជិក |
| ១០. ឯកឧត្តម **ឆាយ រតនៈ** | សមាជិក |
| ១១. ឯកឧត្តម **កៅ ថាច** | សមាជិក |
| ១២. ឯកឧត្តម **សៀង ធីរិទ្ធ** | សមាជិក |
| ១៣. ឯកឧត្តម **ស៊ាង ផល្លា** | សមាជិក |
| ១៤. លោក **អេង ទូច** | សមាជិក |
| ១៥. លោក **សេង ស្រេង** | សមាជិក |
| ១៦. លោក **អ៊ុន មាត្រា** | សមាជិក |
| ១៧. លោកស្រី **ង៉ែត ម៉ូវីឡែន** | សមាជិក |
| ១៨. លោក **ឈាង វណ្ណារិទ្ធ** | សមាជិក |
| ១៩. លោក **ហៃ សុវុឌ្ឍា** | សមាជិក |

| | |
|---|---|
| ២០. លោក **គីម កែវមុនីរត្ន៍** | សមាជិក |
| ២១. លោក **ពៅ រិទ្ធជ័យសិទ្ធ** | សមាជិក |
| ២២. លោក **សេង តុលា** | សមាជិក |
| ២៣. លោក **ទី អាទិត្យ** | សមាជិក |
| ២៤. លោក **ផាន់ តេត** | សមាជិក |
| ២៥. លោក **ម៉ិញ ឃានសុវណ្ណអាទិច្ចាសីលា** | សមាជិក |
| ២៦. លោក **អ៊ុក សុផា** | សមាជិក |
| ២៧. លោក **អ៊ុំ យុទ្ធី** | សមាជិក |
| ២៨. លោក **លី ទ៉ុង** | សមាជិក។ |

សម្រាប់កិច្ចការនេះ សមាសភាពលេខាធិការដ្ឋាន ដែលបានចូលរួមរៀបចំ មានដូចតទៅ÷

| | |
|---|---|
| ១. ឯកឧត្តម **យ៉េត វីណែល** | ប្រធាន |
| ២. ឯកឧត្តម **ស៊ាង ផល្លា** | អនុប្រធាន |
| ៣. លោក **អ៊ុក សុផា** | អនុប្រធាន |
| ៤. លោក **អ៊ុំ យុទ្ធី** | អនុប្រធាន |
| ៥. លោក **លី ទ៉ុង** | អនុប្រធានប្រចាំការ |
| ៦. លោក **សាយ អ៊ាន** | សមាជិក |
| ៧. លោក **រស់ សុខណារុណា** | សមាជិក |
| ៨. លោក **ឈាន សាមឌី** | សមាជិក |
| ៩. លោក **យន ម៉ាលីមឆេង** | សមាជិក |
| ១០. លោក **ហ៊ែល ប៊ុនថាន** | សមាជិក |
| ១១. លោក **ឈឹម ចាន់ដារ៉ូ** | សមាជិក |
| ១២. លោក **ឈាង ដាមី** | សមាជិក |

១៣. លោក **ដៀប ពិសិដ្ឋ** សមាជិក

១៤. កញ្ញា **អំ វីណា** សមាជិក

១៥. លោក **សូ សុភា** សមាជិក

១៦. លោក **ប៊ុន ហៃ** សមាជិក

១៧. លោក **អ៊ុច សោភ័ណ** សមាជិក

១៨. លោកស្រី **ស៊ុម ច័ន្ទសូរិយា** សមាជិក

១៩. លោក **ប៉ុម លៃហេង** សមាជិក

២០. លោក **សុខ ច័ន្ទកិត្យា** សមាជិក

២១. លោក **ហ៊ីម សុវណ្ណដារ៉ា** សមាជិក

២២. លោក **ឈិត សុចន្ទ្រា** សមាជិក

២៣. លោក **ផល សូលី** សមាជិក

២៤. លោក **អ៊ុង មករា** សមាជិក

២៥. លោក **នួន រតនៈសម្បត្តិ** សមាជិក

២៦. កញ្ញា **ហ៊ួត សំណាង** សមាជិក

២៧. លោក **ហាក់ រដ្ឋា** សមាជិក

២៨. លោក **ចាយ សេរីវឌ្ឍន៍** សមាជិក

២៩. លោក **អឿន វណ្ណារ៉ា** សមាជិក

៣០. កញ្ញា **អ៊ូ សុផាន់ផា** សមាជិក

៣១. កញ្ញា **តួន សុភាព** សមាជិក។